00315803

**Decalssified to Public**
**06 September 2012**

E1/9.1

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរ</u>
# <u>នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"</u>
# <u>សម្ងាត់</u>

## សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី៥)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម សួយហុង

លោក ម៉ាត្ទូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក រ៉ូប៊ឺត ពេទីត *(Mr. Robert Petit)*

លោក យ៉េត ចរិយា

លោក វាលៀម ស្មីត *(Mr. William Smith)*

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ ប៊េត

*(Mr. Alexander Bates)*

លោក ជឺហ្គិន អាស្មាន*(Mr Jurgen Assmann)*

លោក ប៉ាក ចាន់លីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ៖**

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គង់ ពិសី

លោក យុង ផានិត

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោក ហ្វីលីព កាណុន

*(Mr. Philippe Canonne)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

# សាក្សី

**សាក្សី៖** ជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ ឌុច

សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ចាប់ផ្ដើបន្ត ......................................................... ...ទំព័រ២

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី.........................................................................................ទំព័រ៤៧

សួរដោយ លោកស្រី ជា លាង ផ្ដើមពី...................................................................................ទំព័រ៥៤

សួរដោយ លោក រ៉ូប៊ីត ពេទីត ផ្ដើមពី.................................................................................ទំព័រ៥៧

សួរដោយ លោក អាឡាំង វ៉ែនណឺ ផ្ដើមពី............................................................................ទំព័រ៧២

សួរដោយ លោក យុង ផានិត ផ្ដើមពី..................................................................................ទំព័រ៧៨

សួរដោយ លោក ហ្វីលីព កាណុន ផ្ដើមពី.............................................................................ទំព័រ៨១

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ដាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក ហ្វីលីព កាណុន | បារាំង |
| លោកស្រី ជាលាង | ខ្មែរ |
| ក្រឡាបញ្ជី | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក រ៉ូបឺត ពើទីត | អង់គ្លេស |
| លោក ហ្វ្រង់ស្វ័រ រ៉ូ | បារាំង |
| លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ, បារាំង |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |
| លោក យុង ផានិត | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៨:០០]

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ជាដំបូងនេះ អញ្ជើញក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាននិងអវត្តមានភាគី ដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរនីតិវិធីនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ។ ខ្ញុំបានត្រួតពិនិត្យវត្តមាននិងអវត្តមានភាគី ដែលបានចូលរួមក្នុងដំណើរការនីតិវិធីរួចរាល់ហើយ ។ ដែលក្នុងថ្ងៃនេះ មានមេធាវីការពារជនជាប់ចោទអវត្តមានម្នាក់ គឺលោកមេធាវី ការ សាវុត្ថ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីបញ្ចូលនៅបញ្ជីវត្តមាន អវត្តមានភាគី ដែលត្រូវអញ្ជើញចូលរួមនៅក្នុងនីតិវិធីដំណើរការសវនាការនៅព្រឹកនេះទៅក្នុងប្រតិចារឹក ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទមកកាន់ឈើរាងវង់ក្រចកសេះ ដែលបានត្រៀមទុកសម្រាប់ជនជាប់ចោទ ។

[០៩:១០:៤៥]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន ខ្ញុំគិតថា អាចនឹងជាការល្អដើម្បីពិនិត្យមើល ដើម្បីអតីតអនាគតអ្នកសាក្សី គឺគាត់មិនត្រូវវត្តមាននៅក្នុងសាលសាធារណៈទេ ហើយគាត់នឹងបង្ហាញខ្លួននៅពេលក្រោយ ។ ប៉ុន្តែ គេមិនអាចចូលរួមនៅក្នុងសវនាការពេលនេះបានទេ ។

*[ចៅក្រមពិភាក្សាពីម៉ោង០៩:១១:០៩ រហូតដល់ ម៉ោង០៩:១៥:០០ ]*

[០៩:១៥:២៤]

**ប្រធានអង្គជំនុំ៖**

អង្គជនុំជម្រះសូមជម្រាបថា អស់លោកស្រី ដែលមានឈ្មោះជាសាក្សីនៅក្នុងដំណើរការនីតិវិធីសវនាការរឿងក្ដីនេះ មិនត្រូវបានអនុញ្ញាតឲ្យចូលមកអង្គុយមើលដំណើរការសវនាការនៃដំណើរការរឿងក្ដីនេះទេ ដែលវាផ្ទុយទៅនឹងវិធានផ្ទៃក្នុងស្ដីពីសាក្សីនេះ ។

ទីពីរ គឺនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញាក្នុងតុលាការកម្ពុជានេះមានអង្គភាពមួយទៀត គឺអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើការជាមួយនឹងអង្គភាពនោះជាញឹកញាប់ហើយ អំពីកិច្ចដំណើរការប្រព្រឹត្តិទៅឲ្យបានល្អត្រឹមត្រូវតាមវិធាននេះ ។ ដូច្នេះចាប់ពីពេលនេះតទៅ ប្រសិនបើអស់លោក លោកស្រីជាសាក្សីនោះ គឺមានកាតព្វកិច្ចមួយ គឺត្រូវចាកចេញពីបន្ទប់សវនាការ ហើយមិនអនុញ្ញាតឲ្យចូលមុនពេលត្រូវធ្វើសក្ខីកម្មនោះទេ ។ ទីពីរ គឺអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សូមធ្វើការសម្របសម្រួលបញ្ហានេះឲ្យបានត្រឹមត្រូវតាមវិធាន និងតាមអ្វីដែលបានពិភាក្សាគ្នាកន្លងមក ។

ដំណើរការសវនាការពីម្សិលមិញ យើងបានដំណើរការកំពុងតែធ្វើការសាកសួរជនជាប់ចោទពាក់ព័ន្ធទៅនឹងអង្គហេតុមន្ទីរសន្តិសុខម-១៣ដែលត្រូវបានសាកសួរដោយចៅក្រម ហ្សង់ម៉ាក ។ ហើយនៅព្រឹកនេះយើង អង្គជំនុំជម្រះបន្តកិច្ចដំណើរការនេះតទៅទៀត ហើយសូមអញ្ជើញលោក ហ្សង់ម៉ាក បន្តនៅសំណួរដែលមានការប៉ុនប៉ងសួរដល់ជនជាប់ចោទ ពាក់ព័ន្ធជាមួយអង្គហេតុដែលបានជម្រាបនេះ ។ សូមអញ្ជើញ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

យើងនឹងបន្តជាមួយការសួរសំណួរ ។ ខ្ញុំសូមលើកសំណួរទៅលោកផ្ទាល់ ទាក់ទងទៅនឹងៗលក្ខខណ្ឌនៃការឃុំខ្លួនអ្នកទោសនៅក្នុង ម-១៣ ។

**ស៖** តើលោកអាចពន្យល់ប្រាប់យើងបានទេ ថាតើវិធានការសន្តិសុខអ្វីខ្លះ ដែលត្រូវបានយកមកអនុវត្តដើម្បីធានាថា អ្នកទោសទាំងនោះមិនអាចរត់គេចខ្លួនបាន នៅពេលដែលជាប់នៅក្នុងមន្ទីរឃុំឃាំង ហើយនិងរបងយ៉ាងម៉េច? លក្ខខណ្ឌម៉េចខ្លះ?

**ជនជាប់ចោទ៖**

**ឆ៖** បញ្ហានេះ ដំបូងយើងខ្ញុំទុកមនុស្សសម្រាប់បង្កបង្កើនផល ។ នេះជាដំណាក់ទីពីរទៅហើយ

ទេ ។ ដំណាក់ទីមួយ ទុកនៅលើកផ្ទះហ្នឹង សម្រាប់តែសួរចប់ ហើយន្ទាលនឹងយកទៅកម្ទេច ។ ដល់ដំណាក់ទីពីរ យកចេញទៅពីឃុំទួលស្វាយមាស តំបន់ស្វាយមាសហ្នឹង ដើម្បីធ្វើស្រែ ។ ខ្ញុំមិនបានជាគិតគូរអីស្អីវែង ឆ្ងាយទេ យប់ដាក់ខ្នោះ ថ្ងៃឡើងឲ្យគេធ្វើការ ។ នៅពេលដែលខ្ញុំមកនៅហ្នឹង ខាងពួកជនរងគ្រោះ ដែលមកជាប់ទោសហ្នឹង គេឆក់កាំភ្លើងអាកាបាន គេបាញ់កងការពារ ហើយគេនាំគ្នាមនុស្សហ្នឹងរត់ទៅអស់ទៅ ។ តាំងពីពេលនោះមក ខ្ញុំក៏ប្ដូរកន្លែងមកនៅត្រពាំងច្រាប ដូចខ្ញុំបានជម្រាបម្សិលមិញអីចឹង ។

ដល់មកនៅត្រពាំងច្រាបហ្នឹង យប់ដាក់ខ្នោះ ថ្ងៃចេញធ្វើការ ។ ស្រីអត់មានធ្វើស្អីទេ គឺដាំត្រប់ដាំបន្លែនៅចន្លោះត្រពាំងច្រាប ហើយនិងគុក ។ ឯចំណែកប្រុស ថ្ងៃខ្ញុំខ្លួនឯងផ្ទាល់ហ្នឹង ជូនទៅធ្វើការលើកទំនប់ មិនមែនជូនទៅផ្ទាល់កាន់កាំភ្លើងខ្លួនឯងទេ ខ្ញុំជឿទុកចិត្តខ្លួនឯងថា ឆ្លាត ។ ឆ្លាត ត្រង់ដែររហ័សយល់ភេទ តើគេប្រុងឆក់កាំភ្លើង ឬយ៉ាងម៉េច? អ្នកកាន់កាំភ្លើងចេញទៅអ្នកផ្សេងទេ ក៏ប៉ុន្តែវិធានការដែលអ្នកនាំមនុស្សយកទៅហ្នឹង គឺដូចខ្ញុំបានជម្រាបលោកចៅក្រមម្សិលមិញហើយ ។ ចងនឹងខ្សែរអង្រឹងភ្ជាប់គ្នា ។ ចងក។នេះជាប់គ្នាឲ្យវាឆ្ងរទេ ។ មួយខ្សែរអង្រឹងហ្នឹងបីនាក់ ហើយខ្ញុំជាអ្នកទៅមើលទេ មិត្តយើងផ្សេងទៀត ក្មេងៗហ្នឹង គេកាន់កាំភ្លើងយាម ហ្នឹងជៀសមិនឲ្យរត់រួចមួយបែប ។ តែមួយបែបទៀត យើងខ្ញុំរកស្អីសង់ផ្ទះសង់អីមិនបានទេ សភាពការណ៍ក្រ ។ ដោយសភាពការណ៍ក្រអ៊ីចឹងទៅកាប់ឃ្លី តំបន់នោះ សម្បូរឃ្លីណាស់ ដើមឃ្លី ។ ដែលហៅថា ឃ្លីហ្នឹង គឺជាឬស្សីមួយបែប យកមកហាល ត្រាំទឹក ត្បាញ់ជាប្រដឹស ហើយលើកជារបងជុំវិញកន្លែងឃុំឃាំងហ្នឹង គ្មានផ្ទះ គ្មានជញ្ជាំងក្ដារអីទេ ។ ដល់ធ្វើជញ្ជាំងឃ្លីហ្នឹងហើយ យើងខ្ញុំជីករណ្ដៅដូចបានជម្រាបម្សិលមិញអ៊ីចឹង ។ ជម្រៅប្រហែលជា២ម៉ែត្រ ទទឹង២ម៉ែត្រ បណ្ដោយប្រហែល៣ម៉ែត្រ ហើយប្រក់ដំបូលពីលើ ។ ហ្នឹងការពារកុំឲ្យគ្រាប់ផង ហើយកុំឲ្យជនរងគ្រោះ ដែលជាប់ទោសនុ៎ង ងើបឡើងរត់រួចផង ។ ប៉ុណ្ណឹងហើយនៅថែមយប់ដាក់ខ្នោះជើងទៀត ទាំងស្រី ទាំងប្រុស ។ ស្រីក៏ដាក់ខ្នោះជើងដែរអង្គាល់នុ៎ង ។ នេះជាវិធានការដែលយើងខ្ញុំធ្វើដើម្បីការពារកុំគេរត់ ហើយកុំឲ្យគេឆក់កាំភ្លើងអីវៃដូច គ្រោះថ្នាក់ពីកាលនៅភ្នំពីសហ្នឹង នៅជើងភ្នំពីស នៅតំបន់នោះគេហៅ ទួលស្វាយមាស ឬតាលាវ ។

**ស៖** តើអ្នកយាមមានការណែនាំអ្វីពិសេសចំពោះករណី ដែលថាមានអ្នកទោសរត់គេចខ្លួនដែរឬទេ?

[០៩:២២:៤០]

**ឆ៖** ខ្ញុំៗ ភ្នែកខ្ញុំវៃ ខ្ញុំៗឃើញបញ្ហាហ្នឹង ខ្ញុំជឿថា ភ្នែកខ្ញុំវៃជាងគេ ។ ចំពោះអ្នកដែលចង់រត់ គ្មាននរណាមួយរហ័សជាងខ្ញុំទេ ក្នុងចំណោមពួកបុគ្គលិកមន្ទីរ១៣ ។ សូម្បីតែ ម៉ម ណៃ ក៏មើលមិនទាន់ខ្ញុំដែរ ។ បើកាលណាខ្ញុំឃើញថា ជនរងគ្រោះម្នាក់ដែលត្រូវជាប់ទោសនៅហ្នឹងប្រុងរត់ ខ្ញុំចាប់ ឲ្យគេចាប់ សួរចម្លើយ ឬក៏ចាប់ទុកនៅនុ៎ងមិនឲ្យចេញ ។ ដូច្នេះ ឲ្យតែខ្ញុំបានសង្កេត បានពិនិត្យ វាច្បាស់របស់ខ្ញុំ ។

ឯចំណែកអ្នកដែលរត់រួចទៅហើយ ជាគោលការណ៍កំណត់ គឺឲ្យខ្ញុំរាយការណ៍ទៅលើ ។ រត់ដឹងរត់ភ្លាម រាយការណ៍ភ្លាម ឲ្យតែជនណាដែលរត់ចេញពីមន្ទីរ១៣ ហើយតែខាងកងទ័ព ឬខាងមូលដ្ឋានគេចាប់បាន គេអត់ឲ្យត្រឡប់មកវិញទេ គេកម្ទេចនៅឯនុ៎ងឯង ។ ដូច្នេះ នេះជារឿងពិត ដែលប្រព្រឹត្តទៅជាប្រចាំនៅ ម-១៣ ។

**ស៖** តើអ្នកយាមមានអាវុធកាន់ ហើយតើអ្នកយាមនោះមានការណែនាំទាក់ទងថាទៅ ហ្នឹងប្រើអាវុធ នៅពេលណា ប្រសិនបើអ្នកទោសព្យាយាមរត់គេចខ្លួននោះ?

**ឆ៖** កងការពារនឹងមានកាំភ្លើង ពិត ។ កាលណាអ្នកណារត់ហើយត្រូវតែបាញ់ នេះក៏ជារឿងពិត ។ ខ្ញុំសូមនិយាយបញ្ហាមួយ ព្រឹត្តការណ៍ហ្នឹងវាកើតហើយ ដើម្បីជាឧទាហរណ៍ថា អ្នករត់ហើយត្រូវតែបាញ់ ។

ពេលនោះខ្ញុំមិននៅ ខ្ញុំទៅធ្វើការ មានជនរងគ្រោះដែលជាអ្នកទោសរត់ ។ រត់ បង ម៉ម ណៃគាត់ ដេញបាញ់ បាញ់នឹងកាំភ្លើងពីស្នូលេគាត់ កាំភ្លើងពីស្នូលេចិន ។ មិត្ត សឿង កងការពារខ្ញុំម្នាក់បាញ់ត្រង់ណាស់ លើកកាំភ្លើងឡើងច្រឡំបង ម៉ម ណៃ ថាពួកអ្នករត់ ។ បាញ់ផ្ទង់ របួសបង ម៉ម ណៃ។

ដូច្នេះ អារឿងដេញបាញ់អ្នករត់ដែលជាជនរងគ្រោះមកជាប់ទោស វាច្រឡំគ្នាឯងនេះ ជាគោលការណ៍ដែលខ្ញុំលើកឡើង ដើម្បីជម្រាបថា វាពិតជាមានបទបញ្ហាមួយថា បើការរត់ត្រូវតែបាញ់ ។ ក៏ប៉ុន្តែ សូមបញ្ជាក់បន្ថែមថា បង ម៉ម ណៃ អត់មានគំនុំគុំកួនអីនឹងមិត្ត សឿង ទេ ។ មិត្ត សឿង ឥឡូវរស់នៅជាមួយនឹងគាត់ បានប្រពន្ធបានកូនអីអស់ទៅហើយ ។

[០៩:២៦:១១]

**ស៖** ដូច្នេះការណែនាំ គឺធ្វើយ៉ាងណាត្រូវតែបាញ់អ្នកទោសណាម្នាក់ដែលព្យាយាមរត់គេចខ្លួនមុនពេលដែលលោកឆ្លើយ ខ្ញុំសូមឲ្យលោកចាប់អារម្មណ៍ថា ទៅអង្គហេតុដែលថាបញ្ជី ដែលបានចែកជូនពីម្សិលមិញនោះ ដោយមានរហស្សនាមដែលលោកត្រូវប្រើទាក់ទៅនឹងឈ្មោះសាក្សីទាំងអស់នោះ ។ ខ្ញុំសូមឲ្យលោកចាប់អារម្មណ៍ប្រើរហស្សនាមហ្នឹង កុំថាឈ្មោះ ដោយហេតុថា យើងមានផ្សាយបន្តផ្ទាល់

ហើយប្រសើរបំផុតប្រសិនថា យើងអាចប្រើជារហស្សនាម កុំឲ្យហៅឈ្មោះសាក្សី ឬជនណាម្នាក់ ។ តើលោកចង់ឲ្យមេធាវីរបស់លោក ប្រាប់ពីគំនិតហ្នឹង បានច្បាស់ដែរឬទេ?

ដើម្បីបន្តទៅទៀតលោកបានបញ្ជាក់ថា ការណែនាំនោះ បើសិនជាអ្នកទោសព្យាយាមរត់ ហើយអ្នកយាមត្រូវតែបាញ់ តើអ៊ីចឹងពិតទេ?

[០៩:២៨:០៧]

លោកក៏បានបញ្ជាក់ដែរថា នៅពេលកន្លងទៅនោះ គឺថាបើសិនជាមានការប៉ុនប៉ងគេចខ្លួន អ្នកយាមគឺថាត្រូវតែប្រើកាំភ្លើងដើម្បីបាញ់ ។ ប៉ុន្តែ ម្សិលមិញនោះ ខ្ញុំចាំមិនច្បាស់ទេ លោកបានបញ្ជាក់ថា គឺថាមានអ្នកឃុំ-- ជាប់ឃុំបានព្យាយាមគេចខ្លួនមួយចំនួន ហើយលោកបានរាយការណ៍ថា នៅក្នុងហេតុការណ៍មួយ លោកបានរាយការណ៍ទៅថ្នាក់លើ ហើយទៅលោក វន វ៉េត ។ ហើយលោកស្នើសុំឲ្យ វន វ៉េត ដាក់ទោសកំហុសលោក ។ តើលោកអាចប្រាប់យើងបានទេថា តើក្រោមលក្ខខណ្ឌអ្វីខ្លះ ដែលថា វាមានហេតុការណ៍ហ្នឹង កើតឡើងចុងក្រោយនោះ មានលក្ខខណ្ឌអី ដែលវាកើតហេតុការណ៍នោះហ្នឹង?

**ឆ៖** សូមអរគុណលោកចៅក្រមហើយ ដែលលើកបញ្ហាពីរនេះមក ដែលលោកចៅក្រមលើកបញ្ហាពីរនេះមកសួរខ្ញុំក្នុងពេលតែមួយជាមួយគ្នា ។ បញ្ហានេះមានទាក់ទងគ្នាបន្តិច ។

ទីមួយ ពេលដែលគេរត់រួចនៅអីខាងភ្នំពីសនោះ គឺមានមិត្តម្នាក់ខ្ញុំឲ្យគាត់ឡើងយាមលើដំបូកគាត់ឈរ អង្គុយយាមនៅលើដំបូកនោះ ។ នៅពេលនោះ ខ្ញុំអត់នៅទេ ខ្ញុំទៅធ្វើការជាមួយនឹងភូមិភាគដល់មិត្តដែលអង្គុយយាមលើដំបូកហ្នឹង គាត់ជាអ្នកចេះជក់ថ្នាំ ។ មានជនរងគ្រោះដែលជាប់ទោសនៅទីនោះ អ្នកមាឌធំ ឈ្មោះ រឿង នៅតែទៅសុំថ្នាំគាត់ជក់ ។ ដល់ទៅគាត់ភ្លេចខ្លួន ជននោះទៅជិតខ្លួនបានឆក់កាំភ្លើង *អា.កា* (AK) ពីគាត់ដេញបាញ់កងការពារពាសណាពាសណី ។ ម៉ោងប្រាំល្ងាច បានគេរាយការណ៍ ដល់ខ្ញុំ ម៉ោងប្រាំពីរយប់បានខ្ញុំទៅដល់កន្លែងភូមិភាគ សូមចូលជួប វន វ៉េត ដើម្បីរាយការណ៍ពីសភាពការណ៍ជាក់ស្តែង ។

ដូច្នេះពេលនុំង យើងគ្មានបាញ់អីគេទាន់ទេ កងការពារគ្មានបាញ់អ្នករត់រួចហ្នឹងបានទេ គឺមានតែគេបាញ់ ។ បាញ់របួសមិត្ត ប៉ុន, បាញ់របួសមិត្ត មាស, បាញ់របួសមិត្ត ម៉ៅ អីច្រើន ។ នេះជាព្រឹត្តិការណ៍ទីមួយ ។ ឯចំណែកព្រឹត្តិការណ៍ទីពីរ គឺមានរឿងបាញ់អ្នកទោសម្នាក់នៅមន្ទីរ-១៣ រវាងឆ្នាំ៧៣ ជនរងគ្រោះដែលជាប់ទោសហ្នឹងឈ្មោះ យ៉ឺ ខ្ញុំភ្លេចហើយមិនជាមកពីស្រុកណាទេ ។ ខាងលើត្រូវការ

ចម្លើយរបស់បុគ្គលនេះដែរ ដើម្បីតាមដានរកកាំភ្លើង ។ គាត់ច្រងេងច្រងាងពេក ខ្ញុំភ័យខ្លាចកើតមានគ្រោះថ្នាក់ដូចអង្កាលនោះទៀត ខ្ញុំស្ទុះទៅរាយការណ៍ឲ្យ ជូ ជេត ហៅ ស៊ី នៅមិនឆ្ងាយពីខ្ញុំប៉ុន្មានទេ ប្រហែលជាដប់គីឡូ មិនដល់ផង ។ ដល់រាយការណ៍សព្វគ្រប់នឹងទៅ ជូ ជេត សម្រេចហ្នឹងវាហួសបំណងខ្ញុំហើយ ។

បំណងខ្ញុំគឺគ្រាន់តែសូមឲ្យខាងលើ ចង់ឲ្យលើអនុញ្ញាតឲ្យគេយកទៅកម្ទេចតាមធម្មតាស្ងាត់ៗ ។ ស្រាប់តែសេចក្តីសម្រេច ជូ ជេត គាត់ប្រើឲ្យខ្ញុំបញ្ជាឲ្យមិត្តម្នាក់ដែលបណ្តោយខ្លួនឲ្យគេឆក់កាំភ្លើងបានហ្នឹង បាញ់ឈ្មោះ យ៉ើ ហ្នឹងដោយផ្ទាល់ដៃហើយឲ្យបាញ់ចំសំដៅក្បាល ។ ខ្ញុំតក់ស្លុតដែរ មកដល់គ្រាន់តែប្រាប់បទបញ្ជាហ្នឹងទៅ ឲ្យមិត្តដដែលហ្នឹងបាញ់ ឯខ្ញុំគេចហើយ ។ ប៉ុន្តែ តាមដំណឹងក្រោយមកឮល្បីថា ផ្កាយខ្មួរខ្មាតទៅលើអ្នកផ្សេងទៀត ធ្វើឲ្យអ្នកដែលនៅទីនោះតក់ស្លុត ។ ហើយគោលបំណងរបស់បងស៊ី ជូ ជេត ហៅ ស៊ី ហ្នឹងបញ្ជាមកឲ្យខ្ញុំក៏ធ្វើឲ្យជនរងគ្រោះដែលជាអ្នកទោសផ្សេងទៀតនោះតក់ស្លុត ។ នេះគោលបំណងពិត ។

សូមបញ្ជាក់ជូនលោកចៅក្រមថា មិត្តនុំងក្រោយពីបាញ់ហើយ គាត់មានការសោកស្តាយក្នុងខ្លួនតក់ស្លុត មិនបានប៉ុន្មានថ្ងៃគាត់សុំខ្ញុំចេញទៅ ។ ខ្ញុំក៏មានចិត្តអាណិតអាសូរគាត់ដែរ គាត់ចេញទៅបាត់ ។ ឥឡូវខ្ញុំបាត់ដំណឹងគាត់ទៅ មិនទាន់ដឹងជារត់ស្លាប់ ឬរស់ទេ ។ ប៉ុន្តែ ឧក្រិដ្ឋកម្មទាំងអស់នេះ ខ្ញុំមិនផ្តើយដាក់ទៅលើមិត្តនុំងទេ ថ្វីតែមានរឿងជាប់គ្នាអ៊ីចឹងក៏ដោយ ។ ហើយក៏មិនផ្តើយដាក់ទៅលើបងស៊ី ជាអ្នកសម្រេចដែរ ។ គឺខ្ញុំទទួលឧក្រិដ្ឋកម្មមួយដែលរាងមានលក្ខណៈឃោរឃៅ ហើយចំហ មិនមែនតែទៅលើបុគ្គលម្នាក់ដែលស្លាប់នោះទៅទេ ។ មានទៅលើបុគ្គលដទៃទៀតដែលនៅរស់ យើងកំញើញគំរាមសតិអារម្មណ៍គេ ជាជាងកាលដែលខ្ញុំជាប់គុកនៅខ្ទាំងនៅព្រៃសទៅទៀត ។

*(មានបញ្ហាខាងបកប្រែ)*

អ្នកបកប្រែ៖ សូមអភ័យទោសបកប្រែរីឡេ អ្នកទទួលបកអត់បាន។

[០៩:៣៤:៥៥]

**ចៅក្រម រ៉ូប៊ើត ពើទីត៖**

លោកប្រធាន ខ្ញុំគិតថា ប៉ុស្តិ៍លេខពីរ ។ ដល់អ៊ីចឹងហើយវាប្តូរប៉ុស្តិ៍លេខមួយនិងលេខពីរ ទៅជាបារាំង អង់គ្លេស ។ អ៊ីចឹងគឺថា នៅពេលដែលមីក្រូហ្វូនរបស់ជនជាប់ចោទបិទ គឺថាអ្នកបកប្រែអាចប្រាប់យើង ថាតើប៉ុស្តិ៍ណាភាសាអ្វី ។ ប៉ុស្តិ៍លេខមួយភាសាខ្មែរ, ពីរ ភាសាអង់គ្លេស ហើយប៉ុស្តិ៍លេខបី

ភាសាបារាំង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើស្តាប់បាន-- តើដំណើរការបានទេ?

**ចៅក្រម រ៉ូប៊ឺត ពើទីត៖**

បាន ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ដូច្នេះលោកបានបញ្ជាក់ថាពីហេតុការណ៍ទីមួយ ។ ហើយខ្ញុំចង់ដឹងតទៅទៀត ថាតើវាទាក់ទងទៅនឹងការរត់គេចរបស់អ្នកឃុំខ្លួន អ្នកទោសជាច្រើនទេក្នុងហេតុការណ៍ហ្នឹង?

**ជនជាប់ចោទ៖**

**ឆ៖** អ្នកដែលរត់កាលលើកទីមួយនោះ ប្រហែលជាសាមសិបនាក់ ។ បានន័យថា អ្នកដែលជាប់ឃុំទាំងប៉ុន្មានរត់ទៅទាំងអស់គ្នា អត់មានសល់ម្នាក់ទេ ។

**ស៖** អ៊ីចឹងនៅក្នុងហេតុការណ៍ហ្នឹង លោកបានពាក់ព័ន្ធផ្ទាល់ទេ? លោកបានរាយការណ៍ភ្លាមទៅថ្នាក់លើទេ ដោយស្នើសុំវិធានការណ៍ដើម្បីដាក់ទណ្ឌកម្មអ្នកដែលបណ្តែតបណ្តោយឲ្យគេរួចខ្លួននោះឬទេ?

**ឆ៖** ខ្ញុំរត់រកម៉ូតូគេ ឲ្យប្រធានភូមិ-- ឃុំអមលាំងជូនខ្ញុំទៅ ម៉ោងប្រាំពីរខ្ញុំទៅដល់មេខ្ញុំ វន វ៉េត ។ ខ្ញុំសុំចូលរាយការណ៍ទាំងយប់ បានទាំងយប់ ។

**ស៖** តើហេតុការណ៍ហ្នឹង ត្រូវមានការកែតម្រូវតាមរបៀបមួយ ដើម្បីឲ្យមានការឃ្លាំមើលអ្នកទោសគ្រប់ពេល ដើម្បីជៀសវាងហេតុផលហ្នឹងទេ ឬផលពិបាកហ្នឹងទេ?

**ឆ៖** ក្រោយពីព្រឹត្តិការណ៍នេះ ខ្ញុំដូចបានជម្រាបលោកចៅក្រមហើយ សូមឲ្យ វន វ៉េត គាត់ដាក់ទោសខ្ញុំ ។ ហើយយូរបន្តិចមកបានឃើញអ្នកទោសទៅដល់យូរមួយៗ ។ វិធានការនៅដដែលទេ គឺដាក់ខ្នោះទាំងយប់ទាំងថ្ងៃមិនឲ្យចេញ ។ ពីលើកមុនដាក់ខ្នោះតែយប់ ថ្ងៃឲ្យចេញទៅធ្វើការ ដល់ពេលនេះមនុស្សមកមួយ-ពីរអ៊ីចឹង យប់ដាក់ខ្នោះ ថ្ងៃក៏ដាក់ខ្នោះដែរ លើកលែងតែពេលយកទៅសួរ ។ នេះវិធានការដំបូង ។ ដល់ក្រោយមកមនុស្សចេះតែច្រើនទៅ ខ្ញុំក៏ឆ្លៀតបញ្ចេញយកទៅធ្វើស្រែខ្លះ ។ ពេលហ្នឹងដែលចាប់ផ្តើមមានរបងខ្លី ពេលហ្នឹងដែលចាប់ផ្តើមជីកដីដាក់ការពារគ្រាប់ផង ហើយការពារកុំឲ្យជនរងគ្រោះទៅជាប់ទោសហ្នឹងរត់រួចផង ។

[០៩:៣៨:៥៧]

**ស៖** អ៊ីចឹងលោកប្រាប់យើងថា យើងបានជីករណ្តៅដើម្បីជៀសវាងកុំឱ្យអ្នកទោសរត់រួច អ៊ីចឹង មែនទេ?

**ឆ៖** វាជារឿងពិត ចៅក្រមលោកគិតមើលចុះ កំពស់ប្រហែលជាពីរម៉ែត្រ វាផុតក្បាលមនុស្ស ហើយ ឡើងចុះដាក់ជណ្តើរ ។ ដូច្នេះគ្នាមិនងាយនឹងរត់ដែរ បើយើងដាក់គេទៅក្នុងរណ្តៅនោះហើយ ។

**ស៖** តើមានរណ្តៅច្រើន ឬក៏រណ្តៅរួម ឬក៏រណ្តៅមួយសម្រាប់អ្នកទោសច្រើន?

**ឆ៖** កាលដែលមានអ្នកទោសតែម្នាក់នោះ ខ្ញុំអត់បានជីករណ្តៅទេ ។ ខ្ញុំជីករណ្តៅនៅសម័យ ពេលដែលមាន បេ-៥២ហ្នឹង ។ ដែលនឹកឃើញជីករណ្តៅនៅសម័យមាន បេ-៥២ ។ ដូច្នេះ អ្នកទោស ប្រហែលជាប្រាំនាក់យ៉ាងតិច ប្រាំអ្នកទោដប់នាក់យ៉ាងច្រើនប៉ុណ្ណឹងឯង ។

ដូច្នេះ គ្មានរណ្តៅសម្រាប់បុគ្គលឯកជនម្នាក់ទេ ។ ខ្ញុំបែកគំនិតធ្វើ *ស៊ែឡ៊ី* ឯកជននៅពេលដែល ខ្ញុំកាន់កាប់ស-២១ នៅពេលបាន*លីសហ្សេផ្ទេយ៉ា (?)*ហើយទេ ។

**ស៖** *(មិនមានការបកប្រែ)?*

[០៩:៤០:០០]

**ឆ៖** សូមលោកចៅក្រមសួរខ្ញុំម្តងទៀត ។

**ប្រធានអង្គជំនុំ៖**

ខាងអ្នកបច្ចេកទេសមើលសម្របសម្រួលបញ្ហាមីក្រូហ្វូនហ្នឹងឱ្យបានល្អ ជាងនេះមើល៍!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** សំណួរខ្ញុំ តើមានរណ្តៅសម្រាប់អ្នកទោសរួម ឬក៏មានរណ្តៅមួយសម្រាប់អ្នកទោសម្នាក់ ដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ខ្ញុំចាប់ផ្តើមមានគំនិតឱ្យជីករណ្តៅនេះ គឺនៅសម័យចាប់ផ្តើមមានអាបេ-៥២ (B-52) ។ ដូច្នេះ ជីកទទឹងពីរម៉ែត្របណ្តោយបីម៉ែត្រជម្រៅពីរម៉ែត្រ ។ ម្នាក់ក៏ខ្ញុំដាក់ក្នុងរណ្តៅមួយ ប៉ុណ្ណឹង មកប្អូនប្រាំនាក់ក៏ក្នុងរណ្តៅមួយប៉ុណ្ណឹងដែរ អត់មានកូនរណ្តៅមួយតូចសម្រាប់បុគ្គលម្នាក់ទេ ។

**ស៖** តើរណ្តៅទាំងនោះនៅជិតមាត់ស្ទឹង ឬក៏រណ្តៅទាំងនោះនៅទីតាំងកន្លែងណា? តើរណ្តៅ ទាំងនោះធ្លាប់មានទឹកជំនន់លិចចូលទេ? លិចនៅពេលណា?

**ស៖** ប្រហែលជាប្រាំម៉ែត្រពីមាត់ស្ទឹង ។ ថ្ងៃមួយនោះក្នុងឆ្នាំ១៩៧៣ ប្រហែលជាខែ១០ មុនខែ

១០បន្តិចផងមិនដឹង មានទឹកជន់លិចៗរត់ទាំងអស់គ្នា អណ្តែតទាំងជ្រូកអណ្តែងអីអស់រលីង ។ ជនរងគ្រោះដែលនៅប៉ុន្មានហ្នឹង ខំជញ្ជូនយកទៅដាក់លើទួលចម្ងាយពីនោះប្រហែលជាហាសិបម៉ែត្រ ។ ដូច្នេះ មានទឹកជនមែន ម្តងនៅឆ្នាំ១៩៧៤ ខែ១០ ។

[០៩:៤៣:១៨]

**ស៖** ប្រសិនបើខ្ញុំយល់ច្បាស់ លោកបានប្រាប់យើងថា អ្នកទោសទាំងអស់នោះត្រូវបានប្តូរចេញពីកន្លែងនោះ ។ តើមានអ្នកទោសណាដែលនៅក្នុងរណ្តៅ ហើយលង់ទឹកស្លាប់ដែរឬទេ?

**ឆ៖** ពេលនោះគ្មានជនរងគ្រោះដែលលង់ទឹក អណ្តែតទឹកស្លាប់ទេ ។ ក៏ប៉ុន្តែ នៅពេលដែលគ្នា--មុនដំបូងខ្ញុំអត់ឲ្យចេញទេ ខ្ញុំអត់ទាន់ឲ្យចេញ ខ្ញុំស្មានថាទឹកតិចៗ ។ ដល់ទឹកឡើងត្រឹមនេះ ខ្ញុំថាអ៊ំា មិនបានទេឡើង! ឡើងលើទួល ឡើងលើដីឡើង ។ ឲ្យចេញពីរណ្តៅមក មកឡើងលើដី ។ ដល់ឡើងលើដីសុខភាពគ្នាវាទ្រុឌទៅហើយខ្ញុំបណ្តើរឆ្លងស្ទឹងទៅ ពីរ-បីថ្ងៃមកមានស្លាប់ម្នាក់ពីរមែន ។ ក៏ប៉ុន្តែ អ្នកដែលអណ្តែតទឹក លង់ទឹកងាប់ គឺអត់មានទេ ។

**ស៖** ការជន់ហ្នឹង ជោរជន់ តើលោកបានរាយការណ៍ទៅថ្នាក់លើទេ អំពីទឹកជំនន់លេចទីតាំងនេះនោះ?

**ឆ៖** ខ្ញុំពិតជាបានរាយការណ៍ទៅខាងលើ ក៏ប៉ុន្តែមិនរាយការណ៍បន្ទាន់ ដូចថ្ងៃរឿងដែលគេរត់រួច ពួកនោះរត់រួចទេ ។

**ស៖** ដូច្នេះ នៅក្នុងរបាយការណ៍នេះលោកបាននិយាយ តែពីរចំណុចមួយថា លោកបានចាត់វិធានការ ដើម្បីយកអ្នកទោសហ្នឹងចេញពីកន្លែងមួយដែលៗអាចមានទឹកជំនន់លិចបាន ។

**ឆ៖** ទឹកជន់នោះវាអត់នៅលើសពី៤៨ម៉ោងទេ ។ ដូច្នេះយើងខ្ញុំរង់ចាំទឹកស្រកប្រមូលគ្នាមកនៅកន្លែងដើម វិញរួចហើយចាត់ចែងសព្វគ្រប់ស្រួលបួលហើយ បានខ្ញុំឡើងទៅរាយការណ៍ ។ ដូច្នេះ មិនផ្លាស់កន្លែងជាស្ថាពរទេ គ្រាន់តែជម្លៀសជនរងគ្រោះចេញពីកន្លែងលិចលង់នោះទៅលើទួល ។

**ស៖** ឥឡូវនេះខ្ញុំចង់សួរទាក់ទងទៅនឹងការសួរចម្លើយទៅលើអ្នកទោស តើលោកអាចប្រាប់យើងបានទេ ថាតើមានវិធីសាស្ត្រខុសៗគ្នាដូចម្តេចក្នុងការសួរចម្លើយថា ដែលមានវិធានការអីដែលត្រូវយកមកប្រើដើម្បីសួរចម្លើយអ្នកទោសទាំងនោះ?

**ឆ៖** រឿងនេះ វាមានការ នេះមិនឯកភាពទេ--យើងមិនអាចនិយាយមួយម៉ាត់បានទេ វាច្រើនបែប ។ ដូច្នេះ ខ្ញុំសូមនិយាយពីដំបូង ពីដំបូងហើយខ្ញុំនៅចាំមិនភ្លេចទេ ខ្ញុំបានជម្រាបលោកចៅក្រម

ម្សិលហើយ ឈ្មោះម្នាក់ដែលខ្ញុំសួរចម្លើយនោះ ។ ខ្ញុំខំសួរស្ងួត គាត់មិនឆ្លើយ គាត់នៅតែឆ្លើយថា ចូលមកទិញមាន់ ចូលមកអីឯណា ហើយខ្ញុំបានជម្រាបលោកចៅក្រមម្សិលមិញហើយ ខ្ញុំកំពុងតែសួរហើយហើយពេល ហ្នឹងកំពុងគ្រុនញាក់ផងខ្លួនឯងនេះ ។ ស្រាប់តែកម្មាភិបាលហាណូយពីរនាក់គេមានកាំភ្លើងខ្លី មានអីមក មកដល់គេសេរី វ៉ៃមនុស្សរបស់ខ្ញុំ នៅមុខខ្ញុំ ។ ខ្ញុំវាហួសចិត្តបន្តិចដែរ ដល់គេវ៉ៃ ផស់ចង្កុលមុខចុះឡើង ឃើញឆ្លើយ។ ខ្ញុំខឹងបណ្តោយ ។ យី! អញនិយាយស្លូតអ្អែងមិនស្តាប់ អ្អែងខ្លាចគេកាចខ្លាចគេវ៉ៃហ៎អ្អែង ។ ខ្ញុំក៏ស្ទុះទៅខ្លួនឯងវ៉ៃ ដល់វ៉ៃមនុស្សនោះវាលើកដៃសំពះ អូ៎! តាឯងអាណិតខ្ញុំកុំវ៉ៃទៀត ខ្ញុំក៏ទៅលែងរួចទៅ ។ ដល់ក្រោយមកជាមួយមនុស្សនេះខ្ញុំសួរចប់ចុងចប់ដើម ពេលខ្លះកំញើញវ៉ៃពេលខ្លះក៏វ៉ៃខ្លួនមួយរំពាត់ពីរទៅនេះ ។ ជាភេទមួយដែលខ្ញុំចាំមិនភ្លេច ក្នុងរឿងខ្ញុំសួរផ្ទាល់ខ្លួន ហើយខ្ញុំធ្វើទារុណកម្ម ។

ភេទមួយទៀត នៅចុងក្រោយបំផុតដែលខ្ញុំមានពិសោធន៍ក្នុងរឿងសួរ ក្នុងពេលកាលដែលខ្ញុំដឹកនាំការសួរចម្លើយនេះ ហូរហែមក ខ្ញុំមានពិសោធន៍ ខ្ញុំចង់លរមើលពិសោធន៍ ខ្ញុំសួរមនុស្សម្នាក់ចំណាយពេលប្រហែលជាមួយខែ ។ ឈ្មោះនោះ អូ! មនុស្សនោះឈ្មោះ ង៉ែត សំប៊ុន ហៅ វំពេ ជាអ្នកធ្លាប់សរសេរកំណាព្យឱ្យកាសែត ហើយចូលទៅបង្កប់ខ្លួនក្នុងដីរំដោះ ។ ខ្ញុំចង់មានពិសោធន៍ខ្ញុំប្រថុយសួរខ្លួនឯងលរ មើលចំណាយពេលមួយខែ ។ ខ្ញុំមានវ៉ៃខ្លួនឯងផ្ទាល់ នេះជារឿងពិត ។

សរុបមករឿងទារុណកម្ម ដែលខ្ញុំធ្វើដោយផ្ទាល់ដៃខ្លួនឯង យ៉ាងតិចណាស់ក៏មានពីរនាក់នេះដែរក្រៅពីនោះ ភាគច្រើន ច្រើនតែខ្ញុំសួរ ហើយខ្ញុំណែនាំឱ្យគេធ្វើទារុណកម្ម ខ្ញុំណែនាំឱ្យគេសួរបែបនេះសួរបែបនេះ ហើយខ្ញុំណែនាំឱ្យគេធ្វើទារុណកម្ម ។

ដូច្នេះសរុបមករឿងទារុណកម្ម ទោះបីខ្ញុំណែនាំឱ្យគេធ្វើមិនធ្វើផ្ទាល់ដៃដោយថ្នាក់ខ្ញុំវាតាំងខ្លួនជាធំបន្តិចហ្នឹងក៏ដោយ ក៏ខ្ញុំសូមជម្រាបលោកចៅក្រមដោយស្មោះថា ខ្ញុំទទួលខុសត្រូវលើ ឧក្រិដ្ឋកម្មដែលធ្វើទារុណកម្មមនុស្សនេះ ។ ចម្លើយដែលបានមកពីទារុណកម្មទាំងប៉ុន្មានធ្លាក់ទៅលើអាយុជីវិតអ្នកផ្សេងទៀតក៏ខ្ញុំទទួលដែរ ខ្ញុំអត់ប្រកែកទេ ។ គ្រាន់តែនេះ ខ្ញុំសូមបញ្ជាក់ជូនលោកចៅក្រមអំពីការពិតដែលកើតមាននៅទីនោះ ។ ទោះបីខ្ញុំ ក្នុងឋានៈខ្ញុំតាំងខ្លួនជាស្នងការម្នាក់ដែលបញ្ជាទៅលើអធិការក៏ដោយ ក៏ខ្ញុំនៅតែទទួលខុសត្រូវថា ឧក្រិដ្ឋកម្មនេះវាកើតពីខ្លួនខ្ញុំ ។

សូមទោស ខ្ញុំងាកទៅឃើញមុខលោក ជុំ ម៉ី ខ្ញុំអត់បានទៅវ៉ៃលោក ជុំ ម៉ី ទេ មិត្ត សេង គាត់វ៉ៃលោក ជុំ ម៉ី តែខ្ញុំបញ្ជាឱ្យនៅលើហ្នឹង ខ្ញុំសូមទោសលោក ជុំ ម៉ី ។

**ប្រធានអង្គជំនុំ៖**

យើងធ្វើសវនាការលើអង្គហេតុ ម-១៣ អ៊ីចឹងកុំឲ្យឃ្លាតឆ្ងាយអំពីអង្គហេតុដែលកំពុងដំណើរការសវនាការណាស់ ចំពោះអង្គហេតុដែលពាក់ព័ន្ធជាមួយនឹងករណីអម្បាញ់មិញនេះជារឿងអង្គហេតុផ្សេង ចាំដល់ពេលអង្គហេតុផ្សេងសឹមមានការពាក់ព័ន្ធ ។ សុំបង្វែរមកវិញពាក់ព័ន្ធទៅនឹង សំណួរដែលសួរពាក់ព័ន្ធនឹង ម-១៣ ។

សូមអញ្ជើញបន្តទៀតលោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ ម៉ាកឡាវែន៖**

**ស៖** ដូច្នេះលោកបានជម្រាបយើងថា ថាតើមានបញ្ហាបច្ចេកទេស ឬយ៉ាងម៉េច សូមអភ័យទោស ?

**ឆ៖** ខ្ញុំសូមត្រឡប់មកវិញ សូមទោស ដែលខ្ញុំនិយាយជ្រុលទៅដល់ខាងមុខ ម្ខាង ស-២១ ។ សរុបមកការរៀងធ្វើទារុណកម្ម ទៅធ្វើមន្ទីរនគរបាល ហើយជៀសមិនរួចពីធ្វើទារុណកម្មទេ ទោសឧក្រិដ្ឋទាំងប៉ុន្មានដែលខ្ញុំធ្វើទារុណកម្មជនរងគ្រោះ ទោះបីខ្ញុំមិនបានធ្វើដោយផ្ទាល់ដៃខ្ញុំ គ្រាន់តែណែនាំគេក៏ដោយ ខ្ញុំទទួល ។ ហើយខ្ញុំគិតថា ការនេះវាសាហាវជាងខ្ញុំធ្វើដោយផ្ទាល់ដៃទៀត បើខ្ញុំធ្វើដោយផ្ទាល់ ដៃសូមជម្រាបដោយត្រង់ ខ្ញុំវ៉ៃបានមនុស្សម្នាក់ទេ តែបើសិនខ្ញុំណែនាំគេវិញ វាកាន់តែបានមនុស្សច្រើន សម្រាប់ឃោរឃៅទៅលើជនស្លូតត្រង់ ។ ដូច្នេះ ឧក្រិដ្ឋកម្មនេះខ្ញុំទទួល ។ នេះជាបញ្ហាមួយ ។ បញ្ហាមួយទៀត ដែលខ្ញុំសូមរាយការណ៍ជូនលោកឲ្យហើយអំពីទារុណកម្ម តាមវិធីឲ្យមុជទឹកនៅក្នុងរដូវរងា ហើយឡើងមកហាលខ្លួនឲ្យស្ងួត វិធានការនេះខ្ញុំធ្វើជាមួយស្រី ។ ធម្មតាមនុស្សស្រីខ្ញុំមិនដែលហ៊ានឲ្យនរណាសួរទេ គឺខ្ញុំសួរខ្លួនឯង ខ្ញុំខ្លាចរឿងប៉ះពាល់ដល់ការរំលោភលើផ្លូវភេទ ឬរំលោភលើរាងកាយ ។

[០៩:៥៣:១៩]

ដល់ថ្ងៃមួយខ្ញុំនឹកឃើញថា ហ៎ា បើសិនយើងមិនវ៉ៃ ហើយយើងប្រថុយយកទៅដាក់ នែ៎ឲ្យងូតទឹក ហើយងើប ឡើងឈរហាលខ្យល់ត្រជាក់ តើបានផលទេ? ខ្ញុំនាំគ្នាពីរនាក់មិត្ត ប៉ុន ទៅធ្វើ គឺឲ្យមនុស្សនោះមុជទឹកលិចក្បាល ហើយងើបឡើងមកឈរហាលខ្យល់ ។ មុជទឹកលិចក្បាល ហើយងើបឡើងមកឈរហាលខ្យល់ ។ ដល់ក្រោយមក ដកពិសោធន៍ខ្ញុំឃើញថា មិនបានការទេ ហើយគ្រោះថ្នាក់ផងស្រួលមិនស្រួល គេស្រី យើងយកទៅគ្នាពីរនាក់ហ្នឹងក៏ដោយ មានកើតចិត្តភ្លើតភ្លើនទប់មិនជាប់កំបុតករ ។

អ៊ីចឹងខ្ញុំឈប់ធ្វើ ដូច្នេះវិធីនេះខ្ញុំធ្វើចំពោះស្រី ។ ដូច្នេះកាលដែលខ្ញុំធ្វើទារុណកម្មដោយផ្ទាល់ដៃទៅលើជនរងគ្រោះផ្សេងទៀត ខ្ញុំសូមជម្រាបលោកចៅក្រមថា ខ្ញុំនឹកមិនឃើញទេ អាចមានលើសពីពីរនាក់ ហើយនឹងជ្រលក់ ឲ្យម្នាក់នោះងូតទឹកមែន នេះវិធីធ្វើទារុណកម្ម ដែលខ្ញុំបញ្ជា ហើយខ្ញុំដឹកនាំ ។

[០៩:៥៤:៤២]

**សៈ** កាលពីម្សិលមិញ នៅពេលលោកធ្វើការ ត្រូវបានសួរចម្លើយ លោកបាននិយាយថា នៅក្នុងមន្ទីរឃុំឃាំង នៅមន្ទីរឃុំឃាំងសម័យខ្មែរក្រហម សម័យឥស្សរៈ គឺការធ្វើទារុណកម្ម គឺមិនជៀសមិនរួចទេ តើលោកអាចបញ្ជាក់អំពីការជៀសមិនរួច អំពីការធ្វើទារុណកម្មនេះដែរឬទេ ?

**ឆៈ** ការពិតនេះបានទេ នៅក្នុងមន្ទីរនគរបាលសម័យឥស្សរៈក៏ដូចជានៅក្នុងមន្ទីរនគរបាល បើសម័យមុន១៧ មេសា ក៏ដូចជានៅមន្ទីរនគរបាលក្រោយ១៧ មេសា ជាទូទៅ គឺសុទ្ធតែមានទារុណកម្ម ជៀសអត់រួច ។ ជៀសអត់រួចទេ គ្រាន់តែខ្ញុំសូមបញ្ជាក់ ទារុណកម្មខ្ញុំធ្វើដោយផ្ទាល់ដៃ ឬទារុណកម្មដែលខ្ញុំប្រើឲ្យគេធ្វើដោយណែនាំល្អិត ថាមិត្តឯងត្រូវធ្វើអញ្ចេះ មិត្តឯងត្រូវធ្វើអញ្ចេះ ។ នេះពិត ។

**សៈ** ថាតើអំពើហឹង្សាបែបណាដែលបានប្រើប្រាស់ក្នុងពេលសួរចម្លើយ?

**ឆៈ** បើនិយាយអំពី អំពើកម្រោលដែលយើងធ្វើទៅជនរងគ្រោះនៅពេលសួរចម្លើយ នៅមន្ទីរ ១៣ មានពីរបែប ។ បីបែប ។ ទីមួយ គឺយើងសួរស្លូត បបួលនិយាយពីនេះ បបួលនិយាយពីនោះ ណែនាំបញ្ចុះបញ្ចូល មិនតាមទេ អាហ្នឹងក៏នៅក្នុងសម្តីដែរ ហៅថាក្នុងបែបទីមួយក៏ថាបានដែរ វានៅក្នុងការប្រើសម្តី ។

គឺកំហែង សម្លុត កំញើញ យកស្នឹដែលធំយកទៅកំញើញ ឧទាហរណ៍ដំបងមួយធំ ឬដាវមួយ ប៉ុន្តែគ្មានដាវទៀតផង តាមពិតនោះ ។ ឧបមាថា ញញួរមួយ ញញួរឈើមួយ យកទៅកំញើញ នេះអត់ទាន់វ៉ៃប៉ះខ្លួនប្រាណទេ ។ ដល់មិនកើតហើយទុកចោល លើកក្រោយមកយកមកនិយាយពីរបីម៉ាត់វ៉ៃ ឲ្យគេវ៉ៃ ។ ធម្មតាទេ ខ្ញុំអនុញ្ញាតត្រឹមវ៉ៃ អាចក្មេងៗរហូតដល់ទាត់ធាក់អីក៏ផងមិនដឹង នេះមានមែន នេះជារូបភាពមួយ ។ ឯចំណែកសេចក្តីណែនាំរបស់ វន វ៉េត ខ្ញុំមិនដែលបានធ្វើកើតទេ គាត់ប្រាប់ខ្ញុំថាស្បោងប្លាស្ទិក ។ យួនវាចងស្បោងប្លាស្ទិកគ្របពីលើអញ្ចេះ ។ ខ្ញុំធ្វើមិនកើតទេព្រោះដីរំដោះវាអត់មានស្បោងប្លាស្ទិកទេ ។ ដូច្នេះ ខ្ញុំសូមទោសឥឡូវនឹកឃើញរូបភាពមួយទៀតហើយ នៅពេលដែលសួរចម្លើយរកកាំភ្លើងនេះ ជនរងគ្រោះតែងតែទាក់ទងគ្នា និយាយប្រាប់គ្នាថា ឲ្យឆ្លើយអញ្ចេះ ឲ្យឆ្លើយអញ្ចុះ ។ ខ្ញុំគិតថា ហ៉េ!បើសិនជាអ៊ីចឹងធ្វើម៉េចទៅ បើវាចេះតែលួចប្រាប់គ្នាអ៊ីចឹងហ៉ាទៅឯណា? កាំភ្លើងនៅឯណា?

គិតចុះគិតឡើង មិនដឹងជាបានស្អី ក៏ទៅពិគ្រោះជាមួយ រាយការណ៍ជូន បង ស៊ី ឈ្មោះដើម ជូ ជេត អនុលេខាភូមិភាគនិរតីជំនាន់នុំង ដល់រាយការណ៍ជូនគាត់ គាត់គិតធ្មេចភ្នែកមួយសន្ទុះ គាត់បើកភ្នែកឡើងគាត់ថា ឌុច ឯងធ្វើអញ្ចេះ បោះបង្គោល ឲ្យវាឃ្លាតគ្នា ហើយឲ្យកងការពារយើងយាមចងវាភ្ជាប់ទៅនឹងបង្គោលនុំង ហើយកុំឲ្យវានិយាយគ្នា ។ អើធម្មតាទេ ហេតុតែយើងឃើញការចង់រកកាំភ្លើងជាធំ ដើម្បីផ្គាប់ផ្គន់ចិត្ត តាម៉ុក ។ មកដល់ក៏ចងជនរងគ្រោះទៅនឹងបង្គោលនុំង ដូច្នេះដោតបួនបង្គោល ឬក៏ប៉ុន្មានបួនបង្គោល ។ រើយដល់ដោតបួនប្រាំថ្ងៃទៅ វារលាត់នឹងអាខ្សែអង្រឹងដែលចងដៃហ្នឹង គ្នាឡើងខ្ទុះ ខ្ញុំឲ្យពេទ្យយកថ្នាំក្រហមទៅលាបឲ្យ ដោះមកយកថ្នាំក្រហមទៅលាបឲ្យអីៗ ។ នេះជារូបភាពមួយទៀតនៃការធ្វើទារុណកម្ម ដោយបំបែកគ្នា មិនចង់ឲ្យនិយាយគ្នា ព្រោះយើងវាខ្វះ *"សែឡឺ អាំង ឌុយវី ឌុយអែល"* ។

នេះជារូបភាពទារុណកម្ម ដែលខ្ញុំសូមលើកឡើងតាមការនឹកឃើញបណ្តើរៗជូនលោកចៅក្រមជ្រាប ។ អាចងបង្គោលនេះក៏ខ្ញុំណែនាំដែរ គំនិតរបស់ខ្ញុំដែរ ហើយខ្ញុំទាមទារឲ្យកងការពារគេអនុវត្តបទបញ្ជាខ្ញុំឲ្យបានដាច់ខាតដែរ ។

[១០:០០:២៨]

**ស៖** នៅពេលដែលលោកនិយាយថាចងនឹងបង្គោល ថាតើពួកគេចង ឬក៏ព្យួរពីបង្គោល?

**ឆ៖** ដើម្បីច្បាស់លាស់ ខ្ញុំសូមងើបឈរ ហើយធ្វើជូនលោកចៅក្រមមើល ។ នេះបង្គោល នេះជនរងគ្រោះគេចងអីចេះ គេចងអានេះមួយកង់ ហើយគេចងអានេះទៀតទៅក្រោយ ។ ឈរអីចឹង ។ នោះមួយទៀត នោះមួយទៀត ទាំងអស់៤ ។

**ស៖** ថាតើលោកនិយាយប្រាប់យើងថា ពួកគេត្រូវបានចង មិនមែនចងព្យួរទេ គឺថាគេចងដៃទៅខាងក្រោយ ទៅខាងខ្នងនឹងបង្គោល?

**ឆ៖** នោះមកដល់ ចងផ្អែកនៅអីចេះ ដៃទៅក្រោយ ។ ចងមួយកង់ត្រង់នេះ ចង់មួយកង់ទៀតត្រង់នេះ ចងពីរកង់ ។

**ស៖** ដូច្នេះ អ្នកទោសនៅចងនៅទីនោះ៤ថ្ងៃ ដោយមិនអនុញ្ញាតឲ្យនិយាយទៅកាន់អ្នកទោសជាប់គ្នា ថាតើពួកគេអាចផ្តល់អាហារដែរឬទេ?

**ឆ៖** ខ្ញុំភ្លេចទៅកាលហ្នឹង មិនដឹងជាខ្ញុំដាក់មកឲ្យគេហូបបាយសិន ឬក៏ឲ្យកងការពារបញ្ចុក? ខ្ញុំភ្លេច ។

**ស៖** ថាតើលោកមានឃើញអ្នកទោសត្រូវបានគេព្យួរដែរឬទេ? ព្យួរដោយដៃ កដៃ ជើង ឬក៏ព្យួរដើម្បីសួរចម្លើយ?

[១០:០៣:០០]

**ឆ៖** ខ្ញុំគ្មានចេញបញ្ជាឲ្យធ្វើអារបៀបហ្នឹងទេ ហើយក៏គ្មានស្ទីសម្រាប់ព្យួរយោងដែរ ។

**ស៖** ថាតើលោកបានឃើញអ្នកទោស ដែលអាចត្រូវបង់ចូលក្នុងបឹងដែរ ឬទេ?

**ឆ៖** សូមជម្រាបលោកចៅក្រម ការយកអ្នកទោសឲ្យទៅមុជទឹក ហើយមកឈរហាលខ្យល់ត្រជាក់ជាវិធីតែម្តងគត់ ដែលខ្ញុំធ្វើទៅលើស្រីម្នាក់ជាមួយមិត្ត ប៉ុន ហើយក្រោយមកខ្ញុំឈប់ឲ្យអ្នកណាធ្វើ ។ រូបភាព ឲ្យមុជទឹក មានតែម្តងគត់ ។

**ស៖** លោកមិនដែលឃើញ ពេលដែលក្បាលរបស់អ្នកទោសជ្រមុជចូលទឹក?

**ឆ៖** កាលណាយើងដាក់មនុស្សម្នាក់នៅក្នុងទឹក ហើយយកកម្លាំងទៅសង្កត់ពីលើ កម្លាំងស្ទីក៏ដោយ សង្កត់ពីលើ ហៅថាជ្រមុជ ។ វិធីធ្វើទារុណកម្មនៅមន្ទីរ១៣ គ្មានវិធីជ្រមុជទឹកទេ ។

**ស៖** ថាតើលោកឃើញអ្នកទោស ដែលត្រូវបានគេបង្ខំឲ្យស៊ី ឬក៏ផឹកទឹកដោយសាប៊ូផ្សេងៗដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកចៅក្រមថា សម័យនោះខ្ញុំបាទខ្លួនឯងហ្នឹង ក៏គ្មានសាប៊ូដុសខ្លួនផងដុសខោអាវផង ។

**ស៖** តើលោកឃើញអ្នកទោសៗ ត្រូវបានគេចាក់ចូលម្ជុលចូលក្នុងក្រចកដែរ ឬទេ?

**ឆ៖** រូបភាពនេះ គ្មានសោះ ។

[១០:០៥:៤៧]

**ស៖** ថាតើលោកឃើញអ្នកទោស ឃើញគេដកក្រចកដែរឬទេ?

**ឆ៖** ការធ្វើទារុណកម្មជំនាន់នោះ ខ្ញុំតាមដានជិតដល់ដែរ ។ គ្មានៗទេ គ្មានបញ្ជាខ្ញុំ ហើយក៏គ្មានម្ជុលឯណាសម្លាប់ ។ ហើយក៏គ្មានបញ្ជាណាពីខ្ញុំ ហើយក៏គ្មានដែលឃើញអ្នកណាគេរំលោភដោយដកក្រចកជនរងគ្រោះទេ ។

**ស៖** តើអ្នកទោសត្រូវបានៗគេដុតដោយភ្លើងដែរឬទេ?

**ឆ៖** រឿងនេះមានម្តងគត់ គឺខ្ញុំសូមអធិប្បាយរឿងនេះជូនដោយលម្អិត៖

យប់នោះគេចាប់មិត្ត ផល ។ ខ្ញុំឲ្យគេចាប់មិត្ត ផល តាមបញ្ជាពីលើ ក៏ប៉ុន្តែខ្ញុំចង់អប់រំមិត្ត មាស

ឲ្យរៀនសួរចម្លើយមិត្ត ផល ។ ខ្ញុំចង់បង្រៀនមិត្តមាស ឲ្យសួរចម្លើយ មិត្តផល ។ យប់នោះនៅជុំគ្នាបីបួននាក់ ខ្ញុំធំជាងគេខ្ញុំដេកអង្រឹង ។ ហើយមិត្តប៉ុន បន្ទាប់ពីខ្ញុំមក ក៏គាត់ដេកអង្រឹងដែរ ។ មិត្តមាស គាត់ក្មេងជាងគេបំផុត គាត់សួរចម្លើយ ។ ដូច្នេះ ចំពោះបញ្ហាចិត្តសាស្ត្រ មិត្តមាស គាត់ក្មេងជាងមិត្តផល ហើយគាត់ចូលសម្ព័ន្ធយុវកកក្រោយ មិត្តផល ហើយគាត់ទៅហៅមិត្តផល អ្អែងចុះ អ្អែងឡើង មិត្តផលខឹង ។

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** ខ្ញុំសូមរាយការណ៍ឡើងវិញ ។ ក្នុងចំណោមគ្នាខ្ញុំហ្នឹង មាន៤នាក់ ។ ខ្ញុំមួយ, មិត្តប៉ុន ទី២, មិត្តមាស ទី៣ ជាអ្នកសួរ ហើយមិត្តផល ទី៤ ជាអ្នកភ្ជាប់ចំណងឲ្យគេឆ្លើយ ។ សូមបញ្ជាក់ថា មិត្តមាស នេះ គឺជាមនុស្សដែលក្មេងជាងគេ ហើយក៏ចូលយុវកកក្រោយ មិត្តផល ទៅទៀត ។ ដល់គាត់អ្អែងចុះ អ្អែងឡើងជាមួយមិត្តផល មិត្តផល គាត់ខឹង ។ ដល់មិត្តផល គាត់ខឹង គាត់បួងដៃដាល់ មិត្តមាសពីក្រោម អ៊ីចឹង "ផាច់ៗអ្អែង នេះអ្អែង" ។ ដល់អ៊ីចឹងមិត្តប៉ុន គាត់ក្រោមភ្លែត អាចន្លុះកំពុងតែនៅហ្នឹង ។ គាត់ក្រោកភ្លែតឡើង ឆក់អាចន្លុះដែលកំពុងដុត រុញទៅលើមុខ មិត្តផល រុញឆាច់ៗ ពីរ-បីនេះទៅ ។

ដូច្នេះ ប្រឡាក់មុខ ប្រឡាក់មាត់ បកមកដោយទាំងសាច់ ទាំងអីហ្នឹង ទាំងអស់ហ្នឹង ។ ហើយដល់ខ្ញុំឮអ៊ីចឹង ខ្ញុំងើប ។ ដល់ខ្ញុំងើបឡើង មិត្តផលគាត់-- ដល់មិត្តផល គាត់ឃើញខ្ញុំងើប គាត់ខ្លាចដែរ គាត់ថា "បងអើយបង" ដល់អ៊ីចឹង ខ្ញុំធ្វើដៃអ៊ីចេះ ប៉ុន ក៏ឈប់ ហើយផល ក៏មិនប៊ាននេះទៀតក៏ចាប់ផ្ដើមនិយាយគ្នាធម្មតាទៅយប់ហ្នឹង ។

ដូច្នេះ រឿងនេះគឺជារឿងដែលខ្ញុំចាត់ចែងខុសដែរឲ្យមាស ទៅសួរផល មិនបានទេ ។ បើខ្ញុំសួរខ្លួនឯង គ្មានកើតឧប្បត្តិហេតុហ្នឹងទេ ។ ហើយបើសិនជាខ្ញុំ បើសិនជាខ្ញុំមិននៅហ្នឹងទេ ក៏ប្រហែលជាមិត្ត ប៉ុន គេមិនប្រញាប់ប្រញាល់ទាញចន្លុះយកទៅអុជផលដែរ ។ ព្រោះបើសិនជាខ្ញុំនៅហ្នឹង ផ្ទោះផ្ទោយយ៉ាងម៉េច ប៉ុន ក៏គេទទួលខុសត្រូវដែរៗ ។ ដូច្នេះ គេស្ទុះទៅរកចន្លុះប្រញាប់ហ្នឹង ក៏ព្រោះតែស្មារតីគេការពារខ្ញុំនៅហ្នឹង ។

សរុបមក ការដុតជនរងគ្រោះដែលទៅជាប់ទោសនៅទីនោះដោយចន្លុះ គឺមានពិត ហើយនៅហ្នឹងភ្នែកខ្ញុំ ។

**ស៖** ដូច្នេះ អ្នកទោសដែលត្រូវបានគេសួរចម្លើយ ហៅ ផល? ថាតើអ្នកទោសនេះ ជាបុគ្គលិក

របស់ ម-១៣ ដែរឬទេ កាលពីមុន?

**ឆ៖** វាពិតណាស់ហើយលោកចៅក្រម ខ្ញុំសូមនិយាយរឿងមិត្តផលនេះ ជូនបន្តិច ។ មិត្តផលនេះ ឈ្មោះពេញលេញរបស់គាត់ ម៉ែន សុផល ជាក្មេងដែលចុះទៅពីភ្នំពេញជាមួយខ្ញុំ ទៅតំបន់២៥ ។ ហើយក្រោយមក ក៏តាមមកជាប់ខ្ញុំនៅអមលាំងហ្នឹងទៀត ។ នៅពេលដែលខ្ញុំចាត់តាំងកកើតម-១៣ "ខ" ខ្ញុំ ឲ្យមិត្តផល នេះ ទៅធ្វើអនុប្រធានមិត្ត ស៊ុំ ហើយដល់នៅបានមួយរយៈ គាត់មានរឿងរ៉ាវស្រីញីៗ មេខ្ញុំផ្លាស់ឲ្យទៅនៅជាមួយអង្គភាពមួយផ្សេងទៀត ។ ដល់ផ្លាស់គាត់ឲ្យទៅនៅអង្គភាពមួយផ្សេងទៀត ប្រហែលជាក្នុងខែ១១ *ណុងៗ*!! មេខ្ញុំផ្លាស់ឲ្យគាត់ទៅនៅក្នុងអង្គភាពមួយផ្សេងទៀត មិនដឹងជាខែណាទេ ។ ក៏ប៉ុន្តែខែ១១ ខ្ញុំឃើញមិត្តផលទៅដល់ផ្ទះខ្ញុំ នៅអមលាំង កាន់កាំភ្លើងអាកាបត់មួយដើមថ្មីថ្ងៃសទៅដល់ ។ ដល់យកកាំភ្លើងអាកាថ្មីដថែសយកទៅហុចខ្ញុំដែពីរទៀត ថ្ងៃនុំង ។ ដល់ពេលខ្ញុំទៅធ្វើការៗខ្ញុំរាយការណ៍ជូនលោកគ្រូ សុន សេន ។ ខ្ញុំយកទាំងកាំភ្លើងទៅជូនគាត់ ។ ដល់លើកនេះមេខ្ញុំអត់ទាន់មានយោបល់ថា ម៉េចទេ ។ ដល់ខ្ញុំទៅធ្វើការលើកក្រោយជាមួយនឹងគាត់ទៀតៗ គាត់ប្រាប់ថា ចាប់ហើយវ៉ៃសួរចម្លើយទៅ ហើយកម្ទេចទៅ ។

ដូច្នេះមិត្តផលនេះ សរុបឡើងវិញជាពិត ជាកម្មាភិបាលរបស់ ម-១៣ មិនមែនជាបក្ខជនទេ តែជាសម្ព័ន្ធយុវកក ។

[១០:១៦:២៩]

**ស៖** ថាតើមានបញ្ហាឲ្យធ្វើការសួរចម្លើយកម្មាភិបាលដែរឬទេ? ដោយសារតែគាត់មានបញ្ហាសីលធម៌ ហើយគាត់មានបញ្ហាហ្នឹង?

**ឆ៖** បទបញ្ហាដែលខ្ញុំបានទទួលមកពីរឿងមិត្ត ផល នេះ ។ ទី១ គេផ្តុំទេ រឿងសីលធម៌ ឯរឿងពិតមែនទែន គឺគាត់ទៅនៅក្នុងអង្គភាពថ្មីគាត់បង្កហេតុនៅនុំង ។ គាត់បង្កហេតុនៅក្នុងអង្គភាពថ្មីហ្នឹងនៅក្នុងអង្គភាពចាស់ជាមួយនឹងកម្មាភិបាលចាស់ ចេះយោគចេះយល់គាត់ ។ ហើយដល់នៅអង្គភាពថ្មីគាត់បង្ករឿងនឹងគេ គេមិនអត់ឱនឲ្យគាត់ទេ គេរាយការណ៍លើហើយ ។ ដូច្នេះ គាត់គ្រោះថ្នាក់ដោយ-សារអារឿងដែលមានបញ្ហានៅក្នុងអង្គភាពថ្មីនុំង ។

[១០:១៧:២៨]

**ស៖** ក្នុងការយល់ឃើញរបស់លោក នៅពេលដែលហិង្សាត្រូវបានប្រើប្រាស់ ថាតើវាជាគោលបំណងក្នុងការទាញយកចម្លើយសារភាព ដើម្បីទាញរកការពិតដែរឬទេ? ឬគ្រាន់តែជាការទាញយក

ចម្លើយសារភាពដែលលោកទាមទារឲ្យមានការធ្វើដូច្នោះ?

**ឆ៖** បញ្ហានេះលោកចៅក្រមសួរមានលក្ខណៈជ្រាលជ្រៅណាស់ក្នុងនយោបាយ ខ្ញុំសូមសាកល្បងឆ្លើយតាមការពិចារណារបស់ខ្ញុំពេលនេះ ហើយនិងតាមការយល់ដឹងរបស់ខ្ញុំនៅពេលនេះ ។ ផ្ទាល់ខ្លួនខ្ញុំ មុននឹងធ្វើទារុណកម្ម ឬមុននឹងបញ្ជាឲ្យគេធ្វើទារុណកម្ម ខ្ញុំណែនាំឲ្យគេសួរឲ្យគេដេញដោល ឲ្យគេផ្ទាល់សព្វគ្រប់ ។ ធ្វើម៉េចឲ្យបានចម្លើយមួយដែលអាចស្របនឹងការពិតបានមួយកម្រិតណា ។ ក៏ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ ខ្ញុំមិនដែលជឿថា ចម្លើយដែលខ្ញុំទទួលបានស្របនឹងការពិតទេ ។ យ៉ាងច្រើនណាស់បាន ៤០% ។ ខ្ញុំនិយាយ ៤០%នេះ មិនមែននិយាយក្នុងភាសាជាអ្នកនយោបាយទេ លោកចៅក្រម ។ ក្នុងឋានៈជាអ្នកនយោបាយដូចយ៉ាង សុន សេន អីតែគាត់និយាយថា ៥០% ចប់ហើយគឺពេលលេញ ១០០%ហើយ ក៏ប៉ុនខ្ញុំនិយាយ ៤០%នេះ ។ ៤០%ក្នុងឋានៈជាអ្នកគណិតវិទ្យា ។

[១០:១៩:៣១]

ដូច្នេះ ចម្លើយដែលខ្ញុំទទួលបានអំពីបែបណាក៏ដោយ យ៉ាងច្រើនបានពិតត្រឹម ៤០% ។ នេះអំពីសភាពការណ៍ ដែលគេរាយការណ៍ឲ្យយើង ។ ប៉ុនមនុស្សដែលគេឆ្លើយដាក់យ៉ាងច្រើនពិតត្រឹម ២០% ខ្ញុំឃើញប៉ុនន្នុង ។ គ្រប់ពេលវេលា ខ្ញុំភ័យណាស់ ភ័យតែអារឿងប៉ះពាល់លើមនុស្ស ។ នេះជាការយល់ដឹងរបស់ខ្ញុំ ការធ្វើរបស់ខ្ញុំ ស្របទៅនឹងការជាក់ស្តែងដែលខ្ញុំផ្ទឹមប្រៀប ក៏ប៉ុន្តែវាគ្មានស្អីជាការផ្ទឹមប្រៀបដើម្បីយល់ប៉ុន្មានភាគរយច្បាស់ទេ ។ នេះជារឿងក្នុងការប្រតិបត្តិ ។ ក៏ប៉ុន្តែបើនិយាយអំពីឧក្រិដ្ឋកម្មវិញដែលបានមកអំពីចម្លើយមានទារុណកម្ម គ្មានការតាមដានពិនិត្យបែបវិទ្យាសាស្ត្រប៉ូលិសទេ គិត គឺពិតជាឧក្រិដ្ឋកម្មដែលខ្ញុំទទួលៗធ្វើការងារក្នុងយន្តការនេះ ដោយខានមិនបានទេ ។ ក៏ប៉ុន្តែ រឿងជាក់ស្តែងដែលខ្ញុំនិយាយហើយនេះ វាគ្រាន់តែចូលបង្ហាញការពិតដែលខ្ញុំបានប្រតិបត្តិខំ វាប៉ុណ្ណឹង ។

ដូច្នេះ ឧក្រិដ្ឋកម្មវាមានបើប្រៀបធៀបទៅនឹងវិទ្យាសាស្ត្រប៉ូលិស ដែលគេត្រូវតែធ្វើមិនដឹងជាមានប៉ុន្មានទេ? វាមហាឧក្រិដ្ឋនឹងសូមជម្រាបលោកចៅក្រម ។

[១០:២១:២០]

**ស៖** ខ្ញុំនឹងសួរសំណួរលោកចំពោះការសម្លាប់ថា តើលោកអាចជម្រាបយើងយ៉ាងម៉េចអំពីការសម្លាប់? ឋានរណាជាអ្នកសម្រេច? ហើយនៅពេលណា? អ្នកណាជាអ្នកសម្រេចថាបុគ្គលណាជាអ្នកទទួលខុសត្រូវលើការសម្លាប់?

**ឆ៖** លោកចៅក្រមជាទីគោរព! នៅក្នុងរបបខ្មែរក្រហមអ្នកដែលមានសិទ្ធិសម្រេចឲ្យចាប់ តែ

កាលណាគេបញ្ជាឲ្យយើងចាប់ហើយ គេឲ្យយើងកម្ទេចហើយ ។ យូរឬឆាប់ត្រូវតែកម្ទេចឲ្យគេ សួរចម្លើយបានឆាប់ចប់ពេលណា ល្អពេលនោះ យកទៅកម្ទេចទៅ ។ រឿងនេះហើយ ដែលធ្វើឲ្យខ្ញុំតក់ស្លុត ។ ខ្ញុំគិតថា បើមេខ្ញុំវាក្បត់ គេចាប់ច្បាស់ជាខ្ញុំកំបុតក ។ ខ្ញុំបានអង្វរករថាមិនធ្វើទេនគរបាល ខ្ញុំខ្លាចកំបុតកដោយគ្រោះថ្នាក់បែបនេះ ។

បង គឹមហ៊ី គាត់អះអាងខ្ញុំថា មិនអីទេ អ្នកគេសម្រេចគឺសុទ្ធតែសមាជិកមជ្ឈិម ។ ពោលគឺ បងវន, តាម៉ុក, បងស៊ី ហៅ ជូ ជេត ឈ្មោះដើម ហើយនិង បងប៉ាល់ ឈ្មោះដើម ហួត ហេង សុទ្ធតែជាសមាជិកមជ្ឈិម ។ ដូច្នេះ មិត្តចាប់ទៅអ្នកទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ គឺគេ ។

[១០:២៣:០៥]

ឥឡូវខ្ញុំងាមករក ការងារជាក់ស្តែងដែលលោកចៅក្រមសួរខ្ញុំ ។ អ្នកបញ្ជាឲ្យចាប់ ហើយបញ្ជូនមកមន្ទីរ១៣ គឺគេជាអ្នកបញ្ជាឲ្យកម្ទេចហើយ ។ មិត្តឯងសួរឆាប់ចប់ មិត្តឯងត្រូវយកទៅកម្ទេចឲ្យគេ ។ អានេះជាគោលការណ៍ ក៏ប៉ុន្តែដើម្បីច្បាស់លាស់ ខ្ញុំក៏ចង់បានគាប់គួរជាមួយនឹងខាងលើដែរ ។ ពេលខ្លះសួរចប់ហើយ យកបង្ហាញចម្លើយទៅគេហើយថា អានេះល្មមប៉ុណ្ណឹងហើយបង ។ កម្ទេច ។ គេថាល្មមហើយក៏កម្ទេចឲ្យគេទៅ ។ អានេះវាជាពិធីសាស្ត្រ ឬក៏ពិធីការ ឬក៏ការខិនលំទោនរបស់ខ្ញុំចំពោះខាងលើ អាហ្នឹងវាម្យ៉ាងទៀត ។ នេះជាគោលការណ៍ដែលយកទៅកម្ទេច ។ ហើយតែកាលណាបានគោលការណ៍អ៊ីចឹងហើយ ខ្ញុំបញ្ជាហើយ ទៅខាងក្រោមឲ្យគេកម្ទេច ។ ពិសេសអ្នកដែលនៅខាងកម្ទេច គឺមិត្ត មាស ។ មិត្ត មាស ហ្នឹង គាត់ក្មេង កូនកសិករនៅភូមិស្នួល ឃុំអមលាំង ស្រុកថ្ពង នេះជាមនុស្សដែលខ្ញុំកសាងពិសេស ហើយដែលខាងនោះគេប្រគល់មកឲ្យមកការពារ និងការកម្ទេចនេះឯង ។

ហើយអ្នកដឹកនាំចលនាយកទៅកម្ទេច និងទទួលខុសត្រូវរឿងកម្ទេច គឺមិត្ត មាស ហើយក្រៅពីនោះគេប្រមូលយុវជនផ្សេងៗទៀត ដូចជា មិត្ត ទិត្យ, មិត្តណាន យកទៅជាមួយ ហើយមិត្តផ្សេងទៀតខ្ញុំភ្លេចឈ្មោះ អស់ហើយ ហើយក៏មិនបានជានឹកនាទាំងអស់មកជូននេះ ។ កងការពារខ្ញុំគេជាអ្នកកម្ទេចនេះអំពីចលនាកម្ទេច ។ នេះអំពីចលនាកកម្ទេច ។

ហើយយូរៗមិត្ត ប៊ុន គាត់ទៅចូលរួមម្តង មិនយូរ-- ញឹកដែរ ។ គាត់មករាយការណ៍ប្រាប់ខ្ញុំថា អ៊ីយ!មិត្ត មាស ស្តាស់ណាស់បង វ៉ៃសុទ្ធតែយោលជើង ។ ខ្ញុំថាខ្ញុំធ្វើមិនបានដូចទេ ប៉ុន្តែមិនប៊ានថាម៉េច ព្រោះយើងវាមិនប៊ានធ្វើដូចគេ ។

សរុបមក អារឿងកម្ទេចនេះ ខ្ញុំអត់បានទៅធ្វើគំរូគេទេក្នុងរឿងនេះ ខ្លាចដូចខ្ញុំបានជម្រាបជូន

លោកចៅក្រមរួចមកហើយ ។ ពេលដែលបង គឹមហ៊ គាត់ប្រគល់ភារកិច្ចជាប្រធានមន្ទីរនគរបាលឲ្យខ្ញុំប្រាប់ថា ខ្ញុំមិនប៊ានកម្មេចទេ ។ សម្លាប់មនុស្សមិនខ្ញុំមិនប៊ានទេ ។ គាត់ថាយើងមានចំណុចខ្សោយជាបញ្ញាជន ត្រូវរៀនសូត្រពីកសិករទៅ ប្រគល់ភារកិច្ចនេះឲ្យគេទៅ ។

[១០:២៥:៥៨]

ដូច្នេះ ភារកិច្ចខាងកម្ទេចនេះ គឺមិត្ត មាស ។ ទោះបីយ៉ាងនេះក៏ដោយ ក៏ពេលណាកម្ទេច ខ្ញុំបញ្ជាខ្ញុំសម្រេច ។ ឧក្រិដ្ឋកម្មក្នុងការកម្ទេចមនុស្សទោះបីគេសម្រេចពីខាងលើមកទុកជាគោលការណ៍ហើយក៏ដោយ ក៏ពេលជំទាស់ណាមួយខ្ញុំធ្វើ រាល់ពេល ។ ដូច្នេះ ឧក្រិដ្ឋកម្មនេះ គឺវានៅលើខ្ញុំដដែល ។

ដូច្នេះ ហើយបានជាពេលម្សិលមិញ ខ្ញុំនិយាយថា វិញ្ញាណក្ខន្ធជនរងគ្រោះទាំងអស់ ដែលបាត់បង់ជីវិតនៅអមលាំង ខ្ញុំនៅតែសុំខមាទោស ។ ខ្ញុំនៅតែរំឭកឈ្មោះឡើងវិញ ដើម្បីសរសេរសៀវភៅមួយ ។ នេះពីបញ្ហាកម្ទេច ។ ខ្ញុំអត់គេចអំពីឧក្រិដ្ឋកម្មដែលត្រូវធ្លាក់មកលើក្បាលខ្ញុំទេ ខ្ញុំទទួល ប៉ុន្តែការពិតវាបែបនេះ ។

[១០:២៦:៥៨]

**ស៖** ដូច្នេះ អ្វីដែលលោកជម្រាបយើង គឺការកម្ទេចត្រូវបានធ្វើឡើង ដើម្បីទទួលបញ្ជាចេញដោយថ្នាក់លើជាពិសេសលោកបានលើកឡើងថា ទាំងអស់នោះ គឺជាសេចក្តីសម្រេច ដែលសម្រេចដោយគណៈមជ្ឈិម តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំបានរាយការណ៍ការជូនជាមូលដ្ឋានហើយ ឥឡូវនេះគ្រាន់តែសូមបញ្ជាក់ឲ្យវាកាន់តែច្បាស់ឡើង ។ អំណាចសម្រេចឲ្យចាប់គេហៅថា “អំណាចកម្ទេច” ។ អ្នកដែលមានអំណាចនេះ ជំនាន់នោះ គឺនៅលើសមាជិកមជ្ឈិមបក្សជាទូទៅ សមាជិកមជ្ឈិមពេញសិទ្ធិរបស់បក្សជាទូទៅ ។ ក៏ប៉ុន្តែមនុស្សដែលសួរចម្លើយរួចហើយជាគោលការណ៍ ខ្ញុំចាត់ចែងកម្ទេចបាន ដោយគ្មានទាស់ ។ ក៏ប៉ុន្តែពេលខ្លះៗ ជាទូទៅដែរ កាលណាសួរចម្លើយចប់បានពីរ-បីនាក់ ខ្ញុំប្រញាប់រត់ទៅរាយការណ៍ឲ្យគេ ហើយសួរគេថាល្មមកម្ទេចបានហើយនៅ? ចម្លើយប៉ុណ្ណេះពេញចិត្តទេ? ដូច្នេះដែលផ្គាប់ចិត្តគេ អារឿងឯណេះទៅវិញទេ ។ អារឿងក្នុងការអនុវត្តជាក់ស្តែងពេលវេលាត្រូវចេញយកទៅកម្ទេច ។

**ស៖** លោកបានលើកឡើងអំពីក្រុមជំនាញ ដែលជាក្រុមជំនាញខាងកម្ទេច ។ តើលោកអាចជម្រាបយើងបានដែរឬទេ? ថាតើសមាជិកនោះ ក្រុមនោះមានអាយុប៉ុន្មាន?

[១០:២៩:០៥]

**ឆ៖** លោកចៅក្រមជាទីគោរព ។ មិត្តមាស ខ្ញុំប្រើគាត់តែក្នុងច្រកនេះ តាំងពីអាយុ១៦ឆ្នាំម្ល៉េះ ។ តាំងពី ១៦ម្ល៉េះ ១៦, ១៧ ,១៨ យ៉ាងច្រើន ។ មិនដល់ទេ មិនដែលដល់១៨ទេ ។ មិត្តមាស ១៨ ចូលបក្សបាត់ទៅហើយ ។ ក៏ប៉ុន្តែ នៅអនុវត្តភារកិច្ចនេះ ។ ដូច្នេះ អាយុក្រោម ១៨ ។

**ស៖** ថាតើមានកុមារណាដែលជាអ្នកទទួលខុសត្រូវក្នុងការកម្ទេចដែរ ឬទេ?

**ឆ៖** កាលនោះបើសិនជាយើងគិតថា អាយុ១២ឆ្នាំ ជាក្មេងជំទង់ ។ មានក្មេងជំទង់ពីរនាក់ដែលខ្ញុំយកមកធ្វើនីរសារ ពួកនេះអត់ទៅកម្ទេចទេ ។ ក្រៅពីនោះ លើសពី១២ឆ្នាំ ឯចំណែកមានកូនក្មេងតូចៗពីរនាក់ដែរ ទី១ គឺកូនបងមុំ ឯចំណែក-- មានក្មេងតូចៗពីរនាក់ដែរ ទី១ គឺកូនមិត្តយើងកម្មាភិបាលនៅនុ៎ង ហើយទី២ គឺប្អូនរបស់នីរសាររបស់ខ្ញុំហ្នឹង គឺក្មេងតូចៗ អត់ប្រើអីទេអានុ៎ងគិតរត់លេង តែអត់មានពេលកម្មវិធីឲ្យវាបានរៀនទេ ។

សរុបមក ក្មេងមានពីរនាក់ យើងខ្ញុំអត់ប្រើកម្ទេចទេ ក្មេងជំទង់អាយុ១២ឆ្នាំ យើងខ្ញុំមានពីរនាក់ យើងខ្ញុំយកមកធ្វើនីរសារផ្ទាល់ខ្លួន ។

**ស៖** ខ្ញុំសួរសំណួរឥឡូវនេះ តើមានកុមារជាអ្នកទទួលបន្ទុកក្នុងការកម្ទេចមនុស្សដែរឬទេ? ម្យ៉ាងទៀតថា តើកុមារត្រូវបាន-- ដើម្បីឲ្យកុមារនោះសម្លាប់អ្នកទោសដែរឬទេ?

**ឆ៖** ចំពោះក្មេងពីរនាក់តូចៗ ដែលជាកូនមិត្តយើងម្នាក់ ហើយនិងកូនអ្នកស្រុកម្នាក់នោះ គេអត់មានទៅឃើញកន្លែងកម្ទេចទេ ។ ឯចំណែកនីរសារខ្ញុំ ខ្ញុំមិនច្បាស់ទេ ខ្ញុំភ្លេចបាត់អស់ដែរហើយ ។ មិនដឹងជាគេទៅ ឬក៏អត់? តែឲ្យខ្ញុំបញ្ជូនទៅគឺអត់ទេ នីរសារខ្ញុំពីរនាក់នុ៎ង មួយឈ្មោះ សើ មួយឈ្មោះ ឆេន អត់ទេ ។ ដូច្នេះ អាចគេទៅក្រៅចាត់តាំងក៏សឹងតែថាបាន ក៏ប៉ុន្តែថាឲ្យខ្ញុំចាត់តាំងទៅដើម្បីរៀនសូត្រអត់ទេ ។

[១០:៣២:៣៤]

**ស៖** ថាតើគេអនុវត្តការកម្ទេចនោះ ដូចម្តេច? តើគេប្រើវិធីដូចម្តេចដែលគេប្រើសម្រាប់សម្លាប់ដើម្បីកម្ទេចអ្នកទោសនោះ?

**ឆ៖** នៅមន្ទីរ ១៣ ហើយក៏ប្រហែលដូចមន្ទីរនគរបាលផ្សេងដែរយ៉ាង។ ប្រើតែដំបងហើយវៃត្រង់ណេះ ក្រៅពីនោះគ្មានវិធីអីទៀតទេ ។

**ស៖** តើគាត់បាន-- លោកធ្វើបាន-- បានធ្វើការសម្លាប់ដោយខ្លួនឯងដែរឬទេ? ឬក៏លោកបានឃើញការកម្ទេច ឬក៏លោកបានពន្យល់ថា តើត្រូវកម្ទេចរបៀបណាដែរឬទេ?

**ឆ៖** និយាយអំពីការណែនាំ មានជាប់ ហើយក៏រំឭកជាប់ ។ រំឭកយ៉ាងម៉េច? ធ្វើម៉េចកុំឲ្យថ្កោះថ្កោយមនុស្សរត់រួចមុននឹងយើងកម្ទេច ហើយកុំឲ្យធ្វើម៉េចគេស្រែកបែកការណ៍ ។ នេះគឺជាការងារខ្ញុំដែលខ្ញុំធ្វើជាប់ជាប្រចាំ ។ ត្រង់ចំណែកថា វ៉ៃត្រង់ណាអីត្រង់ណា អាហ្នឹងក៏ខ្ញុំមានប្រាប់គេដែរ ដោយឈរលើពិសោធន៍ដែលមានតាមរយៈមិត្តមាស ហើយនិង មិត្តប៉ុន ហើយនិងតាមរយៈអ្នកផ្សេងទៀតគេប្រាប់អំពីរឿងមន្ទីរនគរបាលផ្សេងទៀត ។ ឧទាហរណ៍ ដូចបង ឆាយ គឹមហ៊ កេប្រាប់ថា នែ៎គេធ្វើអីចេះៗ ខ្ញុំក៏យកមកណែនាំទៅ ។ ក្នុងគោលការណ៍ដែលខ្ញុំប្រយ័ត្នតែមួយទេ ហើយ ឆាយ គឹមហ៊ គាត់អ្នកណែនាំឲ្យខ្ញុំប្រយ័ត្នដែរ ប្រយ័ត្នមិនស្លាប់ ។

ដូច្នេះ ត្រូវមើលឲ្យប្រាកដប្រជាថា ត្រូវស្លាប់ ។ ហើយប្រយ័ត្នទី២ កប់ឲ្យជ្រៅ ប្រយ័ត្នខ្លាទៅអូស នេះរឿងណែនាំ គឺវាសព្វជ្រុងសព្វជ្រោយអ៊ីចឹងក្នុងឋានៈខ្ញុំជាមេដឹកនាំ ពិតជាបានណែនាំសព្វជ្រុងសព្វជ្រោយ ។ ពិតជាបានតាមដាន ។ ក៏ប៉ុន្តែឲ្យខ្ញុំទៅមើល មិត្តប៉ុន គឺជាមនុស្សដែលខ្ញុំទុកចិត្ត ហើយខ្ញុំឲ្យទៅមើល ។ ឲ្យខ្ញុំទៅផ្ទាល់ខ្លួនខ្ញុំអត់ទៅទេ ព្រោះក្នុងអារម្មណ៍ខ្ញុំ ដូចខ្ញុំបានរាយការណ៍ជូនលោកចៅក្រមម្សិលមិញហើយ រឿងអ្នកបាញ់សម្លាប់ ព្រាប អិន គ្នាអ្នកបាញ់នោះទៅមានទោសអី អ្នកដែលសម្រេចពីលើ គឺសម្តេចព្រះសីហនុ ដែលខ្ញុំគិតថាហ្នឹង ។

ដូច្នេះ ខ្ញុំពិតជាមានឧក្រិដ្ឋកម្មទៅលើជីវិតគេ ។ ក៏ប៉ុន្តែ ឲ្យខ្ញុំធ្វើផ្ទាល់ដៃដូចពេជ្ឈឃាដដែរ ខ្ញុំមិនធ្វើទេ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសឈប់សម្រាក១៥នាទី រហូតដល់ម៉ោង១១ ខ្វះ១០នាទី សូមអញ្ជើញចូលវិញ ។

*[សវនាការសម្រាកនៅម៉ោង ១០:៣៦នាទី រហូតដល់ម៉ោង ១០:៥៥នាទី]*

[១០:៥៥:៤៩]

**លោកស្រី សែ កុលវុឌ្ឍី៖**

អញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត។ ហើយមុននឹងជូនវេទិកាហ្នឹងទៅលោក ចៅក្រម ហ្សង់ម៉ាក ។

ខ្ញុំសូមជម្រាប ប្រាប់ទៅជនជាប់ចោទថា សុំជនជាប់ចោទនៅពេលដែលលោកស្តាប់នូវសំណួរ សួរជាភាសាបារាំងនោះរួចហើយ លោកបង្អង់បន្តិចដើម្បីទុកលទ្ធភាពឲ្យដល់អ្នកបកប្រែ បកប្រែភាសា នូវសំណួរនុ៎ងរួចរាល់សិន សឹមលោកឆ្លើយ ។

ដូច្នេះ កន្លងមកនេះ គឺនៅពេលដែលលោកស្តាប់យល់ហើយលោកឆ្លើយភ្លាម ការបកប្រែជាភាសាខ្មែរ ហើយនិងទៅជាភាសាអង់គ្លេសហ្នឹង គឺមានបញ្ហា ។ អ៊ីចឹង គឺគ្រាន់តែបង្អង់បន្តិច ដើម្បីទុកពេលវេលាសមល្មម សម្រាប់អ្នកបកប្រែធ្វើការបកប្រែនូវសំណួរ ។

ហើយបញ្ហាទីពីរ គឺនៅពេលដែលលោកឆ្លើយចប់ សឹមលោកចុចផ្តាច់នូវមេក្រូហ្វូន ដើម្បីកុំឲ្យវាមានការកុងគ្នានៅក្នុងការសួរនាំនេះ ។ លោកយល់ទេ ?

សូមអញ្ជើញ លោក ហ្សង់ម៉ាក បន្តសួរតទៅទៀត ។

**ជនជាប់ចោទ៖**

លោកចៅក្រម, ខ្ញុំសុំអនុញ្ញាតបញ្ជាក់ឃ្លាចុងរបស់ខ្ញុំ ។

ជម្រាបបញ្ជាក់ឃ្លារបស់ខ្ញុំ ដែលខ្ញុំនិយាយមានន័យមិនច្បាស់លាស់ ខ្ញុំសូមបញ្ជាក់ជូនលោកចៅក្រម ។

ឃ្លាចុងក្រោយរបស់ខ្ញុំនេះ ខ្ញុំនិយាយលឿនពេក អារម្មណ៍ខ្ញុំវាគិតទៅលឿនពេក ធ្វើឲ្យមានការច្របូកច្របល់ ច្របូកច្របល់ដែលចេញពីន័យនៃន័យពាក្យរបស់ខ្លួនឯង ។ ខ្ញុំនិយាយអំពី ព្រាប អិន ។ ខ្ញុំនិយាយអំពីសម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ ហើយខ្ញុំនិយាយជាប់ភ្លាមវិងមកដល់ខ្លួនខ្ញុំ ។

បញ្ហានេះ ខ្ញុំសូមបញ្ជាក់ដូចតទៅ: រឿងសម្តេចព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ កាលនោះតុលាការកម្ពុជាកាត់ទោសជនរងគ្រោះ ជនជាប់ចោទក្នុងព្រះបរមនាមនៃព្រះមហាក្សត្រ ហើយជនជាប់ចោទម្នាក់ៗដែលតុលាការសម្រេចកាត់ទោសប្រហារជីវិត អាចមានសិទ្ធិសុំអនុគ្រោះពីព្រះមហាក្សត្រ ឬពីព្រះប្រមុខរដ្ឋ ។ ដូច្នេះ តួនាទីព្រះអង្គធំប៉ុនគ្នានឹងគណៈមជ្ឈិមបក្សជំនាន់ខ្មែរក្រហម ។ ដោយឡែករូបខ្ញុំជាអ្នកអនុវត្តបញ្ជា ក៏ប៉ុន្តែខ្ញុំនឹកដល់ឧក្រិដ្ឋកម្មរបស់ខ្ញុំ ខ្ញុំនិយាយវិងទៅវាហួស ។

ដូច្នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ខ្ញុំមិនទៅប្រៀបធៀបខ្លួនខ្ញុំទៅនឹងសម្តេចព្រះប្រមុខរដ្ឋទេ ។

**សួរដោយចៅក្រម ហ្សង់ ម៉ាកឡាវែន៖**

**ស៖** ការកម្ទេចទាំងនោះ តើធ្វើឡើងជាសម្ងាត់? ឬក៏ធ្វើឡើងនៅកន្លែងណាមួយជាក់លាក់? ឬក៏អ្នកដែលអ្នកទទួលបន្ទុកក្នុងការកម្ទេចនោះ ដែលទទួលការណែនាំមិនឲ្យនិយាយពីការសម្លាប់ ការកម្ទេច

នុំងដែរឬទេ?

**ឆ៖** លោកចៅក្រមជាទីគោរព! អង្គភាព ឬក៏បុគ្គលដែលទទួលភារកិច្ចកម្ទេចជនរងគ្រោះដែលទៅជាប់ទោសនៅ ម-១៣ ត្រូវរក្សាសម្ងាត់ ។ កម្ទេចបែបម៉េច? កម្ទេចនៅទីណា? កន្លែងកម្ទេចហ្នឹងក៏មិនឲ្យអ្នកណាដឹង ក្រៅអំពីអង្គភាពរបស់ខ្លួនដែលគេដើរទៅឃើញ ។ ដូច្នេះ ត្រូវនៅស្ថិតជាសម្ងាត់ ។ ដោយសាររក្សាសម្ងាត់ ដូច្នេះហើយបានជាកន្លែងកប់សាកសពដែលយើងខ្ញុំកម្ទេច មិនឆ្ងាយប៉ុន្មានពីកន្លែងហ្នឹងពេកទេ ប្រហែលជា១០០ម៉ែត្រអីប៉ុណ្ណឹង ។ នេះជារឿងសម្ងាត់ ដែលត្រូវរក្សាពាក់ព័ន្ធនឹងការកម្ទេច ។

**ស៖** តើការកម្ទេចនោះ គឺមានចំនួនច្រើន ឬក៏ជនរងគ្រោះត្រូវបានគេកម្ទេចរៀងរាល់ថ្ងៃ? តើលោកអាចបញ្ជាក់ពីពត៌ព័ត៌មានអ្វីថែមទៀតបានទេ?

**ឆ៖** នៅមន្ទីរ១៣ ជនរងគ្រោះដែលទៅជាប់ទោស ហើយត្រូវកម្ទេចនៅទីនោះ បើតាមខ្ញុំសរុបត្រួសៗដើម្បីសរសេរអត្ថបទរបស់ខ្ញុំនោះ មិនលើសពី៣០០នាក់ទេ ហើយក៏មិនតិចជាង២០០នាក់ដែរ ។ គ្រាន់តែនៅមូលដ្ឋានចាស់គឺឃុំអមលាំង ខ្ញុំរាប់ត្រួសៗ ដែលខ្ញុំរំឭកឈ្មោះឡើងវិញឃើញ២៥នាក់ទៅ៣០នាក់ ។

ដូច្នេះ ខ្ញុំគិតថា ពួកនៅមូលដ្ឋានចាស់នេះប្រហែលជា៦០នាក់ចុះ ។ ដូច្នេះ រាប់ទាំងពួកដែលមានទំនាស់ផ្ទៃក្នុងជួរផង រាប់ទាំងអ្នកពួកមកពីក្រៅ ដែលគេចោទថាគិញអីផង មិនលើសពី៣០០នាក់ទេ ។

[១១:០២:៣៦]

**ស៖** អ៊ីចឹង ហើយអ្នកទាំងអស់ហ្នឹង គឺជា “គិញ” ជា “ខ្មាំង” ឬជាអតីតកម្មាភិបាលរបស់បក្សកម្ពុជាៗ តើគេជាការបោសសម្អាតទេនៅពេលហ្នឹង?

**ឆ៖** និយាយអំពី ពួកដែលគេចោទថា “គិញ” មាន ជាពិសេសរយៈដំបូង ។ អ្នកដែលចូលពីដីលន់ នល់ មកដីរំដោះ ។ ក៏ប៉ុន្តែ ក្នុងមូលដ្ឋានបង្អែកខ្លួនឯង គឺឃុំអមលាំងនោះ គេចោទថា “ខ្មាំងវណ្ណៈ” ធ្វើសកម្មភាពប៉ះបោរ ជាអ្នកប្រឆាំងបដិវត្តន៍ ។ ឯចំណែកកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំនៅចាំពីរនាក់ច្បាស់ ។ ទីមួយ ឈ្មោះ សង្ហា ហឿន ជាមនុស្សជំនិតរបស់ តាម៉ុក ។ ខ្ញុំបានជម្រាបលោកចៅក្រមម្សិលមិញហើយ គាត់ជាអ្នកអាយ៉ៃ ដៃគូគ្នាជាមួយនឹង សំ ប៊ិត ។ ហើយទីពីរ គឺកម្មាភិបាលមកពីហាណូយម្នាក់ ឈ្មោះ ប្រាជ្ញ សុន ហៅ ពត ដែលគាត់ចាប់បង្ខំឲ្យខ្ញុំវ៉ៃស្នូរចម្លើយនោះ ហើយខ្ញុំមិនធ្វើតាម ។ ឯចំណែកក្រៅពីនោះ មានកម្មាភិបាលហាណូយពីរបីនាក់ទៅដែរ ជាចុងក្រោយដែលគេ

ជម្រុះ ។

ដូច្នេះ កម្មាភិបាលក្នុងបក្សកុម្មុយនីស្តកម្ពុជា និយាយម៉ាចប់ទៅមាន ក៏ប៉ុន្តែថ្នាក់ធំ ខ្ញុំនៅចាំពីរនាក់នុ៎ង មិនមានធំលើសពីនុ៎ងទេ ។ ហើយកម្មាភិបាលហាណូយ បើតាមខ្ញុំចាំគឺ៤នាក់ ។ ដូច្នេះ មិនច្រើនលើសពី៦-៧នាក់អីទេ ខ្ញុំវាយតម្លៃប៉ុណ្ណឹង ។ ឯចំណែកអ្នកដែលមាន-- នៅឯភូមិជិតខ្មាំង ដូចភូមិពោធិ៍ ដែលលោកគ្រូ សុន សេន ខ្ញុំ គាត់ហៅថាភូមិសន្តិសម្ព័ន្ធនោះ គាត់បារទៅទាំងអស់ ។ គាត់ជ្រើសរើសទុកឲ្យមន្ទីរ១៣ សួរចម្លើយប៉ុន្មាន៥-៦ នាក់ ក៏ប៉ុន្តែក្រៅពីនោះ គាត់ឲ្យបញ្ជូនទៅបាត់ដំបង ។ នេះខ្ញុំចាំត្រួសៗបានប៉ុណ្ណឹង ។

សរុបមកឧក្រិដ្ឋកម្មវាមានទៅលើមនុស្សដែលចោទគេថា "គិញ" វាមានទៅលើមនុស្សដែលនៅក្នុងមូលដ្ឋានបង្អែក ដែលគេចោទថា ជាអ្នកត្រៀមបះបោរពីខាងក្នុង ហើយសុទ្ធតែជាវណ្ណៈសក្តិភូមិនាយទុន វាមានអ្នកដែលគេចោទថាក្បត់បដិវត្តន៍ កម្មាភិបាលដែលក្បត់បដិវត្តន៍ ហើយវាមានអ្នកដែលគេថាទទួលឥទ្ធិពលពីខ្មាំងទៅជាភូមិសន្តិសម្ព័ន្ធ ដូចយ៉ាងភូមិពោធិ៍ មិនដឹងឃុំអីទេ ប៉ុន្តែ នៅតំបន់១៥ ជិតទៅដីខ្មាំងនោះ ។

**ស៖** តើពួកវៀតណាមមានជាអ្នកទោសទេ នៅក្នុង ម-១៣ នោះ?

[១១:០៦:១៦]

**ឆ៖** គ្មានជនជាតិវៀតណាមណាម្នាក់ទៅដល់មន្ទីរ១៣ទេ ឬមួយក៏ខ្ញុំភ្លេច ប៉ុនដូចជាមិនភ្លេចទេ ប៉ុនតាមខ្ញុំចាំ គឺគ្មាន ។

**ស៖** តើហេតុការណ៍នោះ បានកើតឡើងនៅពេលដែលមានចំនួនជនស៊ីវិលច្រើនខ្ពស់ជាងគេនៅក្នុងម-១៣ ដោយហេតុថា មានសង្គ្រាមនូវការធ្លាក់ដួលរលំនៃឧដុង្គ តើមានអ្នកទោសជាស៊ីវិលហ្នឹងមានចំនួនកើនច្រើនបំផុតទេ ពេលនោះ?

**ឆ៖** ភាគឧដុង្គ ខ្ញុំមិននឹកឃើញទេ ដល់លោកចៅក្រមសួរមក ខ្ញុំសូមបញ្ជាក់ជូន ។

បញ្ហាឈ្នះឧដុង្គលើកទីមួយនេះ មេខ្ញុំបញ្ជូនទៅម-១៣ ច្រើនដែរ បណ្តោះអាសន្នម៉ាយប់ ឬពីរយប់ទេ គាត់ចាត់ចែងឲ្យគេដឹកទៅខាងបាត់ដំបងពាយ័ព្យ ហើយទុកមួយចំនួនប្រហែលជា ៥-៦ នាក់ឲ្យខ្ញុំសួរចម្លើយ មែនពេលនុ៎ង ទៅប្រហែលជា២០-៣០នាក់ ។

**ស៖** ដូច្នេះ ទាក់ទងទៅនឹងអំពីផល ដែលលោកបាននិយាយពីខាងដើម ថាតើគាត់ជាសមាជិក

ដែលត្រូវបានសម្លាប់ចោលនៅម-១៣ ទេ?

**ឆ៖** មិនមាន មិនមានទេ ក្រៅពីមិត្ត ផល មួយ មិនមានអ្នកណាបុគ្គលិករបស់មន្ទីរ១៣ ត្រូវបានកម្ទេចនៅមន្ទីរ១៣ ទេ ។ អ្នកណាដែលធ្វើការមិនស្រួល ជាពិសេស នៅខាងមន្ទីរ១៣“ក” តែម្តង ។ បុគ្គលិករបស់ខ្ញុំ ដែលខ្ញុំនៅជ្រើសពីឃុំមក ខ្ញុំឃើញការងារមិនហ្មត់ចត់ ខ្ញុំចេះតែរកលេសឲ្យគេត្រឡប់ទៅភូមិឃុំវិញ ។ ដូច្នេះ គ្មានកម្ទេចទេ ។

**ស៖** តើមានការដាក់ទោសទណ្ឌកម្មទៅលើបុគ្គលិក ហើយជាជាងការកម្ទេចដើម្បីជាការត្រួតទៅលើបុគ្គលិក ថាតើការទិតៀន ស្វ័យទិតៀននោះរៀបចំដូចម្តេច ? តើគេបញ្ជាក់ដូចម្តេចនៅក្នុងវគ្គទិតៀន ស្វ័យទិតៀនក្នុងប្រជុំនោះ?

**ឆ៖** ក្រៅអំពីការកម្ទេច ខ្ញុំបានជម្រាបលោកចៅក្រមមិញហើយ អ្នកណាដែលមានស្មារតីបំពេញការងារមិនហ្មត់ចត់ ខ្ញុំរកវិធីឲ្យគេត្រឡប់ទៅមូលដ្ឋានភូមិឃុំវិញ ។ នេះមួយ ។

ទីពីរ កាលដែលត្រួតពិនិត្យគ្នា ដោយកាលទិតៀននិងស្វ័យទិតៀន សម្រាប់ក្មេងៗមាន ។ ច្បាស់លាស់ទៀងទាត់ គឺម៉ាអាទិត្យម្តង ប្រធានក្រុម គេជាអ្នកធ្វើ សូម្បីតែយើងខ្ញុំដែលជាបក្ខជនហ្នឹងក៏ដោយក៏ទៅធ្វើជីវភាពទិតៀននិងស្វ័យទិតៀនរាល់កន្លះខែម្តងនៅមន្ទីរភូមិភាគដែរ ។ ជារបបធ្វើការរបស់បក្សកុម្មុយនីស្តកម្ពុជា ចសមិនរួចអំពីការធ្វើជីវភាពទិតៀននិងស្វ័យទិតៀននេះទេ ។

**ស៖** លោកបាននិយាយថា បុគ្គលិកហ្នឹងនឹងត្រួតពិនិត្យគ្នាទៅវិញទៅមក តើនោះមានន័យថាពួកគេទទួលការណែនាំដើម្បីបំពេញទឹកចិត្តថ្នាក់លើ ដើម្បីរាយការណ៍ពីម្នាក់ទៅម្នាក់ ដើម្បីជំរុញលើកទឹកចិត្តគេឲ្យនៅក្នុងបុគ្គលដើម្បីរាយការណ៍ទម្លាក់កំហុសពីម្នាក់ទៅម្នាក់មែនទេ? តើនេះជាបុគ្គលិកដែលមិនបានបំពេញការងារល្អ ឬក៏ធ្វើការទិតៀនគ្នានោះ?

[១១:១០:៥០]

**ឆ៖** ចំពោះបញ្ហាដាក់ទណ្ឌកម្មលើការល្មើសធ្ងន់ធ្ងរក្រៅពីការទិតៀនមាន ។ នៅម-១៣“ក” យើងខ្ញុំមិនឲ្យធ្លាក់ទៅដល់បញ្ហាហ្នឹងទាន់ទេ គឺបញ្ជូនឲ្យត្រឡប់ទៅភូមិ ឃុំវិញ ដោយប្រើពាក្យស្លូតបូតទន់ភ្លន់កុំឲ្យគេដឹងខ្លួន ។

ឯចំណែកនៅម-១៣ “ខ” មានបុគ្គលពីរនាក់ ទីមួយគឺ មិត្តផល នេះ ខ្ញុំឲ្យគាត់ទៅធ្វើជាអនុប្រធាន ម-១៣ “ខ” ហើយគាត់ទៅលេងខិលខូចជាមួយនឹងស្រីម្នាក់ជាមួយនឹងមិត្ត ភី ។ ម្ល៉ោះហើយមិត្តភី ក៏មិនឲ្យចូលយុវកក ហើយមិត្តផល ដែលចូលយុវកកហើយហ្នឹង ក៏លោកគ្រូ សុន សេន គាត់

ឲ្យចេញពីអង្គភាពហ្នឹងទៅនៅអង្គភាពមួយទៀត ។

នេះវាកើតមកអំពីមេក្តាប់បាន ហើយមេរាយការណ៍ គឺមិត្ត ស៊ុំ គាត់រាយការណ៍ទៅលើ ។ ឯចំណែកខ្ញុំៗរាយការណ៍ដែរ ក៏ប៉ុន្តែវិធានការណ៍របស់ខ្ញុំ ខ្ញុំមិនដកអ៊ីចឹងទេ គឺណែនាំឲ្យគេត្រឡប់ទៅភូមិឃុំវិញ ច្រើននាក់ដែលខ្ញុំឲ្យត្រឡប់ទៅភូមិឃុំវិញ ។ ព្រោះខ្ញុំជ្រើសរើសបុគ្គលិក ខ្ញុំដឹងហើយថា ខ្លួនខ្ញុំមានវណ្ណភាពជាសាស្ត្រាចារ្យ គេហៅថា "បញ្ញាជន" ដែលបារាំងគេហៅថា "*សឺមីអាំទេឡិចទុយអែល*" នោះ ។

ខ្ញុំភ័យណាស់នឹងវណ្ណភាពរបស់ខ្លួនដែលមិនអំណោយក្នុងការធ្វើបដិវត្តន៍ ។ ខ្ញុំជ្រើសរើសបុគ្គលិក គឺសំដៅរកកសិករក្រីក្រ ដើម្បីឲ្យគេយោងខ្ញុំ ខ្ញុំយោងគេ ។ ខ្ញុំយោងគេខាងទ្រឹស្តី ខាងការដឹកនាំ គេយោងខ្ញុំខាងវណ្ណភាព ទាំងអស់នាំគ្នាធ្វើល្អ ដើម្បីឲ្យបក្សជឿទុកចិត្ត ។ ដូច្នេះ កាលណាបុគ្គលិកដែលខ្ញុំរើសមកពេញចិត្ត ខ្ញុំឲ្យត្រឡប់ទៅភូមិឃុំវិញ ។

សរុបមកវិញ ពាក្យដែលថា កាលដែលរាយការណ៍ទៅខាងលើដើម្បីឲ្យមានការដាក់ទោសទណ្ឌដោយឡែកណាមួយនោះ យើងខ្ញុំធ្វើខុសពីរបែបនេះ ។ ទីមួយនៅមន្ទីរ-១៣ "ខ" រាយការណ៍ទៅលើខាងលើដក ។ ឯចំណែកនៅ មន្ទីរ-១៣ "ក" យើងខ្ញុំរាយការណ៍ទៅលើ ហើយសុំអនុញ្ញាតមេបញ្ចេញគេទៅភូមិឃុំវិញ ។

[១១:១៣:២៩]

**ស៖** លោកបាននិយាយកាលពីម្សិលមិញនេះខ្ញុំពិនិត្យឃើញថា គឺថាមានមនុស្សប្រាំបីនាក់ ដែលលោកបានរៀបចំដើម្បីដោះលែងមនុស្សប្រាំបីនាក់ ហើយមិនត្រូវបានសម្លាប់ទេអ្នកទាំងប្រាំបីនោះ ។ ពេលនោះ លោកបាននិយាយថា ក្នុងករណីពិសេស នៅក្នុងចម្លើយមិនបានបញ្ជាក់ពីម្សិលមិញទេ ប៉ុន្តែនៅក្នុងចម្លើយមួយនៅសហចៅក្រមស៊ើបអង្កេត លោកបាននិយាយអំពី ហាម អ៊ីន ។ បាទ ហាម អ៊ីន នោះ គឺជាមនុស្សដែលលោកបានដោះលែង តើលោកអាចពន្យល់ប្រាប់យើងបានទេ តើអ្វីជាទំនាក់ទំនងដែលលោកមានជាមួយលោក ហាម អ៊ីន ហ្នឹង?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំដោះលែងដប់នាក់ ។ តែពេលដែលខ្ញុំឆ្លើយចំពោះលោកចៅក្រមស៊ើបអង្កេត ខ្ញុំនឹកឃើញពេលនោះតែប្រាំបីនាក់ទេ ។ ដល់ខ្ញុំមកអានសៀវភៅ "*ឡឺព័រតែល*" របស់ប៊ីហ្ស ខ្ញុំនឹកឃើញម្នាក់ទៀត ដែល ប៊ីហ្ស ដែលគាត់មានសរសេរឈ្មោះ ។ ហើយដល់ថ្មីនេះ ឃើញសាក្សីដែលបង្ហាញខ្លួនមកនេះ គឺមានសាក្សី គឺ KW-30 ជាបុគ្គលម្នាក់ដែលខ្ញុំដោះលែងដែរ ។ ទាំងអស់

ដប់ ។

ដោយឡែក ខ្ញុំបាននិយាយល្អិតណាស់ជូនលោកចៅក្រមស៊ើបអង្កេតអំពីរឿង ហាម អ៊ិន និងខ្ញុំមិនដែលស្គាល់គ្នាទេពីមុនមក ប៉ុន្តែខ្ញុំស្គាល់ឪពុក ហាម អ៊ិន ។ ខ្ញុំស្គាល់ឪពុក ហាម អ៊ិន ច្បាស់ណាស់ខ្មោចបង ហាម ។ ក្នុងចំណោមកម្មាភិបាលឃុំអមលាំង មានតែ បងហាម ទេ ដែលក្រជាងគេ ក្រមែនទែនហើយស្លូតជាងគេ ។ ដល់ឃើញគេចាប់គ្នាប្រាំនាក់បញ្ជូនមកនេះ ខ្ញុំឲ្យគេសួរចម្លើយមួយព្រួស ក្ដាប់ប្រវត្តិរូប ។ ខ្ញុំក្ដាប់បានថា ហាម អ៊ិន នេះ កូន បងហាម ។ ខ្ញុំថា អីយ៉ាស់! តែខ្ញុំប៉ានធ្វើទារុណកម្ម អាអ៊ិន ហើយខ្ញុំសម្លាប់ អាអ៊ិន តាមគោលការណ៍កំណត់របស់បក្ស ច្បាស់ជា បងហាម មកហើយ មកមិនខានទេ ខ្ញុំអាណិត ។ ដោយឈរលើវណ្ណភាព ខ្ញុំស្ទុះរឹងទៅជួបបង ជួត ជេត ហៅ ស៊ី សុំគាត់ដោះលែង អាអ៊ិន ។ បងស៊ី ប្រាប់ថា “អេ! ឌុច មនុស្ស បងប៉ាល់ គេចាប់ទេ ទៅសុំគេទៅ ខាង បងប៉ាល់ គេសម្រេច” ។ ខ្ញុំស្ទុះរឹងទៅជួប បងប៉ាល់ សុំសម្រេច ។ បងប៉ាល់ គាត់ទទួលស្ដាប់ពាក្យសំណូមពររបស់ខ្ញុំ តែគាត់ថា ឌុច កុំអាល ចាំមើលខ្ញុំសុំអចិន្ត្រៃយ៍ភាគសិន ។ ប្រហែលជាពីរខែក្រោយមក ខ្ញុំឃើញ បងប៉ាល់ អញ្ជើញទៅ លោកតា ហួត ហេង នេះ ហៅ ប៉ាល់ អញ្ជើញទៅពីរនាក់ បងហុក ខ្ញុំ ។ ទៅដល់ប្រាប់ថា អចិន្ត្រៃយ៍ភាគគេសម្រេច “ទុកឲ្យរស់ ប៉ុន្តែមិនឲ្យដោះលែងទេ ។ យប់ដេកនៅជាមួយនឹងអ្នកទោសដូចគេដូចឯងទៅ ប៉ុន្តែកុំដាក់ជើង ថ្ងៃឡើងឲ្យចេញទៅធ្វើការទៅ ប៉ុន្តែកុំសម្លាប់កុំសួរចម្លើយ” ។

[១១:១៧:១៩]

ដូច្នេះ រឿងផ្ទាល់ខ្លួន ហាម អ៊ិន និងខ្ញុំគ្មានការទាក់ទងទេ តែជាមួយឪពុក ខ្ញុំមានមនោសញ្ចេតនាណាស់ ជាមួយឪពុក នេះម៉្យាង ។ ម៉្យាងទៀត ផ្ទាល់ខ្លួនវា អាអ៊ិន នេះ ពេលដែលខ្ញុំជួបវាដំបូង តែកាលណាអ្នកណាដែលខ្ញុំចង់ដោះលែងហើយ ខ្ញុំមិនដែលឲ្យអ្នកសួរទេ ខ្ញុំសួរផ្ទាល់ខ្លួនឯង សួរចុះ សួរឡើង ខ្ញុំដឹងថា អាអ៊ិន ឆ្នាំមមី ។ ខ្ញុំថា យីអា! ពួកអាមមីនេះក៏ពូកែជាប់គុកម្ល៉េះ អញក៏មមីដែរ ក៏ជាប់គុកទៀត ហែងអាឡូវមកជាប់គុកទៀត រួចឥឡូវហែងធ្វើអី? ធ្វើ *សេ.អ៊ី.អា* ចង់សម្លាប់ឪហែងផង អញផង? ហែងរកគិតសម្លាប់ឪហែង? ដល់ខ្ញុំនិយាយប៉ុនហ្នឹង ថាសម្លាប់ឪហែង? អាអ៊ិន យំបណ្ដោយ ។ ដូច្នេះ មនោសញ្ចេតនាខ្ញុំ និង អាអ៊ិន មានពីពេលហ្នឹងមែន ។ ក៏ប៉ុន្តែ ពីមុនមកខ្ញុំមិនដែលស្គាល់ទេ ខ្ញុំពិតជាមានមនោសញ្ចេតនាជាមួយនឹង បងហាម ។

រឿងដែលចង់ដោះលែង គឺខំចេះទេ ចេះតែខំដោះលែងមនុស្សហើយ ។ បានមិនបានទេ ប៉ុន្តែអាអ៊ិន ហ្នឹង ជាការពិបាកជាងគេ ។ ខ្ញុំសូមជម្រាបលោកចៅក្រមប៉ុណ្ណឹង ។

**[១១:១៨:៣៣]**

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា នៅពីចំណុចចាប់ផ្តើមដំបូងនៃសវនាការយើងនេះ យើងបានបញ្ជាក់ថា នៅក្នុងឯកសារនឹងត្រូវប្រើនូវD៥៩ ។ ឯកសារនេះ គឺជាចម្លើយដែលបានកត់ត្រា ដោយតំណាងរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា ហៅ *ឌីស៊ីខេម* ដែលឈ្មោះថា ហាម អ៊ីន ហើយនិងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១ ។ ខ្ញុំសូមបន្ថែមថា ឈ្មោះ ហាម អ៊ីន គឺជា-- ស្ថិតនៅក្នុងកម្មវត្ថុនៃការសំណើ ដើម្បីសម្ភាសន៍ដោយសហព្រះរាជអាជ្ញាក្នុងដំណាក់កាលស៊ើបអង្កេត ហើយការបញ្ជាក់ពិនិត្យមើល ផ្ទៀងផ្ទាត់ គឺថាធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ហើយនិងបានឈានទៅដល់ព័ត៌មានមួយ ដែលថា ហាម អ៊ីននោះ គាត់បានស្លាប់នៅក្នុងឆ្នាំ២០០៣ ទៅហើយ ។ ហើយនៅក្នុងចម្លើយនៅក្នុងថ្ងៃទី-- នៅក្នុង D៥៩ជាឧបសម្ព័ន្ធនោះ ហាម អ៊ីន នោះបាននិយាយថា ពីបទពិសោធន៍របស់គាត់នៅក្នុង-- ជាអ្នកជាប់ឃុំឃាំង ហើយក៏ជាបុគ្គលិកនៅក្នុងម-១៣ នោះដែរ ។ គាត់បានរៀបរាប់ថា ឌុច គឺជាប្រធាននៃម-១៣ហើយក៏ជាមនុស្សម្នាក់ដែលជាអ្នកធ្វើការសម្រេចថា អ្នកណាត្រូវសម្លាប់ អ្នកណាត្រូវកម្ទេច ឬក៏អ្នកណាដែលត្រូវយកទៅសួរចម្លើយ ។ ហើយគាត់បានវាយបញ្ជីនូវទម្រង់អំពើឃោរឃៅមួយចំនួន ដែលប្រើនៅក្នុងការសួរចម្លើយ ហើយគាត់បានបញ្ជាក់ថា គាត់ជាសាក្សីផ្ទាល់ភ្នែកទៅលើហេតុការណ៍ដូចខាងក្រោមនេះ ។ គាត់បាននិយាយថា គាត់បានឃើញដោយផ្ទាល់ភ្នែកនូវការវាយដំ គឺថាជនរងគ្រោះត្រូវបានវាយជាពិសេស ហើយៗក្ដួយបងជីដូនរបស់គាត់ត្រូវបានកាប់ វះនឹងកាំបិត ហើយត្រូវបង្ហូរឈាមដាក់ទៅក្នុងធុងមួយ ហើយគាត់ធ្វើដោយខ្លួនឯង ហើយគាត់បានឃើញគេព្យួរអ្នកទោសចងកដៃឬក៏ចងកជើង ព្យួរក្បាលចុះក្រោម ។ ហើយគាត់បានចង្អុលបង្ហាញថា ហើយក៏គេមាន-- គេចាក់ម្ជុលទៅនឹងក្រចករបស់អ្នកទោស អ្នកជាប់ឃុំ ហើយអ្នកខ្លះ គេបានដកក្រចកពីអ្នកទោស ហើយគាត់បានបញ្ជាក់ថា អំពើទារុណកម្មបានធ្វើ ។ គេបានប្រើចន្លុះ ដោយមានដុតក្រមួន ជួនកាលយកទៅអុជនឹងមនុស្ស ។ ហើយគាត់ក៏បានបញ្ជាក់ទៀតថា ហើយក៏បានប្រើទឹកសាប៊ូ គេបានប្រើទឹកសាប៊ូ ហើយក៏បានចាក់ចូលទឹកចូលក្នុងបំពង់ក ឬក៏មាត់របស់អ្នកជាប់ទោសដោយអ្នកយាម ។ ហើយគឺជនជាប់ចោទខ្លួនឯងហ្នឹង ក៏បានប្រព្រឹត្តនូវបទទារុណកម្មដែរ ហើយក៏គាត់ថា ជាអំពើមួយឃោរឃៅ ដែលមើលទៅពេលនោះ គឺមានកុមារក៏បានហៅឲ្យកុមារមកមើលអំពើហិង្សាហ្នឹងដោយផ្ទាល់ ហើយក៏បានពន្យល់ថាគាត់ថា "គាត់បានគេជួយសង្គ្រោះដោយហេតុថា-- ហើយគាត់សារភាពថា គាត់ជាខ្មាំង ហើយគាត់ជា

អតីតនគរបាល ហើយមានស័ក្តិ៣នឹងស្មារបស់ខ្លួន ។

នៅពេលដែលជនជាប់ចោទបានដោះលែងគាត់រួចហើយ ជនជាប់ចោទបានសុំឲ្យគាត់ធ្វើការឲ្យជនជាប់ ហើយដើម្បីធ្វើជាគិញ ដើម្បីស៊ើបពីអ្នកជាប់ទោសផ្សេងៗទៀតនោះ រាយការណ៍ឲ្យគាត់ ។ ហើយ ហាម អ៊ិន នោះ បានបញ្ជាក់ថា អំពីកម្ទេចមនុស្សជាច្រើននៅម-១៣ ។

[១១:២៣:១៦]

ជនជាប់ចោទបានបញ្ជាក់ថា មានជនរងគ្រោះពីពីរទៅបីរយនាក់ ។ អ៊ីចឹង ហាម អ៊ិន នោះក៏បាននិយាយថា បីពាន់នាក់ដែលត្រូវសម្លាប់នៅទីនោះ *ស៊ីធីសាវសិន* ឬបីម៉ឺននាក់នៅម-១៣ ។

**ស៖** ដូច្នេះហើយ ខ្ញុំចង់ស្តាប់ តើលោកមានមតិយោបល់ដូចម្តេច? តើលោកបានអានចម្លើយ ហាម អ៊ិន នោះទេ?

**ឆ៖** *កុម្ម៉ង់ទែ* របស់ ហាម អ៊ិន ខ្ញុំអត់ទាន់បានអានទេ ។ ក៏ប៉ុន្តែ តាមការដែលលោកចៅក្រមអានឲ្យខ្ញុំស្តាប់អម្បាញ់មិញ រឿងមួយដែលនៅសល់មានភស្តុតាងសម្រាប់ការស្រាវជ្រាវតទៅទៀត គឺរឿងខ្មោច មានជនរងគ្រោះដែលត្រូវសម្លាប់នៅមន្ទីរ-១៣ ។ ខ្មោចជនរងគ្រោះដែលសម្លាប់នៅមន្ទីរ-១៣ វាអត់ដែលទៅណាឆ្ងាយអំពីទីតាំងរបស់មន្ទីរ១៣ នុ៎ងទេ យ៉ាងច្រើនមួយរយម៉ែត្រ ។ ដូច្នេះ មន្ទីរ១៣ វាមានកន្លែងវាបី ។ គឺកន្លែងទីមួយនៅថ្នគុប ត្រង់ម្តុំអន្លង់វែង កន្លែងទីពីរ គឺនៅតាលាវ ដែលយើងខ្ញុំកម្ទេចឬហៅថា "សម្លាប់" តិចបំផុត ហើយកន្លែងទីបី នៅត្រពាំងគ្រោប ភូមិត្រពាំងគ្រោបក៏ចន្លោះស្ទឹងនិងត្រពាំងច្រាប ។

[១១:២៥:០១]

ភស្តុតាងដែលនៅសល់ វាអាចបញ្ជាក់បានថា ខ្មោចហ្នឹងវាមានអាយុពីអង្កាល់មក? ហើយវាមានចំនួនប៉ុន្មានច្បាស់លាស់? សម្រាប់បញ្ជាក់នូវសេចក្តីដែលខ្ញុំសារភាពការស្មោះត្រង់ជូនជាតិ ប្រជាជនរបស់ខ្ញុំ ។ ឯចំណែកសពផ្សេងទៀតនៅកន្លែងផ្សេងទៀត វាជាសពរបស់មនុស្សខ្មែរ ជាសពខ្មែរដែលស្លាប់ទៅ ដោយសារស្នាដៃបក្សកុម្មុយនីស្តកម្ពុជា ។ ខមាទោស ខ្ញុំសុំខមាទោសដដែល អត់ប្រកែកទេក៏ប៉ុន្តែទទ្ទឹម នឹងនេះខ្ញុំក៏សម្តែងការសោកស្តាយប៉ុណ្ណោះ ហើយនិងរំលែកទុក្ខចំពោះក្រុមគ្រួសារញាតិមិត្តនៃសព ។ ក៏ប៉ុន្តែថា រឿងនេះឲ្យវាពិតថាជាស្នាដៃមន្ទីរ-១៣ ស្នាដៃមន្ទីរ-១៣ មានប្រហែលពីរទៅបីរយនាក់ប៉ុណ្ណោះ អត់មានដល់ពីរ-បីម៉ឺនទេ ។ សូមលោកចៅក្រមមេត្តាពិចារណាប៉ុណ្ណោះ មួយថ្ងៃចូលប៉ុន្មាននាក់? មកពីណាខ្លះ?

ដូច្នេះបើសិនយើងគិតថាមួយថ្ងៃប៉ុន្មាន? មួយថ្ងៃម្ភៃទៅសាមសិបនាក់ មែន ដល់ប៉ុណ្ណឹង មែន ក៏ប៉ុន្តែបើយើងគិតថា បួនដប់ថ្ងៃ ឃើញមកមួយ ឬឃើញមកពីរ អាហ្នឹងវាផ្សេង ។ ហើយខ្ញុំបានរាយការណ៍ជូនលោកចៅក្រមមិញហើយ មានមកជាច្រើនៗ នៅពេលដែលវាយខដុង្គឈ្នះ ។ មេខ្ញុំឲ្យមកប្រហែលជា៥០នាក់កាលពីជំនាន់នោះ ក៏ប៉ុន្តែវ័លែកឲ្យទៅខាងពាយ័ព្យ ជម្លៀសទៅខាងពាយ័ព្យ ។ លេងគាត់ដកមនុស្សពីភូមិពោធិអស់មួយភូមិ យកទៅដាក់នៅមន្ទីរ១៣ ហើយឲ្យឡានដឹកយកទៅពាយ័ព្យ ។ នេះមកច្រើនៗ មិនមែនមកដើម្បីឲ្យម-១៣ សម្លាប់ទេ គឺជាដំណាក់កាលឆ្លងកាត់ប៉ុណ្ណោះ ។ នេះជាហេតុការណ៍ដែលខ្ញុំសូមរាយការណ៍ជូនលោកចៅក្រមថា មកច្រើនៗមានពីរលើកហ្នឹង ប្រហែលជាអាចមានពីរលើកហ្នឹង យ៉ាងតិចក៏មានពីរលើកហ្នឹងដែរ នេះមកច្រើនៗ ។ ក៏ប៉ុន្តែមិនមែនសម្រាប់ម-១៣ទាំងអស់ទេ គឺសម្រាប់ដឹកយកទៅពាយ័ព្យ ។ នេះជាហេតុការណ៍ដែលខ្ញុំសូមបញ្ជាក់ ។

ឯចំណែក ភស្តុតាងដែលនៅសល់ខ្ញុំនៅតែរក្សាដដែលគឺរណ្តៅកប់សាកសពរបស់ម-១៣ វាផ្សេង ។ ភស្តុតាងនេះទុកសម្រាប់យើងជាអ្នកស្រាវជ្រាវតទៅទៀតរកការពិត ។ ខ្ញុំទទួលស្គាល់ភស្តុតាងនេះ ។ ក៏ប៉ុន្តែ ដោយឡែកការបាត់បង់ ជនរងគ្រោះទាំងប៉ុន្មានជាឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំនៅតែទទួលស្គាល់តាមសេចក្តីថ្លែងការណ៍ដំបូងបំផុតរបស់ខ្ញុំដែលបង្ហាញមុខជូនអង្គជំនុំជម្រះនេះឥតប្រកែកទេ ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណោះ ។

**ស៖** ឥឡូវនេះសេចក្តីដកស្រង់ចេញពីឯកសារមួយ ខ្ញុំនឹងអានជាភាសាបារាំងនៅក្នុងទំព័រទី៦ ។ ព័ត៌មានទាក់ទងទៅនឹងសាច់រឿងរបស់ការលង់ទឹកស្លាប់ ។ អត្ថបទភាសាបារាំងមានដូចខាងក្រោម៖

ទាក់ទងទៅនឹងមានការទឹកជំនន់ តើវាមានរឿងអ្វីកើតឡើង?

[១១:២៨:៤០]

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាចង់មាន និយាយអីទៅ? សូមអញ្ជើញ!

**លោក រ៉ូបឺត ពើទីត៖**

ដោយមានការអនុញ្ញាតពីលោកចៅក្រម សូមលោក យោងទៅរក *ERN* នៅក្នុងទំព័រខាង លើអាចនឹងជួយឲ្យយើងខ្ញុំ ឲ្យយើងកត់ត្រាប្រតិចារឹក ហើយនិងភាគីអាចយោងបានពីព្រោះទំព័រគឺថាមិនអាចនឹងឆ្លើយអំពីការបកប្រែនូវអត្ថបទដើម។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមិនមានលេខ *ERN* នៅក្នុងអត្ថបទបារាំងរបស់ខ្ញុំទេ ។ ប្រសិនជាមាននៅក្នុងភាសា អង់គ្លេស មើលទៅ ។

**លោក រ៉ូបឺត ពើទីត៖**

គឺថានៅក្នុងសំណុំរឿងគឺថា ដាក់នៅថ្ងៃទី៦ ខែមិថុនា តើហ្នឹងជាអត្ថបទដែលមាន--

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

--

**លោក រ៉ូបឺត ពើទីត៖**

ប្រហែលជាមិនទាន់បានផ្តល់ឲ្យចុះលេខ *ERN* ទេមើលទៅ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

នៅក្នុងប្រព័ន្ធ *សាយលេប* យើងមានប្រព័ន្ធ ERN០០២៩៥០៨៧ នៅក្នុងអត្ថបទបារាំង ឯកសារបារាំង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើលោក លោកស្រីចៅក្រម អស់លោក គ្រប់ភាគីបានឃើញកថាខណ្ឌ ខ្ញុំនឹងរំឭកឡើងវិញ សំណួរទាក់ទងទៅនឹងបញ្ហាទឹកជំនន់ តើថាទឹកជន់នោះ វាជន់របៀបម៉េច? តើភាគីទាំងអស់បានឃើញទេ? អ្នកបកប្រែសូមលើកថា គឺថា០០២ គឺថា លោកចៅក្រម ថាតើលោកអាចពិនិត្យឃើញលេខ *ERN* បានទេ?

[១១:៣០:៤៦]

**លោក រ៉ូបឺត ពើទីត៖**

នៅក្នុងអត្ថបទអង់គ្លេស ០០០២៨៩៨៤៥។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

តើលេខ *ERN* នៅក្នុងភាសាខ្មែរ មានទេ? ប្រហែលជាលោកសហព្រះរាជអាជ្ញាអាចនឹងជួយយើងបាន ។ ខ្ញុំនិយាយខ្មែរមិនបានទេ សុំទោស។

**លោក រ៉ូបឺត ពើទីត៖**

ប្រហែលជាអាចនឹងផ្តល់ជូនពេលក្រោយ ប៉ុន្តែអ្នកបកប្រែអាចចង្អុលបង្ហាញ ០០០២០៨៦ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រសិនបើភាគីទាំងអស់ឯកភាពហើយ ខ្ញុំសូមអានឯកសារនេះ “ថាតើទឹកជំនន់នោះវាកើតឡើងរបៀបណា? នេះជារឿងរ៉ាវទាក់ទងទៅនឹងទឹកជំនន់ នៅពេលដែលមានទឹកជំនន់ ហើយមានមនុស្សមួយចំនួនច្រើនស្លាប់ មនុស្សមួយចំនួនតូចទេដែលបានដោះលែង ហើយខ្ញុំធ្វើការនៅក្នុងវាលស្រែ ហើយក៏មានការតាមដានមើលពីក្រោយដែរ ។ នៅក្នុងពេលមានទឹកជំនន់នោះ គឺថាវាមាន ហើយគេមានដឹកអ្នកទោសមួយចំនួន ហើយខ្ញុំបានយកទៅមួយកន្លែងដែលឆ្ងាយពីកន្លែងទឹកជន់ ហើយខ្ញុំជួយគេឆ្លងទឹក ហើយដាក់ទុកអ្នកទាំងនោះ។ អ្នកខ្លះដែលចេញមិនទាន់ទេ ត្រូវបានលង់ទឹកស្លាប់ ដូចដែលខ្ញុំបាននិយាយពីដើម ។ អ្នកខ្លះដែលត្រូវឃុំខ្លួនដាច់ដោយឡែកនៅក្នុងកន្លែងឃុំឃាំងនោះ គឺថាម្នាក់ៗគឺថាបីម៉ែត្រគុណនឹងបីម៉ែត្រនៅគ្រប់ទៅកន្លែងនៃរណ្តៅដែលនៅក្នុងរណ្តៅនោះ នៅពេលដែលទឹកជំនន់ឡើងយ៉ាងឆាប់ គឺថាអ្នកទោសជាច្រើនត្រូវបានលង់ទឹកស្លាប់ ។ តាស៊ុម ក៏ជាប្រធានដែរ ប៉ុន្តែគាត់ជាអនុរបស់តាឌុច នៅពេលនោះ ។ តាស៊ុម នោះជាអ្នកសួរចម្លើយខ្ញុំ ហើយគាត់បានរៀបចំឯកសារ ហើយនិងប៊ិច ។ ដូច្នេះ ហើយខ្ញុំអាចធ្វើជាអ្នកតាមដានទៅលើ ឌុច វិញ ។ ដូច្នេះ ខ្ញុំបាននិយាយប្រាប់គាត់ថាយើងមិនគប្បីធ្វើអញ្ចឹងទេ នៅពេលដែលដំរីជល់គ្នាហើយ គាត់ថាបើសិនជាស្រមោច-- ដំរីមួយដួលគឺថាស្រមោចទេជាអ្នកស្លាប់ តើមានមនុស្សស្លាប់ប៉ុន្មានក្រោយពីទឹកជំនន់? គឺថាមានច្រើន ។ គាត់សួរខ្ញុំថា តើវាមានរឿងអ្វីតទៅទៀត?

យើងបានស្ទោរដំឡូង ហើយក៏គាត់សុំឲ្យខ្ញុំតាមដាន តាឌុច ហើយនៅពេលនោះ មានមនុស្សស្លាប់ច្រើនណាស់ គាត់បានសួរខ្ញុំថា នេះអានេះ កើតឡើង។ គឺថាមិនអាចជឿថាតើហេតុអីបានជាបណ្តាលឲ្យមនុស្សស្លាប់ច្រើនអីចឹង? ខ្ញុំបានដឹង ប៉ុន្តែខ្ញុំមិនដឹងថា មិនហ៊ានប្រាប់គាត់ទេ ហើយខ្ញុំបានបញ្ជាក់ថា គឺថាមានមនុស្សច្រើនណាស់ ដែលស្លាប់ ហើយគាត់អាចសួរទៅអ្នកយាមបាន បើគាត់មិនជឿខ្ញុំ ។ អ្នកយាមនោះបញ្ជាក់ថា មានស្លាប់ច្រើនណាស់ ហើយខ្ញុំយល់ ខ្ញុំបានឃើញស្ត្រី៦ ឬក៏៧នាក់ ហើយគេមិនឋិតនៅក្នុងសុខភាពល្អទេគឺស្គមស្គាំងណាស់ ហើយខ្ញុំបានយកគេទៅដីគោកខាងចុងបញ្ចប់” ។

នេះជាអត្ថបទមួយផ្សេងទៀត អ្វីដែលលោកបានចង្អុលបង្ហាញប្រាប់យើងគឺថា ភាពខុសគ្នាមួយដែលនៅក្នុងនេះគឺថា មានអ្នកទោសស្រីមួយចំនួនត្រូវបានគេយកទៅកន្លែងដីគោក ។ ប៉ុន្តែ មនុស្សមួយចំនួនទៀត ដែលតាមមតិសាក្សីនេះគឺថា ចំនួនច្រើនត្រូវបានលង់ទឹកស្លាប់ ប៉ុន្តែព័ត៌មានមួយផ្នែកទៀត

នោះបង្ហាញថា គាត់និយាយថា គេបានសុំឱ្យសាក្សីនេះតាមដានលោក ហើយដើម្បីរាយការណ៍ពីលោកទៅអ្នកថ្នាក់មួយទៀត ដែលថាជាអ្នកទទួលខុសត្រូវចំពោះការស្លាប់ដោយសារទឹកជំនន់នេះ ។

**ស៖** តើលោកអាចឆ្លើយដូចម្តេចបានទៅនឹងព័ត៌មាននេះ?

[១១:៣៥:០៧]

**ជនជាប់ចោទ៖**

**ឆ៖** អំពីរឿងអ្នកស្លាប់ដោយសារគ្រោះទឹកជំនន់ ខ្ញុំនៅតែរក្សាសេចក្តីបញ្ជាក់របស់ខ្ញុំដដែល គឺអ្នកដែលលិចត្រឹមក បាន១ខ្ញុំឱ្យគេជួយជញ្ជូនទៅម្ខាងណោះ ។ ដូច្នេះ គ្មានអ្នកណាលង់ទឹកទេ ក៏ប៉ុន្តែបច្ច័យដែលកើតមកពីគ្រោះទឹកជំនន់នេះ ធ្វើឱ្យសុខភាពខ្សោយ ពីបីថ្ងៃក្រោយមកស្លាប់ ប៉ុន្តែស្លាប់មិនច្រើនទេ នេះខ្ញុំនៅតែរក្សាការពិត ថាវាអញ្ចឹង ។

ចំណែកនិយាយពីរឿងមួយទៀត វាជារឿងមិនគួរឱ្យជឿទេ ។ មិត្តស៊ុម គាត់ធ្វើជាអនុប្រធានខ្ញុំមែន គាត់ចង់បានបុណ្យស័ក្តិធំជាងខ្ញុំមែន។ ក៏ប៉ុន្តែ គាត់នៅមន្ទីរ១៣"ខ" គាត់គ្មានសិទ្ធិទាក់ទងជាមួយនឹងអ្នកទោស ឬក៏អ្នកទោសរួចខ្លួន ឬក៏បុគ្គលិកណាម្នាក់នៅមន្ទីរ១៣"ក" បានទេ ។ ដូច្នេះ គ្មានសិទ្ធិ--គាត់មិនមានលទ្ធភាពនឹងទៅបញ្ចុះបញ្ចូលអ្នកណាឱ្យយកការណ៍ពីខ្ញុំបានទេ ហើយខ្ញុំសូមបញ្ជាក់ថា ក្នុងឋានៈខ្ញុំជាអ្នកទទួលខុសត្រូវលើមន្ទីរ១៣"ក" គ្រោះថ្នាក់បែបនេះ ធ្លាក់ទៅលើជនរងគ្រោះ ខាងលើគេមិនយកចិត្តទុកដាក់នឹងកម្ទេចខ្ញុំ ឬក៏ដាក់ទោសលើខ្ញុំទេ ។ សូម្បីតែជនដែលរត់រួចនៅតាលាវ ខ្ញុំសុំគេឱ្យគេដាក់ទោស ដើម្បីឱ្យខ្ញុំបានរួចចេញពីការងារនគរបាល គេអត់ដាក់ទោសទៀត នេះជារឿងពិតជាក់ស្តែង ។ ដូច្នេះ មិត្ត ស៊ុម គាត់គ្មានលទ្ធភាពទាក់ទងជាមួយនឹង ហម អ៊ីន ដើម្បីសុំឱ្យហម អ៊ីន ធ្វើគិញ យកការណ៍ពីខ្ញុំទេ ។ អត់ទេ ។

**ចៅក្រម ហ្សង់ម៉ាកឡាវែន៍៖**

ខ្ញុំអានដំណកស្រង់មួយទៀត នៅក្នុងទំព័រលេខ១០នៃភាសាបារាំង ។ ខ្ញុំនឹងអានអំពីសំណួរទាក់ទងទៅនឹងការឃុំខ្លួន ថាតើសុំឱ្យផ្តល់លេខឯកសារ *ERN* ជាភាសាបារាំងបានដែរឬទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

គឺ០០២៩៥០៩១ ដែលជាលេខ *ERN* នៅក្នុងភាសាបារាំង ។

**ចៅក្រម ហ្សង់ម៉ាកឡាវែន៍៖**

ថាតើទំព័រនោះបានរកឃើញហើយឬនៅ នៅក្នុងឯកសារអង់គ្លេស?

**លោក រ៉ូបឺត ពេទីត៖**

ថាតើខ្ញុំសុំសំណួរ ឲ្យអានសំណួរ ។

**ចៅក្រម ហ្សង់ម៉ាកឡាវែន៍៖**

សំណួរដូចខាងក្រោមនេះ តើលោកជួប ឌុច ញឹកញាប់ដែរឬទេនៅពេលដែលធ្វើការនៅទីនោះ? ខ្ញុំឆ្លើយថារៀងរាល់ថ្ងៃ ។ ថាតើគាត់និយាយជាមួយលោកទេពេលដែលជាប់គុកនោះ?

**លោក រ៉ូបឺត ពេទីត៖**

ឯកសារភាសាខ្មែរ គឺ០០០០២៨០៦ ។ គឺលេខ *ERN* គឺ២០០០២៨៧៤៩ ភាសាបារាំង និងអង់គ្លេស វាមានលក្ខណៈខុសគ្នាបន្តិចទៅនឹងឯកសារ ដែលលោកបានអាន គឺឯកសារទាំងពីរ គឺវាមានលក្ខណៈខុសគ្នា ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

មេធាវីសូមលើកឡើងថា ឯកសារនេះ មិនមែនឯកសារតុលាការនោះទេ គឺឯកសារដែលប្រមូលដោយអង្គការមិនមែនរដ្ឋាភិបាល ដែលគាត់មានការងារច្រើន គឺមិនមែនជាឯកសាររបស់ចៅក្រមស៊ើបអង្កេតនោះទេ ។ ចំណុចនេះ គួរតែបញ្ជាក់នៅដែលយើងប្រើឯកសារបែបនេះ ។

[១១:៣៩:៥៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំនឹងអាន ប្រសិនបើមានចំណុចខុសគ្នានោះ សូមឲ្យលោកបញ្ជាក់ឲ្យខ្ញុំបានត្រឹមត្រូវ ដើម្បីឲ្យខ្ញុំធ្វើការកែប្រែ ។

*ក្នុងពេលជាប់គុក តើលោកជួប ឌុច ជាញឹកញាប់ដែរ ឬទេ? ខ្ញុំជួបគាត់ញឹកញាប់ ។ តើនិយាយជាមួយលោកដែរឬទេ? គឺគាត់និយាយជាមួយខ្ញុំ គាត់មិនឆ្មើងទេ ។ ហើយគឺគាត់មាន-- នៅពេលដែលគាត់ចង់ធ្វើការកម្ទេចអ្នកទោស គឺគាត់នឹងចង្អុល ហើយនិយាយថា "យកមួយនេះទៅកម្ទេច" ។ នៅពេលដែលគាត់និយាយ គឺគាត់និយាយធម្មតាហើយសើចដូចអ្នកដទៃ ប៉ុន្តែនៅពេលដែលគាត់និយាយថា "គាត់វាយអ្នកទោស គឺគាត់វាយអ្នកទោសភ្លាម" ។ សំណួរថាតើលោកឃើញដោយផ្ទាល់ភ្នែកដែរឬទេ?*

**លោក រ៉ូបឺត ពេទីត៖**

គឺលោកអានអត្ថបទហ្នឹង ឬក៏នៅចុងក្រោយអត្ថបទ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

គឺចំណុចអត្ថបទ ដែលវាខុស-- ឬក៏វាខ្វះ ឬក៏វាជាបញ្ហាពិបាកក្នុងភាសាបារាំង ។ ហើយប្រសិនបើវាមានភាពខុសគ្នាផ្សេងៗនោះ យើងមិនចាំបាច់អានជាភាសាបារាំងទេ ។ មានផ្នែកណាមួយវាអត់មាន នៅក្នុងហ្នឹង ឬក៏ឯកសារពីរហ្នឹងខុសគ្នា?

**លោក រ៉ូប៊ឺត ពើទីត៖**

ខ្ញុំមិនគួរតែ-- ខ្ញុំមិនគួរធ្វើការអន្តរាគមន៍ទេ បើសិនបើមានកំហុសតូច ប៉ុន្តែនៅចំណុចនេះ គឺមានការខុសគ្នាច្រើន ។ តើខ្ញុំសូមឲ្យខ្ញុំធ្វើការកែប្រែភាសាអង់គ្លេសដែរ ឬទេចំពោះបញ្ហាហ្នឹង?

អ្វីដែលខ្ញុំសូមលើកឡើង យើងគួរតែអានភាសាខ្មែរទៅ ។ ដូច្នេះហើយឲ្យលោកចៅក្រមនិយាយភាសាខ្មែរ គួរតែអានឯកសារដើមជាភាសាខ្មែរ ដែលឯកសារនោះកត់ត្រាដោយអ្នកធ្វើកំណត់ត្រា ។ ហើយយើងគួរតែកត់សម្គាល់ឲ្យអ្នកបកប្រែ ហើយការបកប្រែគួរឲ្យមានការផ្ទុះបញ្ចាំងជាក់លាក់ចំពោះចម្លើយរបស់សាក្សី ហើយកុំឲ្យជនជាប់ចោទមានបញ្ហាចោទទៅលើបញ្ហាហ្នឹង ។ ដូច្នេះ ខ្ញុំគួរតែសូមឲ្យអានឯកសារដើម ដែលបានយើងដាក់ចូលនៅក្នុងសំណុំរឿងឆ្នាំ២០០៧ ដូច្នេះហើយ គឺខ្ញុំសូមស្នើសុំឲ្យចៅក្រម និយាយភាសាខ្មែរ និយាយឲ្យគាត់ជាអ្នកអានដើម្បីឲ្យអ្នកបកប្រែគាត់បកប្រែ ។ ដូច្នេះហើយចំណុចនេះ គឺជាចំណុចមួយល្អក្នុងការអាននូវឯកសារដើម ។

[១១:៤៣:០៥]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព! មេធាវីការពារក្តីសូមលើកឡើងចំណុចមួយចំនួន ។ ខ្ញុំយល់សំណើរបស់សហព្រះរាជអាជ្ញា ប៉ុន្តែខ្ញុំមានការលំបាកដោយសារតែនៅក្នុងភាសាបារាំងអត់មាន មាននិយាយថានរណាជាអ្នកសួរសំណួរ ហើយនរណាជាអ្នកបកប្រែ ហើយអ្នកបកប្រែនៅពេលនោះគឺបានស្បថហើយនៅចំពោះមុខនរណា ។ ហើយយើងមាននីតិវិធីច្បាប់របស់យើងក្នុងការអនុវត្ត ហើយនៅក្នុងប្រព័ន្ធ *ខំមិនឡូ* គឺខ្ញុំគិតថា យើងគួរតែដោះស្រាយ និងស្តាប់សាក្សី នៅដែលចូលមកតុលាការនេះ ។

ហើយយើងមានសាក្សី ហើយយើងមាចម្លើយមួយនេះដែលយើងអត់ដឹងអ្វីទាំងអស់ ។ ឥឡូវនេះគឺថាភាសាបារាំងយើងនិយាយថា វាខុសគ្នា ទាំងភាសាបារាំង និងភាសាខ្មែរ ។ ហើយយើងនឹងអានភាសាខ្មែរ ដោយយើងអត់ដឹងថា នរណាគេជាអ្នកកត់ត្រាចម្លើយនេះ ។ ហើយយើងគួរតែធ្វើការកោះហៅ

បុគ្គលដែលធ្វើការកត់ត្រាទៅលើចម្លើយនេះគួរតែកោះហៅគាត់មក បើសិនមិនកោះហៅគាត់ឲ្យបញ្ជាក់ទេ គឺយើងមិនអាចបន្តបានទៀតទេ ។

**លោក រ៉ូបឺត ពើទីត៖**

អរគុណលោកប្រធាន ។ គោលបំណងនៃការអានចំណុចនេះ គឺឲ្យជនជាប់ចោទធ្វើការផ្តល់យោបល់ ។ ពាក់ព័ន្ធទៅនឹងចម្លើយរបស់បុគ្គលដែលគាត់ស្គាល់ ហើយដែលជាប់ឃុំ ហើយគាត់បានដោះលែង ហើយគាត់ស្គាល់ជិតស្និត ហើយគឺជាបុគ្គលម្នាក់ ដែលគាត់ថា គាត់ជិតស្និតជាមួយបុគ្គលនោះ ។ ដូច្នេះហើយ គឺអ្នកសាក្សីមួយនេះគាត់និយាយចំណុចមួយចំនួនហើយជនជាប់ចោទ គាត់បានផ្តល់យោបល់អំពីព្រឹត្តិហេតុនោះហើយ ។

ខ្ញុំអត់ឃើញមានភាពលំបាកទេ ដោយសារតែចម្លើយមុនៗ អាចបង្ហាញជនជាប់ចោទ ឬក៏សាក្សី ។ ហើយចម្លើយមួយនេះ គឺជនជាប់ចោទ គាត់បានថាគាត់ពាក់ព័ន្ធជាមួយ ។ ហើយគឺមានការចម្លើយនេះគឺមានការចោទប្រកាន់ទៅលើគាត់ ។

ដូច្នេះ ហើយយើងគួរតែស្តាប់ជំហររបស់ជនជាប់ចោទ ទាក់ទងទៅនឹងការចោទប្រកាន់ទាំងអស់នេះ ។ ហើយយើងឃើញមាន អាចមានសាក្សីមកពី ម-១៣ ដែលគាត់មកផ្តល់សក្ខីកម្មទាក់ទងនឹងការចោទប្រកាន់ដូចគ្នានេះដែរ ។ ដូច្នេះ យើងគួរតែមានរូបភាពផ្ទុះបញ្ចាំងមួយឲ្យបានពេញលេញចំពោះបញ្ហាហ្នឹងហើយស្តាប់ជំហររបស់ជនជាប់ចោទ ។

[១១:៤៥:៥៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមសង្ខេប ភាគីគាត់យល់ស្របទៅនឹងសេចក្តីសង្ខេប ដែលខ្ញុំរៀបចំ ហើយខ្ញុំមានដែរឬទេ? លោក លោកស្រី ចង់ឲ្យខ្ញុំអានអត្ថបទសង្ខេបនេះដែរឬទេ? យើងមិនចាំបាច់អានឯកសារដែលពីរខុសគ្នានោះទេ ។ ប៉ុន្តែ ប្រសិនបើមានការយល់ស្រប ចំពោះសេចក្តីសង្ខេបនោះ គឺជាការល្អ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

មេធាវីសូមធ្វើការកត់សម្គាល់ ។ ទោះបីជាសេចក្តីសង្ខេបនោះក៏ដោយ គឺផ្អែកទៅលើចម្លើយសារភាព-- ចម្លើយសាក្សីមួយដែលបុគ្គលនោះ គាត់មិនមែនជាអ្នកវិជ្ជាជីវៈ ហើយគាត់មិនបានធ្វើការស្បថ ហើយគាត់បំពេញការងារឲ្យអង្គការក្រៅរដ្ឋាភិបាលមួយប៉ុណ្ណោះ ។ ដូច្នេះ យើងគួរតែធ្វើយ៉ាងណាឲ្យមានផលប្រយោជន៍ ។ ខ្ញុំសូមលើកឡើងចំពោះសហព្រះរាជអាជ្ញានៅក្នុងប្រព័ន្ធច្បាប់*ស៊ីវិលឡ*

គឺបុគ្គលហ្នឹង គឺគាត់សួរដោយនគរបាល ហើយបន្ទាបមកគឺយើងមានចៅក្រមស៊ើបអង្កេត ។ ហើយនៅក្នុងករណីនេះ គឺវាខុសគ្នា អង្គការក្រៅរដ្ឋាភិបាលគាត់សម្រេចទៅធ្វើការសម្ភាសន៍សាក្សី ដូច្នេះហើយ វាមិនមែនជាឯកសាររបស់តុលាការទេ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

គឺខ្ញុំបានបញ្ជាក់ច្បាស់លាស់ហើយនៅពេលចាប់ផ្តើមសវនាការនេះ ។ គឺឯកសារនេះមិនបានកត់ត្រាជាឯកសារតុលាការទេ ។ ហើយយើងឃើញមានការចោទប្រកាន់មួយចំនួន ហើយមានការលើកឡើងថា ជនជាប់ចោទគឺគាត់បានផ្តល់ឱកាស ហើយគាត់គួរតែផ្តល់ឱកាសឲ្យធ្វើការផ្តល់យោបល់ទៅលើការចោទប្រកាន់ទាំងអស់នេះ ។ ដូច្នេះ ឯកសារនេះគឺមិនមែនជាផ្នែកមួយនៃដំណើរការរបស់យើងនេះទេ ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

នេះគឺជាអ្វីដែលយើងចង់បានបញ្ជាក់ដើម្បីឆ្លើយតបទៅនឹងចម្លើយរបស់លោក ពេទីត បានលើកឡើង ។ សេចក្តីសង្ខេបរបស់លោកដែលលោកបានរៀបចំចំពោះចម្លើយមួយនេះ គឺវាមានភាពចាំបាច់នូវអ្វីដែលសាក្សីនោះគាត់បានលើកឡើង ។

[១១:៤៨:១២]

**លោកស្រី ជា លាង៖**

សូមអរគុណ លោកប្រធាន ហើយសូមគោរព អង្គជំនុំជម្រះ ។ ដូចបាន លោកចៅក្រម ឡាវ៉ែន៍ លើកឡើងហើយ គឺថាសាក្សីហ្នឹង គាត់ត្រូវបានស្លាប់ហើយ ។ ដូច្នេះហើយមានការបញ្ជាក់ពីចៅក្រមស៊ើបអង្កេត ទោះបីបទសម្ភាសហ្នឹងត្រូវបានអង្គការមួយក្រៅរដ្ឋាភិបាលបានសម្ភាសន៍ហើយក៏ដោយ ។

ទីមួយ ខ្ញុំសូមបង្ហាញទៅដល់ខាងចៅក្រមជាតិ គឺឯកសារហ្នឹងមានឈ្មោះថា អក្សរD១០៨/២៧.៤ ។ ដូច្នេះ នៅលើនេះមានភាសាខ្មែរ ដែលជាភាសាដើមត្រង់ទំព័រ១២ អ្វីដែលលោកចៅក្រមឡាវ៉ែន៍ បានអានអម្បាញ់មិញនេះ ។ នៅក្នុងនេះ ខ្ញុំមិនទាមទារនូវការថា ត្រូវចាំបាច់ដែលចៅក្រមស៊ើបអង្កេតត្រូវតែសួរនោះទេ ដោយសារមានការបញ្ជាក់ពីចៅក្រមស៊ើបអង្កេតគឺថាសាក្សីនោះត្រូវបានស្លាប់ហើយ ។

ដូច្នេះអ្វីដែលចង់ឲ្យលើកឡើងពេលនេះ គឺមានបំណងចង់ឲ្យជំនុំជម្រះហ្នឹងសួរទៅលើជនជាប់ចោទ ហើយនិងបញ្ជាក់នូវអ្វីដែលសាក្សីនោះបានបកស្រាយ ។ នេះគ្រាន់តែជាកំណត់ហេតុដែលអង្គការ

ក្រៅរដ្ឋាភិបាលបានបន្ទល់មែន ប៉ុន្តែយើងចង់ដឹងពីជំហររបស់ជនជាប់ចោទថា គាត់ទទួលស្គាល់នូវអ្វីដែលសាក្សីដែលគាត់បានលើកឡើងមានការពាក់ព័ន្ធនោះ ។ ដូច្នេះ សុំឲ្យអង្គជំនុំជម្រះពិចារណាហ្នឹង ។ ហើយសូមបញ្ជាក់ជាថ្មីម្តងទៀត ចំពោះចៅក្រមខាងជាតិហ្នឹងគឺឯកសារមានជាភាសាខ្មែរតែម្តង ហើយបើសិនមិនមានទាន់ទេ គឺខ្ញុំនឹងអានលេខហ្នឹងឡើងវិញ គឺD១០៨/២៧.៤ ត្រង់ទំព័រ១២ ។ គឺលោកចៅក្រម គាត់បានលើកឡើងអម្បាញ់មិញនេះ គឺមានច្បាស់លាស់តែម្តង ។ សូមអរគុណ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

គឺជនជាប់ចោទ គឺគាត់ចង់ផ្តល់យោបល់នៅចំពោះអ្វីដែលគាត់បានលើកឡើង ។

**ជនជាប់ចោទ៖**

**ឆ៖** អត់ទាន់ផង មិញអាឡែរតែមើលអានេះ ។ សូមទោស ។

**ស៖** ខ្ញុំចង់ដឹងថា តើលោកមានយោបល់ចង់ផ្តល់ចំពោះអ្វី ដែលលោកបាននិយាយអម្បាញ់មិញដែរឬទេ?

[១១:៥០:៤៧]

**ឆ៖** សូមបញ្ជាក់ជូនលោកចៅក្រមថា អំណាចរបស់ខ្ញុំនៅមន្ទីរ១៣ ពេញដៃពេញជើង។ ខ្ញុំរក្សាលក្ខណៈនឹងនក្នុងការចាត់ចែង។ រក្សាសម្ងាត់ ។ ចង់ចាត់ចែងអ្នកណាឲ្យនាំជនរងគ្រោះដែលទៅជាប់ទោសនៅទីនោះ យកទៅកម្ទេច ក៏ខ្ញុំធ្វើជាសម្ងាត់ មិនដើរទៅចង្អុលមើលតែថ្លុកល្ខោនទេ ។ យើងខ្ញុំមិនដែលបានសំដែងល្ខោនទេ ។ ជីវិតមនុស្ស ខ្ញុំអត់ប្រកែកទេ ខ្ញុំទទួលខុសត្រូវ ។ ក៏ប៉ុន្តែអាកប្បកិរិយាដែលថាយើងខ្ញុំដើរទៅចង្អុលដូចថ្លុកល្ខោននោះ មិនមែនជារឿងពិត ។

ខ្ញុំជម្រាបលោកចៅក្រមដោយត្រង់ ខំណាស់ ខំធ្វើការងារឲ្យបានឃើញលក្ខណៈរក្សាសម្ងាត់ជាកម្មាភិបាលមួយដែលមានអំណាចពេញបរិបូណ៌ ។ អំណាចពេញបរិបូណ៌ គឺនៅត្រង់ស្ងាត់ហើយបញ្ជាគេ គេធ្វើតាមគ្មានប៉ានល្មើស ។ នេះអំណាចដែលយើងខ្ញុំរក្សា ។ ឧក្រិដ្ឋកម្មរបស់យើងខ្ញុំផ្ទាល់ខ្លួនរបស់ខ្ញុំផ្ទាល់ខ្លួនទៅលើជីវិតមនុស្ស ខ្ញុំអត់ប្រកែក ។ ក៏ប៉ុន្តែ អាកប្បកិរិយាដែលថាទៅចាក់ថ្លុកដូចថ្លុកល្ខោននោះ មិនមែនទេ មិនមែនជារឿងពិត ។ នេះសូមបញ្ជាក់សារឡើងវិញតែខ្លីប៉ុណ្ណឹង ។

**ប្រធានអង្គជំនុំ៖**

លោក ឡាវែន៍ មានសំណួរអី ត្រូវសួរទៀតទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតអំពីការសួរចំពោះឯកសារ D៥៥ ឧបសម្ព័ន្ធ១២ ទាក់ទងទៅនឹង អ៊ុន វន ។ ប៉ុន្តែខ្ញុំមានបញ្ហាដូចគ្នាប្រហែលជា១ចំណុចល្អដែលថា អង្គជំនុំជម្រះសាលាដំបូងត្រូវការសម្រេចចំពោះការអានឯកសារទាំងអស់នោះ ។ យើងគួរតែធ្វើការសម្រាកសិននៅព្រឹកនេះ ហើយយើងគួរតែធ្វើការសម្រេច និងបញ្ជាក់ប្រាប់នៅពេលដែលយើងឈប់សម្រាកបន្ទាប់ពី អាហារថ្ងៃត្រង់ទៅលើបញ្ហាទាំងអស់នេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសហព្រះរាជអាជ្ញា ។

**លោក រ៉ូប៊ឺត ពើទីត៖**

យើងនិយាយអំពីចម្លើយដែលជាភាសាខ្មែរ គឺឯកសារ D៥៩ ប្រសិនបើវាទាក់ទងទៅនឹង អ៊ុន វន នោះ គឺវានៅក្នុងឯកសារ D៥៩ នៅក្នុងដីកាស៊ើបសួរ ។ ហើយ *ERN* ចំពោះការប្រែ គឺថ្ងៃទី២៤ ខែមីនា ហើយវាបានបញ្ចូលទៅក្នុងសំណុំរឿង គឺ D១០៧.១២ តើវាជាករណីហ្នឹងមែនដែរឬទេ?

នេះជាចម្លើយ ដែលយើងចង់សំដៅដាក់លាក់ទៅលើឯកសារមួយនេះ ។

[១១:៥៤:៣៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រហែលតែយើងធ្វើការបញ្ជាក់អំពីចំណុចយោងក្នុងពេលលើកឡើងនេះ ។ ខ្ញុំសូមលើកឡើងថា លោកបានសុំឲ្យចៅក្រមស៊ើបអង្កេតធ្វើការស៊ើបសួរដោយចៅក្រមស៊ើបអង្កេត ហើយមានការយល់ស្រប ហើយដូច្នេះហើយ គឺយើងគិតថាវាជាការល្អដែលគិតពិចារណាទៅលើបុគ្គលនេះ ។

ហើយអង្គភាពគាំពារសាក្សីនេះ គឺ ហាម អ៊ីន *នេះ* បានស្លាប់ ។ ដូច្នេះ ហើយគឺថា យើងអត់អាចធ្វើការសម្ភាសន៍សួរយកចម្លើយសាក្សី ហាម អ៊ីន នេះទេ ដោយសារតែគាត់ស្លាប់ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន! លោក លោកស្រីចៅក្រម ដើម្បីឲ្យលោក លោកស្រីសម្រេចជំហរទៅលើឯកសារទាំងអស់នេះ ខ្ញុំសូមរំឭកថា សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាទៅលើបញ្ហាហ្នឹងទេ ។ តាំងពីមុនមក យើងឃើញសាក្សីមួយទៀតដែលគេអាចធ្វើការស្តាប់ចម្លើយនៅក្នុងបរិបទនៃក្របខ័ណ្ឌច្បាប់ ។ ដូច្នេះ យើងនៅទីនេះ យើងមានឱកាសផ្សេងមួយទៀត ។ យើងនៅទីនេះយើងមានឯកសារដែលបានបញ្ចូលទៅក្នុងសំណុំរឿងដោយការិយាល័យសហព្រះរាជអាជ្ញា ។ ហើយនៅទីនេះ គឺយើងមិន

មានឯកសារច្បាប់ផ្លូវការ ដូច្នេះជាបញ្ហារបស់យើងនៅទីនេះ ។

ជាថ្មីម្តងទៀត ក្នុងនាមជាក្រុមការពារក្តី ខ្ញុំសូមធ្វើការបញ្ជាក់ទៅលើបញ្ហាហ្នឹង ហើយខ្ញុំសូមលើកឡើងអំពីឯកសារនេះ យើងមិនយល់អំពីឯកសារ និងអ្នកដែលបានរៀបចំឯកសារនេះ ។ ហើយយើងមិនដឹងអំពីសមត្ថភាពរបស់បុគ្គលដែលធ្វើការសួរចម្លើយ សួរយកចម្លើយនោះ ។ យើងមិនយល់អំពីគោលបំណងរបស់គេទេ ។ ដូច្នេះ យើងមិនអាចនៅទីនេះបញ្ជាក់ថា ឯកសារនោះវាមិនមានតាមផ្លូវច្បាប់នោះទេ ។ ដូច្នេះហើយ យើងគួរតែស្តាប់ចម្លើយដែលចូលមកក្នុងអង្គជំនុំជម្រះសាលាដំបូងរបស់យើង ។ ហើយឱ្យជនជាប់ចោទឆ្លើយតបទៅនឹងសាក្សីទាំងអស់នោះ ហើយដរាបណាដែលឯកសារមិនដាក់ចូលទៅក្នុងសំណុំរឿង គឺយើងត្រូវពិចារណា ។ ប៉ុន្តែ ខ្ញុំសូមអរគុណចំពោះការចង់ផ្តល់ឱ្យជនជាប់ចោទធ្វើការផ្តល់ជំហរ ប៉ុន្តែវាជាករណីផ្សេង ប្រសិនបើវាជាឯកសាររបស់តុលាការនៅក្នុងសំណុំ ហើយវាក៏ដូចទៅនឹងឯកសារទាក់ទងទៅនឹងរូបភាព រូបវីដេអូផងដែរ ។

**លោក រ៉ូប៊ីត ពើទីត៖**

យើងមានការពិភាក្សាច្រើនដងហើយ យើងឃើញធាតុផ្សំឯកសារមួយចំនួនដែលមិនមាននៅក្នុងសំណុំរឿង ហើយវាជាលក្ខណៈមួយច្បាស់ហើយ និងគោលបំណងនៃការដេញដោលនៅទីនេះ គឺយើងបង្កើត និងស្វែងរកការពិត និងអ្វីដែលមិនពិត នេះជាអ្វីដែលយើងគិតថា ជាអង្គហេតុ ។ ហើយយើងធ្វើការសន្និដ្ឋាននៅទីនេះ ។

[១១:៥៨:០៧]

ជាការពិតណាស់យើងនឹងត្រូវពិចារណាទៅលើអង្គច្បាប់ ដែលវាពាក់ព័ន្ធនៅក្នុងវិធីមួយចំនួន ។ ហើយយើងគឺថា បញ្ហាច្បាប់យើងធ្វើការពិចារណានៅក្នុងវិធីខុសៗគ្នា ហើយគោលបំណងនេះនៅចំពោះមុខចៅក្រម យើងមិនធ្វើការស្ទាក់ស្ទើរក្នុងការពិនិត្យទៅលើភស្តុតាងនិងឯកសារទេ ហើយយើងមិនស្ទាក់ស្ទើរក្នុងការចេញសេចក្តីសម្រេចនោះទេ ។ ហើយប៉ុន្តែ ខ្ញុំអត់មានបញ្ហាចោទទៅលើធាតុផ្សំផ្សេងៗដែលបានលើកឡើងនោះទេ ។ ប៉ុន្តែ ខ្ញុំទុកឱ្យលោក លោកស្រី ធ្វើការសម្រេចទៅលើបញ្ហាហ្នឹង ។

*[ចៅក្រមពិភាក្សាគ្នាពី ១១:៥៩:១៨ដល់ ១២:០១:០៩ នាទី ]*

**ប្រធានអង្គជំនុំ៖**

កន្លងមកនេះ យើងបានស្តាប់នូវការលើកឡើងកត់សម្គាល់ ទាក់ទិនជាមួយនឹងឯកសាររវាងមេធាវីការពារនិងសហព្រះរាជអាជ្ញា ។ តទៅនេះអង្គជម្រះក៏ចង់ដឹងអំពីទស្សនៈ អំពីមតិយោបល់របស់

មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរ អំពីឯកសារដែលលើកឡើងរវាងសហព្រះរាជអាជ្ញាជាមួយនឹងមេធាវីការពារនេះ តើខាងមេធាវីហ្នឹង មានយោបល់យ៉ាងម៉េច? ពីដំបូង គឺសុំអញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងជាក្រុមមួយ ។

សូមអញ្ជើញ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ យើងគាំទ្រទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាំងស្រុង ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សូមអរគុណលោកចៅក្រម ។ យើងសូមអនុញ្ញាតទាញជាការចាប់អារម្មណ៍ពីលោកចៅក្រម គឺថាភស្តុតាងទាំងអស់ គឺត្រូវបានទទួលយកពិនិត្យចំពោះអង្គជំនុំជម្រះ លើកលែងតែច្បាប់មិនអនុញ្ញាត។ នៅក្នុងន័យនេះ ខ្ញុំសូមអនុញ្ញាតបញ្ជាក់ជូនថា ខ្ញុំក៏ៗបានកំណត់នូវភាពខុសគ្នារវាងអត្ថបទភាសាអង់គ្លេស ហើយនឹងភាសាបារាំង ។ ដូច្នេះហើយខ្ញុំសូមស្នើថា សូមឲ្យអង្គជំនុំជម្រះមេត្តាពិនិត្យ ហើយនឹងអានផ្នែកខ្លះនៅក្នុងឯកសារភស្តុតាងនេះ ហើយសូមអានជាភាសាខ្មែរ ដើម្បីឲ្យមានការបកប្រែនៅក្នុងសាលសវនាការ ។ ដូច្នេះហើយយើងមានខ្លឹមសារដែលអានមក គឺដូចគ្នា ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងឲ្យដើមបណ្តឹងក្រុមបី ។

[១២:០៣:២៩]

**លោក ហ្វីលីព កាណុន៖**

សូមអរគុណលោកប្រធាន។ ក្រុមបីគឺថា អ្វីដែលយើងរកមើលក្នុងសំណុំរឿងនេះ គឺថាយើងរកការពិត ដូច្នេះហើយវាសមស្របដើម្បីពិចារណាសំណុំរឿងទាំងស្រុង ។ ខ្ញុំសូមត្រឡប់ទៅការសង្កេតមួយដ៏ធំមួយរបស់ខ្ញុំ អំពីមតិរបស់លោក រ៉ូប៊ីត ពេទីត ដែលយើងនឹងវាយតម្លៃឯកសារទាំងអស់ ផ្អែកលើកមូលដ្ឋាននៃធាតុលក្ខណៈនៃឯកសារហ្នឹង ដោយសារជាឯកសារតុលាការ ឬក៏ឯកសារដែលមិនប្រមូលដោយតុលាការ ។ ភាគីទាំងអស់ គឺត្រូវប្រឈមមុខ ភាគីទាំងអស់គឺត្រូវមានលទ្ធភាពដើម្បី

សម្តែងនូវការសង្កេតរបស់ខ្លួន ។ ដូច្នេះហើយយើងចាត់ទុកថា ឯកសារទាំងអស់ ដែលយើងលើកមកទីនេះ គឺត្រូវបង្ហាញ ហើយពិនិត្យឲ្យបានទាំងស្រុង ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងឲ្យក្រុមប្ដូន ។

**លោក គង់ ពិសី៖**

សូមគោរពអង្គជំនុំជម្រះ ខ្ញុំបាទឈ្មោះ គង់ ពិសី នៅក្នុងក្រុមប្ដូន ។ លោក ហុង គឹមសួន គាត់ឈឺ ហើយលោក ព្យែរអូលីយេស្សូរ គាត់អត់បានអញ្ជើញមកទេ ហើយខ្ញុំនៅក្នុងក្រុមហ្នឹងដែរ ។ ហើយខ្ញុំសូមធ្វើការចាប់អារម្មណ៍បន្តិច គឺថានៅក្នុងសំណុំឯកសារហ្នឹង គឺច្រើនមានសំណុំឯកសារជាភាសាខ្មែរ ។ ហើយអ៊ីចឹង ខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាយក គឺជាភាសាខ្មែរហ្នឹងយកមកពិនិត្យមើល ។ ហើយមិនអាចថាច្រានចោលថា ឯកសារហ្នឹងធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលអី មិនអាចយកជាការបានទេ ពីព្រោះថាកាលណាឯកសារទាំងអស់ហ្នឹងដាក់ចូលទៅក្នុងសំណុំរឿង ហើយចៅក្រមស៊ើបអង្កេត គាត់ទទួលយកនៅក្នុងសំណុំរឿងហើយ ។ ឯកសារហ្នឹង ត្រូវជាឯកសាររបស់ចៅក្រមស៊ើបអង្កេតហើយ អ៊ីចឹងភារកិច្ចរបស់មេធាវីការពារហ្នឹង គាត់ត្រូវតែមានតួនាទីពិនិត្យសំណុំរឿងតាំងពីដើមមក តើឯកសារហ្នឹងនៅចៅក្រមអង្កេតហ្នឹង ជាឯកសារដែលប្រមូលយកមកមិនបានទេ ត្រូវតែច្រានចោលនៅដំណាក់កាលចៅក្រមអង្កេតឲ្យហើយទៅ ។ ហើយនៅពេលដែលបញ្ជូនមក យកមកហើយចៅក្រមជំនុំជម្រះនេះហើយ គឺថាអាហ្នឹងវាជាឯកសារមួយយល់ព្រមទាំងគ្នាថាជាឯកសាររបស់ចៅក្រមស៊ើបអង្កេតហើយ ។ អ៊ីចឹងសូមឲ្យអង្គជំនុំជម្រះមេត្តាយកឯកសារនេះ ជាភាសាខ្មែរ មកពិចារណា ។ សូមអរគុណ ។

[១២:០៥:៥៧]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលត្រូវសម្រាកពិសារអាហារថ្ងៃត្រង់ហើយ ។ អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសផ្អាកសវនាការ ដើម្បីពិសារអាហារថ្ងៃត្រង់ រហូតដល់ម៉ោងមួយ និងសាមសិបនាទីរសៀលអញ្ជើញចូលវិញ ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រងចាំ ហើយឲ្យនាំគាត់ត្រឡប់មកសាលសវនាការវិញឲ្យបានមុនម៉ោងមួយនិងសាមសិបនាទីរសៀលនេះ ។ ចំណែកឯអ្នកដែលចូលរួម

និងសាធារណជនក៏ដូចគ្នាដែរ សូមអញ្ជើញចូលឲ្យបានមុនម៉ោងដប់មួយនិងសាមសិបនាទី-- ម៉ោងមួយនិងសាមសិបនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ ។

*[សវនាការសម្រាកនៅម៉ោង ១២:០៧នាទី ដល់ម៉ោង ១៣:៣៥នាទី]*

**ប្រធានអង្គជំនុំ៖**

អង្គជម្រះប្រកាសបន្តដំណើរការកិច្ចនីតិវិធីសវនាការតទៅទៀត ហើយជាកិច្ចបន្តនេះអង្គជម្រះសូមប្រគល់វេទិកានេះទៅចៅក្រម ហ្សង់ម៉ាក ដើម្បីដំណើរការបន្ត ។ សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាកឡាវែន៖**

ជាដំបូងខ្ញុំសូមឲ្យមានការបំភ្លឺ ។ នៅពេលនេះអង្គជំនុំជម្រះមិនមានបំណងធ្វើការបន្តការអានចម្លើយសាក្សីដែលចងក្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដែលវាពាក់ព័ន្ធទៅនឹង អ៊ឹម វន ហើយយើងនឹងចេញសេចក្តីសម្រេចក្រោយមកទៀតនៅពេលក្រោយ ទាក់ទងទៅនឹងឯកសារនេះ ។

នៅពេលនេះអង្គជំនុំជម្រះ សូមមិនឲ្យភាគីយោងទៅលើឯកសារនេះទេ ។

នៅពេលនេះខ្ញុំសូមសួរសំណួរមួយចំនួនទៅជនជាប់ចោទ ពាក់ព័ន្ធទៅនឹងការដួលរលំ ឬការបញ្ចប់នៃម-១៣ ។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ នៅពេលណាដែលគេបានសម្រេចបិទម-១៣? ថាតើមានវិធានការអ្វីបានអនុវត្តឡើង ហើយនៅពេលដែលបិទម-១៣?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំនៅតែរក្សាសេចក្តីដែលខ្ញុំបានរាយការណ៍ជូនលោកចៅក្រមស៊ើបអង្កេតរួចហើយ គឺថ្ងៃ០១ មករា ១៩៧៥ មេខ្ញុំជាប់រវល់វ៉ៃសម្រុកផ្តាច់ព្រែក ។ ដូច្នេះ ម-១៣ នៅចោលទទេគ្មានមេទេ ជនរងគ្រោះដែលទៅជាប់ទោសទាំងប៉ុន្មាននាក់ ខ្ញុំសួរចម្លើយបង្ហើយទុកនៅទីនោះមិនទាន់ប៉ានធ្វើអីទេ ។

ដល់ថ្ងៃ១៧ មេសា ខ្ញុំដឹងជ័យជម្នះនេះតាមវិទ្យុ ខ្ញុំរង់ចាំរហូតដល់ថ្ងៃ៣០ មេសា ទើបឃើញនិរសាររបស់មេខ្ញុំ ទៅហៅខ្ញុំយកមកធ្វើការជាមួយ គឺលោកគ្រូ សុន សេន គាត់ឲ្យគេទៅហៅខ្ញុំយកមក

ធ្វើការជាមួយ ។ មកដល់គាត់ឲ្យខ្ញុំរាយការណ៍ នៅមន្ទីរ ១៣ “ក” នៅសល់មនុស្សប៉ុន្មាននាក់ គាត់ឲ្យរាប់ឈ្មោះ ដល់ហើយគាត់បែងចែក ថាប៉ុណ្ណោះនាក់មិត្តឯងឲ្យគេកម្ទេចទៅ ។ ប៉ុណ្ណោះនាក់ទៀត មិត្តឯងឲ្យគេបញ្ជូនទៅមន្ទីរគរបាលតំបន់៣២ ទៅ ។ ខ្ញុំពេលហ្នឹងទាមទារស្នើសុំគាត់សុំដោះលែងជា ហម អ៊ីន មួយជាស្លាពរ តែគាត់មិនព្រម ។ ខ្ញុំក៏ត្រូវតែអនុវត្តតាមបញ្ជា បញ្ជូន ហម អ៊ីន ទៅមន្ទីរនគរបាលតំបន់៣២ ទៅ ។

ដូច្នេះមន្ទីរម-១៣ ក៏វាចប់នៅថ្ងៃ៣០ មេសា ១៩៧៥ ចំណែកមន្ទីរ១៣ “ខ” ក៏វាចប់នៅថ្ងៃ៣០ មេសា ១៩៧៥ ដែរដោយគាត់បញ្ជាឲ្យខ្ញុំចាត់ចែងឲ្យដោះលែងជនរងគ្រោះដែលទុកអប់រំនៅទីនោះទាំងអស់ ។ ក៏ប៉ុន្តែបុគ្គលិករបស់មន្ទីរ ១៣ “ក” គាត់ឲ្យខ្ញុំយកមកភ្នំពេញទាំងអស់ ។ គាត់មិនទាន់សម្រេចថាយកមកភ្នំពេញទេ គាត់ថាឲ្យទុកនៅជាមួយមិត្តសិន ចាំទទួលបញ្ជាជាក្រោយ ។ ឯចំណែកបុគ្គលិកមន្ទីរ១៣ “ខ” ទាំងប៉ុន្មាន គាត់ឲ្យយកតែមិត្ត ស៊ុំ មួយទេមកជាមួយខ្ញុំ អនុប្រធានខ្ញុំនោះ ។ ឯចំណែកក្រៅពីនោះឲ្យប្រគល់ទៅខាងមូលដ្ឋានគេចាត់ចែង ។ ជាបុគ្គលិករបស់អង្គការមូលដ្ឋាន ។ ដូច្នេះ មន្ទីរ ១៣ “ក” វាបិទត្រឹមហ្នឹង ហើយនឹង “ខ” វាបិទត្រឹមហ្នឹង បិទត្រឹមថ្ងៃ៣០ ខែមេសា ១៩៧៥ ។ ពេលហ្នឹងមេខ្ញុំឲ្យម៉ូតូថ្មីមួយ ប៉ុន្តែមិនមែនបាន *សេអិល-៩០* ទេ គាត់ឲ្យខ្ញុំទៅជ្រើសរើស ខ្ញុំជ្រើសរើសយកម៉ាក *យ៉ាម៉ាហា-៨០* ហើយចប់ ។

[១៣:៤០:០៨]

**ចៅក្រម ហ្សង់ម៉ាកឡាវែន៍៖**

អ្វីដែលខ្ញុំស្នើឡើង គឺថាចម្លើយរបស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត យើងនឹងអាន ។ ហើយលោកបានជម្រាបថា ថាលោកបញ្ជាក់ចំពោះឯកសារហ្នឹងដែរឬទេ? ខ្ញុំយោងទៅលើឯកសារ D.៧០ នៅក្នុងឯកសារទំព័រទីបី ភាសាបារាំង ដែលមានលេខ ERN០០១៨៥៤៨២ ជាភាសាបារាំង ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមឲ្យអស់លោក លោក លោកស្រីផ្តល់អាចផ្តល់លេខ ERN ជាភាសាខ្មែរ និងអង់គ្លេសបានដែរឬទេ?

**ជនជាប់ចោទ (និយាយភាសាបារាំង)៖**

អង់ខ្មែរ ERN ១៨៥ ។ ៤៧៦ នៅទំព័រទីបី នៃឯកសារD.៧០ គឺលេខ ERN ០០១៨៥៥៤៧៦ ទំព័រលេខបី ។

**ចៅក្រម ហ្សង់ម៉ាកឡាវែន៍៖**

ចុះចំណែក ERN ភាសាអង់គ្លេសវិញ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ៖**

គឺឯកសារអង់គ្លេសមានលេខ ERN ០០១៨៥៥៤៧៣ គឺនៅទំព័រដំបូង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំនឹងអានភាសាបារាំង ។ ដូច្នេះ ខ្ញុំសង្ឃឹមថាអត់មានបញ្ហាជាភាសាទាក់ទងនឹងការបកប្រែទេ ។

[១៣:៤២:៤៥]

*លោកបានលើកឡើងថា ខ្ញុំជាប្រធានម-១៣ ខែកក្កដា ចាប់ពីខែកក្កដា ឆ្នាំ៧០ ដល់៧៥ ហើយគឺនៅ-- ក្រៅពីនេះ គឺខ្ញុំរក្សាសិទ្ធិនៅស្មៀម ។*

*សំណួរ៖ លោកយោងថ្ងៃទី០១ ខែមករា ហើយលោកលើកឡើងថា លោកបានធ្វើការពីឆ្នាំ៧៥ ហើយលោកបានលើកឡើងថាគឺវាបន្តពីពេលនោះមកមន្ទីរ គឺមន្ទីរនេះ ។*

*លោកបានឆ្លើយថា៖ អ៊ឹម-១៣ គឺមិនកើតចេញពីថ្ងៃ០១ ខែមករា ៧៥ ទេ គឺអត់មានការសួរចម្លើយ ការកម្ទេច ឬក៏ការមកដល់របស់អ្នកទោសនោះទេ គឺអ្នកទោសរក្សាទុករហូតដល់ថ្ងៃ៣០ ខែមេសា ដែលនៅថ្ងៃនោះ សុន សេន មានការដោះលែងអ្នកទោស ម-១៣ "ខ" ហើយអ្នកទោសនៅមន្ទីរ ម-១៣ "ក" បញ្ជូនទៅតំបន់មួយ ហើយបានសម្លាប់ ។ ហើយនៅពេលនោះគឺខ្ញុំអត់មានការងារធ្វើទេ ហើយខ្ញុំគឺជិះម៉ូតូទៅកន្លែងផ្សេងៗ ហើយខ្ញុំលើកឡើងថា នៅពេលនោះគឺខ្ញុំរងចាំចម្លើយឆ្លើយតបថាបញ្ជូនខ្ញុំទៅក្រសួងឧស្សាហ៍កម្ម ហើយចម្លើយនោះអត់មានការឆ្លើយតប ។ ហើយគឺខ្ញុំសូមការអនុញ្ញាតពីអង្គការទាក់ទងទៅនឹងខ្ញុំ និងប្រពន្ធរបស់ខ្ញុំទាក់ទងនឹងការរៀបការ ហើយអង្គការបានយល់ព្រម ។*

*ហើយដោយសារខ្ញុំអត់មានការងារធ្វើ គឺប្រពន្ធរបស់ខ្ញុំមានការភ័យខ្លាចដោយថា មានការចាប់ខ្លួនខ្ញុំដោយសារខ្ញុំជា បញ្ញវន្ត ហើយនាងគឺភ័យខ្លួនដោយសារតែខ្លាចនាងនៅមេម៉ាយ ហើយក៏មានខ្លាចការចាប់ខ្លួននេះផងដែរ ។*

*នៅថ្ងៃទី២១ ខែកក្កដា លោកបានធ្វើការវគ្គសិក្សា ហើយនៅថ្ងៃទី១៥ ខែសីហា ក្រោយមកលោកបាននិយាយអំពីតួនាទីរបស់លោកនៅក្នុងការធ្វើទារុណកម្ម គឺតើលោកបញ្ជាក់យ៉ាងម៉េចដែរ?*

*ហើយនៅថ្ងៃទី៣០ ខែមេសា ថាតើមានអ្នកទោសប៉ុន្មាននៅក្នុងម-១៣? ហើយមានប៉ុន្មានសម្លាប់? ហើយតើមានការរៀបចំបញ្ជូនយ៉ាងម៉េច? ហើយលោកបានចូលរួមដែរឬទេក្នុងការអំពើទាំងអស់នោះ ?*

*[១៣:៤៥:៣៥]*

*ចម្លើយ គឺមានអ្នកទោសតិចតែប៉ុណ្ណោះ គឺមានតែប្រាំ ទៅ ដប់ នៅ ម-១៣ "ខ" ហើយមានមួយចំនួននៅ ម-១៣ "ខ" ទាក់ទងទៅនឹងចំនួនពិតប្រាកដដែលត្រូវបានកម្ទេច និងបញ្ជូនទៅតំបន់៣២ គឺខ្ញុំបានភ្លេច ហើយចាំថា ខ្ញុំសុំឲ្យមានការដោះលែង ហាម អ៊ឹម ។ ប៉ុន្តែ សុន សេន បានបដិសេធ ។ ហើយបញ្ជាឲ្យបញ្ជូនទៅតំបន់៣២ គឺខ្ញុំមិនបានធ្វើការចូលរួមក្នុងការសម្លាប់ទេ ខ្ញុំផ្តល់ការងារហ្នឹងទៅ ប្រាជ្ញ មាស ហើយរៀងរាល់ថ្ងៃ គឺខ្ញុំឃើញលក្ខខណ្ឌរបស់អ្នកទោសនៅ ម-១៣ ហើយចំណុចនេះហើយដែលខ្ញុំព្យាយាម មិនមើលក្ខខណ្ឌអ្នកឃុំ អ្នកជាប់ទោសនៅតំបន់៣២ ។*

*ប្រាជ្ញ មាស គឺគាត់មើលទៅលើលក្ខខណ្ឌ ហើយនឹងការសម្លាប់នៅ ម-១៣(ក) ហើយ ប៉ុន គឺទទួលខុសត្រូវលើការសួចម្លើយ ហើយចំពោះ ម-១៣ "ខ" ហ៊ូ គឹមអេង ហៅ ស៊ុំ គឺជាប្រធាន ។ ហើយចំពោះខ្ញុំ ខ្ញុំគ្រប់គ្រងរួមទាំងអស់ ។*

**ស៖** ថាតើលោកបញ្ជាក់នូវ អ្វីដែលខ្ញុំបានលើកឡើងដែរឬទេ ? ឬក៏លោកចង់លើកយោបល់ណាមួយទាក់ទងទៅនឹងបញ្ហានេះ ?

**ឆ៖** លោកចៅក្រមជាទីគោរព ! ខ្ញុំឆ្លើយជូនលោកចៅក្រមស៊ើបអង្កេតចេញមកពីដួងចិត្ត ដែលចង់សម្តែងការពិតតែប៉ុណ្ណោះឯង ដូច្នេះគ្មានអីខុសទេ ។ ខ្ញុំគ្រាន់តែសូមបញ្ជាក់បន្តិច ពីររឿងប្រហែលជាខ្ញុំចាំច្រឡំ គឺថ្ងៃ២០ កក្កដា ខ្ញុំបានប្រកាសថា ខ្ញុំបានទទួលសំបុត្រឲ្យមកភ្នំពេញមករៀន ។ ក៏ប៉ុន្តែដល់ ឃើញឯកសារមួយរបស់ KW*០៨* សរសេរថាថ្ងៃរៀន គឺនៅថ្ងៃ២៣ ខែ៦ ។ ដូច្នេះ ប្រហែលជាខ្ញុំច្រឡំខែ ក៏ប៉ុន្តែថ្ងៃ២០ ដូចគ្នា ។ ដូច្នេះ ប្រហែលជាខ្ញុំត្រូវមេហៅមកភ្នំពេញនៅថ្ងៃ២០ ខែមិថុនា ១៩៧៥ ទៅវិញទេ មិនមែនថ្ងៃ២០ កក្កដា ១៩៧៥ ទេ ។ ដូច្នេះ អាចច្រឡំត្រង់ ហ្នឹង ច្រឡំមកពីគំនិតខ្ញុំចាំវាអត់ច្បាស់ទេ ។

នេះសូមជម្រាបបញ្ជាក់ឡើងវិញ សេចក្តីរាយការណ៍ទាំង ប៉ុន្មានរបស់ខ្ញុំ ខ្ញុំទទួល គឺខ្ញុំរាយការណ៍ចេញពីដួងចិត្តរបស់ខ្ញុំដើម្បីសម្តែងការពិតជូនតុលាការ ។

[១៣:៤៨:៤១]

**ស៖** ដូច្នេះលោកបញ្ជាក់ថា លោកចំណាយពេលរបស់លោកបន្ទាប់ពីម-១៣ បិទនេះ គឺថា

លោកជិះ ម៉ូតូទៅកន្លែងផ្សេងៗ ?

**ឆ៖** គឺខ្ញុំមិនដើរទៅណាទេ គឺខ្ញុំចេញពី ម-១៣ "ក" មកកន្លែងរបស់ សឺន វិសុទ្ធ ហៅ កន ហើយឬក៏ ខឹម ផូ ហៅ កែវ ដែលជាលេខាស្រុក ហើយ សឺន វិសុទ្ធ ហៅ កន នេះជាប្អូនរបស់មេខ្ញុំ ប្អូនរបស់ សុន សេន នេះដើម្បីរង់ចាំដំណឹងខាងលើហៅ ។

សូមបញ្ជាក់ជូនលោកចៅក្រមម្តងទៀត ខ្ញុំនិយាយលឿនពេក សូមទោស ។ កាលដែលខ្ញុំបាន ម៉ូតូហើយ ខ្ញុំរាយការណ៍ជូនលោកចៅក្រមស៊ើបអង្កេតថា ខ្ញុំដើរលេង ពិត ក៏ប៉ុន្តែដើរលេងនេះអត់ទៅណាទេ ។ ទិសដៅដែលខ្ញុំដើរមានពីរ ។ ទីមួយ គឺទៅកន្លែងរបស់ សឺន វិសុទ្ធ ហៅ នាយ កន ប្អូន សុន សេន នេះ ។ ហើយទីពីរ ទៅកន្លែង ខឹម ផូ ហៅ កែវ លេខស្រុកពញាឮ នេះដើម្បីរង់ចាំដំណឹងក្រែងអង្គការហៅមកភ្នំពេញ ប៉ុណ្ណឹងឯង ។

[១៣:៥០:២៥]

**ស៖** មុនពេលហ្នឹង ថាតើលោកត្រូវបានគេប្រាប់អំពីការយល់ឃើញថា ប្តូរលោកពីទៅភ្នំពេញដែរឬទេ? តើគេប្រាប់លោក ត្រូវបានគេប្រាប់ថា នឹងមានតួនាទី និងត្រូវបានទទួលពីអង្គការបន្ទាប់មកទៀត ដែរឬទេ?

**ឆ៖** ខ្ញុំបែកពីមេទៅ មេអត់មានប្រាប់អីមួយម៉ាត់ទេ ថ្ងៃ១ មករា នេះបែកគ្នារហូត ។ ដល់ថ្ងៃ ៣០ មករា គាត់ចាត់ចែងអីចឹង ហើយគាត់ឲ្យម៉ូតូមួយ ។ គាត់ណាត់ គាត់ប្រាប់ខ្ញុំថា នៅរង់ចាំ ។ ដូច្នេះ ការងារទៅថ្ងៃមុខយ៉ាងម៉េច អត់ដឹងទេ អត់មានដឹងសោះ ។ អីចឹងហើយបានជាខ្ញុំនៅរង់ចាំ ។ ហើយ សូមបញ្ជាក់ជូនលោកចៅក្រមថា នៅពេលនោះ ភូមិភាគពិសេសគេមកភ្នំពេញអស់រលីង ។ ខាងមន្ទីរពេទ្យគេយកមកពេទ្យអស់ ។ ឯចំណែកខាងតំបន់១៥ គេមកជាមួយនឹង ចេង អន អស់រលីងធ្វើឲ្យខ្ញុំខ្វាក ចង់មកខាង ឧស្សាហកម្មនឹងគេ ។ ដូច្នេះ ខ្ញុំអត់មានដឹងមុន ថាខ្ញុំត្រូវទៅណាមកណាទេ គឺនៅរង់ចាំសេចក្តីសម្រេចរបស់ខាងលើសុទ្ធសាធតែម្តង ។

[១៣:៥១:៤៩]

**ស៖** សំណួរចុងក្រោយ ថាតើមានការត្រឡប់ទៅវិញដែរឬទេ នៅក្នុងឆ្នាំ៧៩ ?

**ឆ៖** នៅពេលដែលខ្ញុំរត់ទៅទៅនេះ ទៅស្នាក់នៅនឹងភូមិរបស់ប្រពន្ធខ្ញុំនៅខាង ហុងត្នោត ឃុំពាម ប៉ុន្មានថ្ងៃទេ យូរដែរប្រហែលកន្លះខែ មួយខែ បានខ្ញុំទៅដល់កន្លែងចាស់របស់ខ្ញុំ គឺមន្ទីរ-១៣"ក" តានឹង ទីតាំងហ្នឹងតែម្តង ជ្រកបណ្តោះអាសន្ន ។ នេះពិត ។

**សះ** ថាតើមានអ្វីគួរឲ្យកត់សម្គាល់កើតឡើងដែរឬទេនៅពេលដែលលោកត្រឡប់ទៅម-១៣“ក”?

**ឆះ** ពេលហ្នុង ខ្ញុំអត់មានធ្វើអីទេ គឺបានសុំអនុញ្ញាតខាងបង ប៉ាល់ អនុលេខាតំបន់ អនុលេខាភូមិភាគបស្ចិមថ្មីដើម្បីសុំដីជ្រកកោន ។ សុំបាយហូបផង ។

[១៣:៥៣:៣០]

**សួរដោយប្រធានអង្គជំនុំះ**

អស់លោក លោកស្រីចៅក្រម ឯទៀតមានសំណួរអីត្រូវសួរដល់ជនជាប់ចោទរូបនេះទេ? ពាក់ព័ន្ធជាមួយនឹងអង្គហេតុមន្ទីរសន្តិសុខ ម-១៣ នេះ ។ បើមានសូមអញ្ជើញ ។

**សះ** លោក កាំង ហ្កេកអ៊ាវ យើងចង់ដឹងបញ្ហាមួយចំនួនពាក់ព័ន្ធជាមួយនឹងមន្ទីរ ម-១៣ ហ្នឹងឲ្យបានច្បាស់ ។ ទីមួយ លោកបញ្ជាក់ឡើងវិញអំពីរបៀបនៃការសួរចម្លើយដែលលោកអនុវត្ត និងបញ្ជាអនុវត្ត នៅមន្ទីរសន្តិសុខ ម-១៣ ហ្នឹងមានប៉ុន្មានរបៀប ? ហើយរបៀបអ្វីខ្លះ ?

**ឆះ** ការសួចម្លើយនៅមន្ទីរសន្តិសុខម-១៣ នេះដូចខ្ញុំបានរាយការណ៍ជូនលោកចៅក្រម ឡាវែន់ព្រឹក មិញហើយ ជនណាដែលខ្ញុំចាប់អារម្មណ៍ថា ត្រូវដោះលែងខ្ញុំសួរដោយផ្ទាល់ខ្លួន ហើយសួរដោយគ្មានទារុណកម្មទេ ។ ចំណែកអ្នកណាដែលខ្ញុំគិតថា ដូចមិនអាចសុំធានាដោះលែងបាន អាហ្នឹងខ្ញុំអាចប្រគល់ទៅឲ្យគេចាប់ផ្តើមសួរ ឬក៏ខ្ញុំចាប់ផ្តើមសួរដំបូងទៅ ហើយមកប្រគល់ទៅឲ្យគេចាប់ផ្តើមសួរ ។ ដូច្នេះ រវាងទារុណកម្ម និងមិនទារុណកម្មឆ្លាស់គ្នា ។ យើងខ្ញុំអាចឆ្លើយបានមួយម៉ាត់ថា ក្រៅពីអ្នកដែលយើងខ្ញុំមានបំណងដោះលែង វិធីសួរ គឺមានតែមួយបែបទេ គឺសួរអង្អៀមឆ្លាស់គ្នា រវាងសួរស្លូត និងសួរក្តៅ ប្រឹងប្រែងជាប់ជាបន្តបន្ទាប់ ។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

[១៣:៥៥:៥១]

**សះ** លោកអាចប្រាប់ដល់អង្គសវនាការបានទេ អំពីរូបភាពនៃទារុណកម្មដែលលោកធ្លាប់បានប្រើប្រាស់ ឬក៏បញ្ជាឲ្យប្រើប្រាស់អនុវត្តនៅក្នុងមន្ទីរសន្តិសុខម-១៣ ? ហើយរូបភាពនៃទណ្ឌកម្មហ្នឹងមានអីខ្លះទៅ?

**ឆះ** រូបភាពនៃទណ្ឌកម្ម ទារុណកម្មជាទូទៅ គឺវ៉ៃនឹងមែកឈើ មែកព្រៃនៅក្បែរ១ទ្នំង ហើយជាពិសេស គឺមានរូបភាពមួយទៀតនៅពេលដែលចង់សួរចម្លើយពីរឿងកាំភ្លើង ដូចខ្ញុំបានរាយការណ៍ព្រឹកមិញ ចងជនរងគ្រោះនៅនឹងបង្គោលឲ្យបែកពីគ្នា កុំឲ្យនិយាយគ្នាកើត ហើយឲ្យគេយាមការពារហ្មត់ចត់ កុំឲ្យជនរងគ្រោះនិយាយគ្នាបាន ។ ហើយមានម្តងនោះ ខ្ញុំសាកល្បងយកមនុស្សទៅឲ្យងូតទឹក

ហើយ ងើបឡើងហាលខ្យល់ត្រជាក់ដើម្បីឲ្យវាត្រជាក់ ។ ខ្ញុំសូមបន្ថែមបន្តិចចុះ រឿងនេះឲ្យវែងបន្តិចចូលដល់ ស-២១ ដោយសារយើងខ្ញុំទាំងពីរនាក់ធ្វើជាមួយមិត្ត ប៊ុន បានជាពេលសួរចម្លើយ វ៉ន វេត មិត្តប៊ុន នឹកដល់រឿងហ្នឹងស្រោចទឹកកក ហើយបើកកង្ហារដាក់ មិនៗប៉ិាននៃ ។

ដូច្នេះ និយាយសរុបមួយម៉ាត់មក ទារុណកម្មនៅម-១៣ មានតែរឿងវ៉ៃហ្នឹងឯងជាសំខាន់ ។ វ៉ៃនឹងស្អី? វ៉ៃនឹងរំពាត់ ។ ឯចំណែករឿងចន្លុះ វាមានទារុណកម្មម្តងដែលមិត្ត ប៊ុន គាត់ធ្វើនៅនឹងមុខខ្ញុំដោយសារមិត្ត ផល គាត់ប្រតិកម្មដោយ មិត្តមាស នេះជាវាករណីពិសេសទេ ។ នេះសូមបញ្ចប់ប៉ុណ្ណឹង ។

**ស៖** របៀបសួរចម្លើយក្តី របៀបវិធីធ្វើទារុណកម្មក្តីហ្នឹង តើលោកបានទទួលការបណ្តុះបណ្តាលពីមជ្ឈដ្ឋានណាដែរ? ឬមួយក៏លោកនឹកឃើញដោយខ្លួនឯង នៅពេលដែលលោកគ្រប់គ្រងនៅមន្ទីរសន្តិសុខ ម-១៣ នោះ?

**ឆ៖** បណ្តុះបណ្តាលឲ្យចំបញ្ហាទារុណកម្មនេះ ។ គ្មានទេ ។ ក៏ប៉ុន្តែ គ្រាន់តែសុំបញ្ជាក់ជូនលោកប្រធានថា ពេលដែលយើងខ្ញុំជាប់គុក ខ្ញុំឮទារុណកម្មដែលពួក *ប៉េ អេស* ធ្វើមកលើខ្មែរក្រហមកន្លែងខ្លះ យើងខ្ញុំធ្វើមិនកើតដែរ ។ ឧទាហរណ៍ដូចដាក់ក្រមាពីលើ ហើយចាក់ទឹក ខ្ញុំថាអ្ហ៎! រកក្រមាឯណាបាន ចាក់ទឹកយ៉ាងម៉េច ចងមនុស្សយ៉ាងម៉េច ស្អីម្តេចទេ ។ ដូច្នេះ ខ្ញុំធ្វើមិនបាន ។ ដូច្នេះមានតែវិធីមួយទេ គឺវ៉ៃ ។

[១៣:៥៩:០៨]

ឯចំណែកដូចខ្ញុំបានបញ្ជាក់ជូនចៅក្រម ឡាវែន៍ ព្រឹកមិញអ៊ីចឹង វ៉ន វេត គាត់ណែនាំឲ្យធ្វើទារុណកម្មមួយបែប ច្រកស្បោង ហើយឲ្យចប់ដង្ហើម ហើយសឹមដោះស្បោងនោះមកវិញ ។ ខ្ញុំថាធ្វើមិនកើតទេ រកស្បោងមិនបានទេដីរំដោះ ។ ហ្នឹងជាវិធីធ្វើទារុណកម្មមួយបែបទៀត ដែលខ្ញុំធ្វើមិនកើតដែរ ។ ដូច្នេះសរុបមកទារុណកម្មនេះ របៀបយើងខ្ញុំយកលំនាំតាមការដែលគេធ្វើនៅ *ប៉េ អេស* ដែលឧទាហរណ៍ដូចខ្ញុំបានលើកឧទាហរណ៍ជូនម្សិលមិញអ៊ីចឹង ពីរឿងអធិការនគរបាលជាតិឈ្មោះ ហ៊ុំ, ហំ ឬក៏ហ៊ុំទេ វ៉ៃមិត្ត ងួន ឃាង ឡើងជាំខ្មៅអស់រលីង ហ្នឹងគឺខ្ញុំមានលំនាំហ្នឹង ។

ដោយឡែកវិធីខ្លះដែល វ៉ន វេត គាត់ណែនាំខ្ញុំៗធ្វើតាមគាត់មិនកើតដែរ ។ គាត់ថាមិត្តឯងវិទ្យាសាស្ត្របន្តិច យួន វាវិទ្យាសាស្ត្រណាស់ ។ មិត្តឯងមើល បើអានេះ វាលោតខ្លាំង អាហ្នឹងមនុស្សមានខ្លួនហើយ មិត្តឯងវ៉ៃចុះ ។ ខ្ញុំធ្វើមិនកើតទេ ដូចមិនសូវពិតទេ អាមើលជីពចរហ្នឹង ។ ដូច្នេះ ការណែនាំពីលើមកស្លួចស្តើងណាស់ ។

រឿងទាំងអស់ជាទារុណកម្ម ជាទណ្ឌកម្ម ជាអីៗ គឺខ្ញុំប្រឌិតដោយគំនិតខ្លួនឯង ជាមូលដ្ឋាន ។ ដូចខ្ញុំបានរាយការជូនលោកចៅក្រម ឡាវែន៍ ម្សិលមិញ ខ្ញុំនិយាយថា ខ្ញុំអត់ដែលធ្វើប៉ូលីសទេ ។ បង ឆាយ គឹមហ៊ កាត់ថាមិត្ត ប្រទេសដទៃទៀត គេមិនបង្រៀនយើងទេវាពាក់ប៉ះពាល់ដល់ការសម្ងាត់ មិត្តដកពិសោធន៍ទៅ ។ ប្រជាជនអំពាវនាវឲ្យកុលបុត្ររបស់ខ្លួនឆ្លើយតប ឥឡូវមិត្តបំពេញភារកិច្ចនេះ ទៅដើម្បីរកការពារដីរំដោះ ការពារប្រជាជនយើង ។ ដូច្នេះ ខ្ញុំចេះតែខំធ្វើតាមទៅ ទោះបីជឿថា អាហ្នឹងវាអ៊ីចឹង ឬមិនជឿសំខាន់ គឺមិនជឿ ប៉ុន្តែយើងខ្ញុំត្រូវតែធ្វើតាមពិសោធន៍ ។

ដូច្នេះ សរុបមកអារបៀបធ្វើទារុណកម្ម ខាងលើណែនាំតិចតួចណាស់ ។ ក៏ប៉ុន្តែ យើងខ្ញុំដក ពិសោធន៍ដោយខ្លួនឯង ខុសត្រូវនៅលើខ្លួនឯង ឧក្រិដ្ឋកម្មហ្នឹង វាជារបស់ខ្លួនឯងហើយ ។

[១៤:០១:៣៣]

**ស៖** លោកអាចបញ្ជាក់ប្រាប់ដល់អង្គសវនាការបានទេ អំពីការបង្កើតឡើងនៅមន្ទីរម-១៣ មាន ពីរកម្រិត ។ កម្រិក "ក" ហើយនឹងកម្រិត "ខ" នេះ ។ តើនៅក្នុងពេលប្រតិបត្តិការតាំងពីដំបូងរហូត ដល់ពេលត្រូវបិតទ្វារនេះ មានការផ្ទេរជនរងគ្រោះពីម-១៣ "ក" ទៅកាន់មន្ទីរ ម-១៣ "ខ" ឬក៏ផ្ទុយពី នេះ បានន័យថាបញ្ជូនជនរងគ្រោះពី ម-១៣ "ខ" មកកាន់ ម-១៣ "ក" ដែរឬទេ? ហើយប្រសិនជាមាន មានប្រហែលប៉ុន្មាននាក់ទៅ?

**ឆ៖** សូមគោរពបញ្ជាក់ជូនលោកប្រធានថា ការផ្ទេរជនរងគ្រោះដែលទៅជាប់ទោសនៅម-១៣ "ក" ទៅ ម-១៣ "ខ" គ្មានទេ គ្មានសោះ ។ ព្រោះមន្ទីរ ១៣ "ខ" ត្រៀមសម្រាប់តែឃុំឃាំងប្រជាជន ខ្មែរណាដែលមានកំហុសមួយរយៈ ហើយដោះលែងទៅវិញ ។ ដល់គណៈតំបន់ចាប់អារម្មណ៍នឹងអ្នក ណាមួយនៅម-១៣ "ខ" ថាអាចមានពិរុទ្ធភាពជាខ្លាំង ទើបបានខាងគណៈតំបន់ស្នើទៅលើ ហើយគេ បញ្ជូនពីមន្ទីរ ម-១៣ "ខ" ទៅមន្ទីរ ម-១៣ "ក" អាហ្នឹងមាន ។ យូរៗឃើញមួយ-ពីរប៉ុណ្ណឹង ។ ខ្ញុំមិន ចាំអស់ទេ បើបញ្ជូនទី ម-១៣ "ខ" ទៅ ម-១៣ "ក" គ្មាន ។ សរុបមក បញ្ជូនពី ម-១៣ "ក" មក ម-១៣ "ខ" គ្មានៗទាល់តែសោះមួយជីវិតប្រតិបត្តិការ ។

**ស៖** ទាំងបច្ចេកទេសក្នុងការសួរចម្លើយ ទាំងវិធីសាស្ត្រនៅក្នុងការធ្វើទារុណកម្ម ដែលលោក បានអនុវត្តនឹងបញ្ហា អនុវត្តនៅមន្ទីរម-១៣ "ក" កន្លងមកហ្នឹង លោកបានយកមកប្រើប្រាស់នៅ ស-២១ ដែរឬទេ?

[១៤:០៣:៤៥]

**ឆ៖** លោកប្រធានជាទីគោរព! របៀបសួរចម្លើយ តាំងពីពេលដែលយើងខ្ញុំកាន់កាប់ជាប្រធាន ស-២១ យើងខ្ញុំណែនាំឱ្យគេសួរចម្លើយតាមការ ដែលយើងខ្ញុំចេះដឹងនៅពេលនោះ ។ នេះពិត ។ នៅពេលដែលយើងខ្ញុំនៅជាអនុប្រធាននៅឡើយ ណាត ដែលជាប្រធានរបស់ខ្ញុំបានចាត់តាំងឱ្យខ្ញុំបង្រៀន របៀបសួរដល់បុគ្គលសួរចម្លើយដែលមិនមែនជាពួកអតីតអ្នកសួរចម្លើយរបស់ម-១៣ គឺជាកម្មាភិបាលសួរចម្លើយរបស់៧០៣ នេះគឺយើងខ្ញុំបានបង្រៀនមែនពិត របៀបសួរ របៀបអីៗ ។

ឯចំណែករបៀបឃុំឃាំង របៀបកម្ទេច របៀបទទួល របៀបចាប់ គឺជាឯកទេសពិសេសរបស់មន្ទីរនគរបាលកងពល៧០៣ គឺជាភាគចំណែករបស់គេ ដែលគេយកមកដាក់ឱ្យម-១៣ ជាកេរដំណែលរបស់គេទុកនៅស-២១ គឺជាកេរដំណែលរបស់មន្ទីរនគរបាលកងពល៧០៣ គេយកមករួមចំណែកនៅស-២១ ។ ឯចំណែកយើងខ្ញុំរួមចំណែកខាងរបៀបសួរ ហើយនឹងធ្វើឯកសារ ហើយចារឯកសារ គឺជាភារកិច្ចផ្ដាច់មុខរបស់ខ្ញុំ ។

សរុបមកមានមួយចំនួនណាជារបស់កងពល៧០៣ គឺឃុំឃាំង គឺចាប់ គឺកម្ទេច វាជាកេរដំណែលរបស់កងពល៧០៣ ។ ឯចំណែករបៀបសួរ របៀបរាយការណ៍ឯកសារ គឺជាកេរដំណែលរបស់ម-១៣ ដែលយើងខ្ញុំ ខ្ញុំបាទផ្ទាល់ជាអ្នកនាំយកមកដាក់ ។

**ស៖** លោកបាន-- នៅក្នុងចម្លើយជាលាយលក្ខណ៍អក្សរ ដែលលោកបានសរសេរដោយខ្លួនឯងចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧ លោកបានអះអាងថា លោកបានដោះលែងមនុស្សចំនួន៨នាក់ ហើយព្រឹកមិញលោកបានកែសម្រួលនៅតួលេខនេះ ឡើងដប់នាក់ ។ នៅក្នុងនោះ គឺមានអ្នកកាសែតបរទេសម្នាក់ផងដែលត្រូវបានដោះលែង ។ លោកអាចជម្រាបប្រាប់ដល់អង្គសវនាការបានទេ អំពីអ្នកកាសែត ដែលជាជាតិបរទេសម្នាក់នោះដែលត្រូវបានដោះលែង ហើយមូលហេតុអីដែលត្រូវបានដោះលែងគាត់? ហើយមួយទៀតថាពេលដែលដោះលែងគាត់ហ្នឹង តើលោកមានបានផ្ញើនូវអ្វីជាមួយគាត់មកកាន់ទីក្រុង ភ្នំពេញដែរឬទេ?

[១៤:០៦:៣៤]

**ឆ៖** លោកប្រធានជាទីគោរព អ្នកកាសែតអី គាត់ហ្នឹងទៅជាប់នៅមន្ទីរ១៣ នេះ ក្នុងឋានៈគាត់ជាអ្នកស្រាវជ្រាវ ជាបុគ្គលិករបស់អភិរក្សអង្គរ ។ គាត់ទៅស្រាវជ្រាវសាស្ត្រាស្លឹករឹតនៅវត្តអូរត្រូវឈ្លបរបស់ភូមិភាគពិសេសចាប់បាន មិត្តរ៉ូម ចាប់បាន ហើយយកទៅ ។ ដល់បញ្ជូនទៅដល់មន្ទីរ១៣ យើងខ្ញុំមានការញាក់ផ្អើលដែរ ។ ក៏ប៉ុន្តែ រឿងរបស់អ្នកកាសែត-- សូមទោស រឿងរបស់អ្នក

អភិរក្សអង្គរ៣នាក់នេះ បារាំងម្នាក់ ខ្មែរ២នាក់នេះ វាជារឿងហួសសមត្ថភាពយើងខ្ញុំ ។ រឿងហួសសមត្ថភាពខ្ញុំបាទ ម្ល៉ោះហើយ ខ្ញុំបាទកុំតែជម្រាបមេៗខ្ញុំគឺ វ៉ន វេត ថាមនុស្សនេះដូចជាមិនមែន *សេអ៊ីអា* មិនមែន *សេអ៊ីអា* ទេ ។ គេជាអ្នកស្រាវជ្រាវពិតប្រាកដ ។ ដល់ខ្ញុំនិយាយអ៊ីចឹង មេខ្ញុំគាត់សើច គាត់ថា មិត្តឯងទៅខ្លាចណាបារាំង មិត្តឯងបក្ខជន ជនកុម្មុយនីស្ត ។ មិត្តឯងទៅខ្លាចអំណាចអា *សេអ៊ីអា* មិត្តឯងសួរទៅឥឡូវ ។ ខ្ញុំឆ្លើយទៅវិញ ខ្ញុំថា *"ហ្វាកុលលីយ៉េ ប៉ូស៊ីសីត"* (facultés psychiques) របស់ខ្ញុំវាអត់ដល់គេទេ ខ្ញុំមិនចេះសួរទេ ។ ឥឡូវមានតែឲ្យគេសរសេរជាកិច្ចសន្យា ហើយសេចក្ដីថ្លែងការណ៍របស់គេមកប៉ុណ្ណឹងឯង ។

ដូច្នេះអ្នកអភិរក្សអង្គររូបនេះ យើងខ្ញុំសួរបានប៉ុន្មានដងដែរ តាមការដែលយើងខ្ញុំតវ៉ាជាមួយនឹងសូមរាយការណ៍ជូនមេ ហើយនឹងសូមយោបល់មេ ។ ដល់ក្រោយមកយូរខែណាស់ ទើបបានខាងលើសម្រេចឲ្យដោះលែង ។ ថ្ងៃសម្រេចឲ្យដោះលែងហ្នឹង ខ្ញុំអត់ដឹងទៀត កំពុងតែនៅធ្វើការនៅមន្ទីរសុខៗ តាម៉ុក ផ្ទះគាត់នៅក្បែរកន្លែងខ្ញុំដែរ គាត់ឲ្យគេទៅហៅ នីរសាគាត់ទៅហៅខ្ញុំពីកន្លែងនោះមក ។ មកដល់គេថាមើល ឌុច មិត្តឯងកុំព្រម ខាងលើៗឲ្យដោះលែងអាបារាំងហ្នឹង មិត្តឯងតវ៉ា បន្តិចទៀតបងវន មកបងឯងតវ៉ាៗ កុំព្រមដោះលែង យើងកុំព្រមដោះលែងពីរនាក់ ។ ខ្ញុំអត់ប៉ានមាត់ទេ ។ ដល់បងម៉ុក គាត់ចូលទៅក្នុងផ្ទះគាត់ទៅ បន្តិច បងវន មកដល់ ។ បងវន គាត់សួរខ្ញុំ ឌុច មកធ្វើអី? ខ្ញុំថាតាម៉ុក គាត់ហៅមក បងម៉ុក គាត់ហៅមក រឿងមិនឲ្យខ្ញុំដោះលែងអាបារាំងហ្នឹង មកពីគាត់ថា *សេអ៊ីអា* ។ គាត់ថាអឺ! ដល់ចូលទៅ បងវន គាត់ចូលទៅ ខ្ញុំក៏ដើរតាមពីក្រោយបងវនទៅ បងម៉ុក កំពុងតែពិសាបាយ ។ ដល់ហើយបាយ គាត់នាំគ្នាទាំង៣នាក់ ខ្ញុំបងវន ហើយនឹងតាម៉ុកនេះទៅអង្គុយនៅផ្ទះមួយក្បែរនុ៎ង ក្បែរផ្ទះប្រពន្ធគាត់ហ្នឹង ។ ទៅដល់គាត់ចេចៗ បងអាបារាំហ្នឹង *សេអ៊ីអា* ខ្ញុំមិនចេះធ្វើនយោបាយម៉េចជាមួយនឹង*សេអ៊ីអា*ទេ ម៉េចថ្វីត្បិតតែខាងលើឲ្យយើងលែង តែយើងវាជាក់ស្ដែងជាង ។ ខ្ញុំឆ្ងល់ដែរ តាម៉ុក កំពុងតែចេចៗអ៊ីចឹង សម្រាប់តែបងវន ថាតែមួយម៉ាត់ទេ ថាវាមិនមែនជា*សេអ៊ីអា*ស្អីវាទេ ។ សម្រាប់តែតាម៉ុក ប្រែខ្វាក ឌុច លែងៗឲ្យមិត្តហុក ។

ហេតុទៅដល់បងវន គាត់មានប្រសាសន៍តែមួយម៉ាត់ហ្នឹង តាម៉ុក ប្រែខ្វាក ។ គាត់ថាមើល ឌុច លែងៗ ឲ្យមិត្តហុក ជប់លៀង ។ ហើយថ្ងៃនេះមិត្តឯងជូនទៅ ជូនដំណើរវាទៅ ហើយឲ្យ មិត្តហុក ជប់លៀង។

[១៤:១០:២៣]

ដូច្នេះ នៅពេលដែលជុបលេងហ្នឹងហើយ ដែលអចិន្ត្រៃយ៍ភូមិភាគមាន តាម៉ុក ជាមេធំប្រគល់ឯកសារមួយជាឯកសារចំហរបស់រណសិរ្សរួបរួមជាតិកម្ពុជាហ្នឹង ឈ្មោះហៅថាកម្មវិធីនយោបាយរបស់រណសិរ្សរួបរួមជាតិទៅឲ្យ ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដោយផ្ទាល់ដៃគាត់ ។ អ្នកអភិរក្សអង្គរហ្នឹង ដោយផ្ទាល់ដៃគាត់ ហើយនិងរូបថតឃោសនាការប៉ុន្មានសន្លឹកទេ? ដូចមានរូបថត ហ៊ូ យន់ ដូចជាអត់មានរូបថត ខៀវ សំផន អីទេ ខ្ញុំមិនបានមើលច្បាស់ ឲ្យអ្នកអភិរក្សអង្គរហ្នឹងចេញទៅ ឲ្យរួចតែបារាំង ទុកខ្មែរពីរនាក់នៅជាមួយនឹងខ្ញុំ ។ នេះគឺសូមបញ្ចប់ប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះខាងអង្គជំនុំជម្រះអស់សំណួរហើយ ដល់វេទិការភាគី ។ ជាដំបូងនេះសូមអញ្ជើញជូនវេទិការនេះទៅសហព្រះរាជអាជ្ញា ប្រសិនបើសហព្រះអាជ្ញាមានសំណួរអ្វី ចង់សួរដល់ជនជាប់ចោទសូមញ្ជើញ ។

**សួរដោយលោកស្រី ជា លាង៖**

សូមអរគុណលោកប្រធាន ហើយក៏សូមអរគុណខាងអង្គជំនុំជម្រះដែរ ដែលអនុញ្ញាតឲ្យភាគីខាងព្រះរាជអាជ្ញាមានសំណួរ ។ យើងមិនមានសំណួរអីច្រើនទេ ដោយសារយើងបានស្តាប់នូវការរៀបរាប់រយៈពេល២ថ្ងៃនេះ គឺថាច្រើនណាស់ហើយ ។ គ្រាន់តែមានពីរសំណួរតូចៗ ដែលក្រោយយើងបានស្តាប់ទៅ ពុំបានស្តាប់អ្វីដែលជនជាប់ចោទបានរ៉ាយរ៉ាប់ ។

សំណួរទី១ ដែលយើងចង់សួរនៅពេលនេះ គឺសហព្រះរាជអាជ្ញាមានបំណងចង់ដឹងអំពីចំនួនបុគ្គលិក ដែលធ្វើការនៅមន្ទីរម-១៣ ដែលរួមទាំងអស់ ទាំងអ្នកសួរចម្លើយ កងការពារ ឬក៏នីរសារពេទ្យ ឬក៏អ្នកដាំស្ល ប្រសិនបើមាន នេះជាសំណួរទី១ ។

ដោយឡែកសំណួរទីពីរ គឺទាក់ទងនឹងសំណួរដែលលោកចៅក្រម ឡាវែន៍ លើកពីព្រឹកម្តងហើយអម្បាញ់មិញនេះ ដែលលើកឡើងបញ្ជាក់ដោយលោកប្រធានម្តងទៀត ទាក់ទងនឹងអំពីប្រភេទនៃការសួរចម្លើយៗនេះ ជនជាប់ចោទក៏បានរៀបរាប់ ហើយនិងបានឆ្លើយអំពីថា ការសួរចម្លើយនេះ ដោយវិធីត្រជាក់ និងដោយវិធីអង្កៀម ។

**ស៖** ព្រះរាជអាជ្ញាចង់ដឹងថា ក្នុងករណីដែលអ្នកទោសគាត់ទទួលនូវទារុណកម្ម ដូចជាការសួរដោយអង្កៀម ឬក៏ដោយមធ្យោបាយត្រជាក់ល្បួងលោមហ្នឹងក៏ដោយ ហើយពុំទាន់ទទួលនូវការឆ្លើយសារភាព តើអនុវត្តវិធីអីតទៅទៀតចំពោះអ្នកទោសទាំងនោះ? ជាមួយគ្នាហ្នឹងដែរ ចង់សួរបញ្ជាក់នៅ

ដំណាក់កាលនៅម-១៣ ហ្នឹង តើក្នុងដំណាក់កាលនៃការសួរចម្លើយ តើជនជាប់ចោទមានបានប្រើអាវុធ ដើម្បី-- នៅពេលដំណើរការហ្នឹង ឬក៏មួយយ៉ាងម៉េចដែរ? អំពីពាក់ព័ន្ធនៃការប្រើប្រាស់នៅអាវុធនេះ ។

ដូច្នេះ ព្រះរាជអាជ្ញាមានបំណងចង់សួរនៅសំណួរពីរទៅលើជនជាប់ចោទ ។ សូមអរគុណ ។

[១៤:១៤:០៩]

**ជនជាប់ចោទ៖**

សូមទោសអ្នកស្រីព្រះរាជអាជ្ញា ខ្ញុំបាទសូមបញ្ជាក់បន្តិច អាវុធហ្នឹង អ្នកស្រីសំដៅអី អាវុធស ឬក៏អាវុធជាតិផ្ទុះ?

ខ្ញុំសូមសួរយោបល់ព្រះរាជអាជ្ញាបន្តិច អ្នកស្រីព្រះរាជអាជ្ញាដែលសួរខ្ញុំថា អ្នកឯងមានប្រើអាវុធទេ? ខ្ញុំចង់បញ្ជាក់ សូមអ្នកស្រីព្រះរាជអាជ្ញាបញ្ជាក់មក អាវុធអី អាវុធស ជាកាំបិត ជាដាវ ជាអីៗ ឬក៏អាវុធជាតិផ្ទុះ?

**ប្រធានអង្គជំនុំ៖**

លោកស្រីសហព្រះរាជអាជ្ញាអញ្ជើញ ។

**សួរដោយលោកស្រី ជា លាង៖**

ខ្ញុំសូមបំភ្លឺ អាវុធនេះចង់សំដៅទៅលើកាំភ្លើង មិនមែនចង់សំដៅទៅលើកាំបិតដាវនោះទេ ។

[១៤:១៥:00]

**ឆ៖** អង្គជំនុំជម្រះជាទីគោរព អ្នកស្រីព្រះរាជអាជ្ញាជាទីគោរព ។ ដំបូងខ្ញុំបាទសូមរាយការណ៍ជូនអំពីបុគ្គលិករបស់មន្ទីរ១៣ ។ មន្ទីរ១៣ របស់ខ្ញុំមានគ្នាតិចណាស់ ប្រហែលជាយ៉ាងច្រើន២០នាក់ ។ អ្នកដាំបាយមានម្នាក់ គឺប្រពន្ធ KW0៨ នេះ និងដាំបាយបុគ្គលិក ហើយនិងដាំបាយកម្មាភិបាល ។ ឯចំណែកដាំបាយឲ្យពួកនុ៎ង ខ្ញុំមិនចាំនឹងអ្នកណា ខ្ញុំចាត់តាំងអ្នកណា ខ្ញុំភ្លេចទៅហើយ ក៏ប៉ុន្តែគ្រាន់សូមជម្រាបថា បុគ្គលិកនៅម-១៣ "ក" មានចំនួនតិចក៏ពិតមែន តែយើងខ្ញុំបានជ្រើសរើសសម្រិតសម្រាំងហៅគេពីឃុំមក យកមកប្រើ មកចាត់តាំងភារកិច្ច ។ កាលណាឃើញដូចជា មិនអាចយោងយិតយើងខ្ញុំបាន ខ្ញុំបានឲ្យគេត្រឡប់ទៅភូមិវិញ ។ ដូច្នេះ នៅសល់ដែលយកមកភ្នំពេញមានតិចណាស់ ប្រហែលជាជាង១០ប៉ុណ្ណឹងទាំងក្មេង ទាំងចាស់ ទាំងអី ប្រហែលជា១៧ ខ្ញុំបាទនិយាយឲ្យយ៉ាងច្រើនទៅចុះ២០នាក់ ។ ក៏ប៉ុន្តែទោះបីតិចប៉ុណ្ណឹងក៏ដោយ ទោះបីយ៉ាងនេះក៏ដោយខ្ញុំមានបញ្ចេញទៅក្រៅក៏ដោយ ខ្ញុំស្គាល់

ទាំងអស់អ្នកណាជាបុគ្គលិករបស់ខ្ញុំ នៅម-១៣ "ក" អ្នកណាមិនមែនជាបុគ្គលិកខ្ញុំស្គាល់ ។ នេះសូមបញ្ជាក់ជូនអ្នកស្រីព្រះរាជអាជ្ញាប៉ុណ្ណេះ ។

[១៤:១៦:៣៨]

ឯចំណែករឿងសំណួរទី២ របស់អ្នកស្រី ថាឥឡូវបើអ្នកឯងប្រើវិធីត្រជាក់ហើយ និងវិធីអង្កៀមហើយមិនចេញ តើអ្នកឯងធ្វើម៉េច? ទុកចោលមួយរយៈត្រូវការសុំយោបល់ពីខាងលើ ឬក៏មនុស្សនោះមិនសំខាន់យើងខ្ញុំសម្រេចឲ្យយកទៅចេញៗ ។ ហើយសូមបញ្ជាក់ជូនអ្នកស្រីព្រះរាអាជ្ញាថា ចម្លើយទោះបីបានដោយវិធីបែបណាវាសុទ្ធតែមិនពិតទេ ។ វាប៉ះពាល់ដល់អាយុជីវិតមនុស្ស វាជាបទឧក្រិដ្ឋហើយ នេះជារឿងពិតយើងខ្ញុំអត់ដែលប្រកែកទេ ទោះបីជារូបភាពណាក៏ដោយ រូបភាពស្លូតក៏ដោយ រូបភាពកាចក៏ដោយ ។ រូបភាពស្លូតបើចង់ដោះលែង របៀបដូច ហាម អ៊ិន អ៊ីចឹង ។ រូបភាពស្លូតបើចង់ដោះលែងរបៀតដូច TC១ អ៊ីចឹង អាហ្នឹងយើងខ្ញុំដោះលែង ។ ឬរូបភាពស្លូតអ្នកស្រីព្រះរាជអាជ្ញាគង់ឃើញទេ ដូចជា KW៣0 ក៏ជារូបភាពស្លូតដែរ យើងខ្ញុំដោះលែង ។

ដូច្នេះ ដោះលែងគឺសុទ្ធតែរូបភាពស្លូត អត់មានដែលប៊ិានកាចទេ ។ យើងខ្ញុំ-- សូមទោស ផ្ទាល់ខ្លួនខ្ញុំបាទយល់ឃើញថា វៃគេមួយពឹកហើយ គេៗមិនល្អទេៗ ។ ដូច្នេះ អ្នកដែលដោះលែងសុទ្ធតែប្រើរូបភាពស្លូត ឯចំណែកអ្នកប្រើរូបភាពអង្កៀមកាចហើយយើងខ្ញុំមិនដែលបាន-- ខ្ញុំបាទមិនដែលដោះលែងទេ គឺសុទ្ធតែបង្ហើយចប់ ព្រោះគោលការណ៍គេសម្រេចឲ្យយើងខ្ញុំកម្ទេចរួចទៅហើយ ។ នេះសូមបញ្ចប់ប៉ុណ្ណេះ ។ នៅមានយោបល់យ៉ាងម៉េចទៀត សូមព្រះរាជអាជ្ញាលោកសួរមកទៀតចុះ ខ្ញុំឆ្លើយជូន ។

[១៤:១៨:៣២]

**លោកស្រី ជា លាង៖**

លោកប្រធានសូមអនុញ្ញាតបន្តបន្តិចទៀត ។ អម្បាញ់មិញហ្នឹង ដោយបានស្តាប់ទៅឃើញថាត្រូវបានយកចេញ ។

**ស៖** សំណួរនេះ សួរថា យកចេញហ្នឹង យកទៅយ៉ាងម៉េច? យកដោះលែង ឬក៏យកសម្លាប់? នេះជាសំណួរមួយដែលដោះលែង ។ ឥឡូវខ្ញុំសូមបន្តិចហ្នឹងសិនសឹមឆ្លងសំណួរមួយទៀត ។ ចាស សូមអរគុណ ។

**ឆ៖** សូមបញ្ជាក់ជូនអ្នកស្រី ដោយស្មោះថា "ពាក្យយកចេញ" នេះៗ គឺអត់សំដៅដោះលែងទេអ្នកស្រី គឺកម្ទេច ។ ពាក្យថា "ដោះលែង" គឺច្បាស់ ដោះលែងដូច TC១ អ៊ីចឹង ។ ពាក្យដោះលែង គឺដូច

TC១ អ៊ីចឹង គឺគេទៅផ្ទះគេ អាហ្នឹងដោះលែង ។ បើថាយកចេញហើយ គឺគ្នាស្គាល់សេចក្ដីស្លាប់ហើយ ។

**ស៖** សូមអនុញ្ញាតមួយសំណួរទៀត ។ សំណួរនេះ ទាក់ទងនឹងការអ្វីដែលជនជាប់ចោទបានឆ្លើយពីព្រឹកមិញហើយដែរ ។ ទាក់ទងនឹងមនុស្សដែលនៅក្នុងរណ្ដៅ ឬថារណ្ដៅដែលថា ឃុំឃាំង មន្ទីរឃុំឃាំងក៏បាន ដែលមានរណ្ដៅជម្រៅ ២ម៉ែត្រហ្នឹង ។ តាមអ្វីដែលជនជាប់ចោទបានរ៉ាយរ៉ាប់នឹង គឺថាអ្នកដែលនៅក្នុងរណ្ដៅនោះ មិនមែនការស្លាប់ទេ ។ អ៊ីចឹង ព្រះរាជអាជ្ញាមានបំណងសួរថា ចង់ដឹងពីហេតុការណ៍ នៅពេលដែលទឹកជំនន់នោះ តើទឹកជំនន់ពេលយប់ ឬក៏ពេលថ្ងៃ?

[១៤:២០:១៦]

ឆ៖ សូមអរគុណ ដែលអ្នកស្រីសួរបញ្ជាក់ឲ្យយើងខ្ញុំឆ្លើយ ។ ទឹកជំនន់នោះ បើតាមខ្ញុំចាំពេលព្រឹកម៉ោងប្រហែល៩ មកគ្រឹកៗទឹកជំនន់ភ្នំ អ្នកស្រីប្រហែលមិនទាន់បានជ្រាបដោយផ្ទាល់ទេ ។ ឡើងលឿនណាស់មួយម៉ោងប្រហែល១ម៉ែត្រ ។ យើងខ្ញុំទប់មិនជាប់ទេ មុនដំបូងខ្ញុំស្មានតែតិចៗល្មមទេ អាភ្លៀងនឹងនៅកន្លែងម-១៣ ហ្នឹងតិចប៉ុន្មាន តិចទេ ប៉ុន្តែវាមកពីលើហ្នឹង មិនដឹងពីណាមកគគ្រឹកៗមកឡើងរឹបៗ ខ្ញុំរត់សឹងតែមិនទាន់យកជនរងគ្រោះចេញពីរណ្ដៅ ទម្រាំឲ្យចេញផុតពីរណ្ដៅមកនៅខាងលើមាត់ហ្នឹង គ្នាលិចត្រឹមកអស់ហើយ ។ ដូច្នេះទឹកជំនន់ថ្ងៃ ។

[១៤:២១:០៤]

**ស៖** សូមភ្ជាប់នឹងសំណួរនេះបន្តិចទៀត ដោយសារឥឡូវនេះបានស្ដាប់ហើយថា ទឹកជំនន់នោះបានចាប់ផ្ដើមលិចនៅម៉ោង៩ព្រឹក ហើយជាល្បឿនមួយដែលខ្លាំង ។ សូម្បីតែធ្វើការភៀសខ្លួននឹងសឹងតែមិនទាន់តែម្ដង បើការស្លាប់មកអម្បាញ់មិញនេះ ។ អ៊ីចឹង ចង់សួរវិធីនៃការសង្គ្រោះ អ្នកដែលនៅក្នុងរណ្ដៅនោះយ៉ាងដូចម្ដេច? ដែលអ្វីដែលជនជាប់ចោទបានអះអាងថា អ្នកដែលជាប់ក្នុងរណ្ដៅហ្នឹងហើយពុំមានការស្លាប់ ដោយសារល្បឿនទឹកជំនន់នោះលឿន ?

**ឆ៖** អាទឹកនឹងវាហៀរចូលរណ្ដៅ ដល់មុនដំបូងលិចត្រឹមណេះ ខ្ញុំដូចជាមិនសូវជាភ័យទេ ។ ខ្ញុំនិយាយលែង "ខ្ញុំថា អ្ហែងបន្តិចទៀតលិចដល់ត្រឹមនេះហើយ" មែន! ដល់អាខ្ញុំដល់ត្រង់នេះ "ចុញមែន! ឡើងៗនាំគ្នាឡើងៗ" ខ្ញុំឲ្យកងការពារជញ្ជូនពួកនុ៎ងឡើងមកឈរនៅមាត់រណ្ដៅហ្នឹងសិន ដល់ងាកទៅមើលទឹកសល្អាចនៅនុ៎ង ។ ដល់ទឹកចាប់ផ្ដើមនងបន្តិច បានៗបញ្ជូនចេញទៅលើទួល ។ លើទួលនេះចម្ងាយប្រហែលជា៥០ម៉ែត្រពីគុក ពីរណ្ដៅ ។ ត្រូវឆ្លងកាត់ត្រពាំងច្រាប វាទំនាបត្រង់ត្រពាំងច្រាប

នុំង ។ ដូច្នេះ ចាំឲ្យអាត្រពាំងច្រាប នឹងវារាក់បន្តិចសិន បរិវេណត្រពាំងច្រាបហ្នឹងវារាក់បន្តិចសិនបាន យើងខ្ញុំឆ្លង ។

សូមបញ្ជាក់ជូន មួយថ្ងៃនោះអត់បាយគ្រប់គ្នា ទាំងពួកខ្ញុំទាំងពួកជនរងគ្រោះ ។ អត់បាយគ្រប់គ្នាមួយថ្ងៃពេញៗ ។ មួយថ្ងៃនោះទាំងអស់គ្នាអត់បាយ អណ្តើតបាត់ជ្រូក អណ្តើតបានក្ងាន ហើយ អណ្តើតបាត់របស់របរតែនៅសល់មនុស្ស ។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៀតអង្គជំនុំជម្រះសូមប្រគល់វេទិកា--

អញ្ជើញៗលោកសហព្រះរាជអាជ្ញា ។

[១៤:២៣:១៧]

**សួរដោយលោក រ៉ូប៊ឺត ពេទីត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំព្យាយាមសួរដោយសង្ខេប ហើយប្រហែលជាភាគីផ្សេងទៀតគេអាចសួរ ហើយឆ្លើយជាភាសាខ្មែរ ប៉ុន្តែខ្ញុំអាចចន្លោះខ្លះនៅក្នុងការបកប្រែ ។ សូមឲ្យ ដោយមានការអនុគ្រោះពីតុលាការនេះ ។ ជាឧទាហរណ៍ដំបូងនោះ ប្រសិនជាអត្ថបទខ្មែរនោះ សរសេរត្រឹមត្រូវ កុមារបីនាក់ដែលជនជាប់ចោទបាននិយាយថា គាត់ចង់ចិញ្ចឹមនោះ ហើយក្រោយមកត្រូវបានស្លាប់ ។

**ស៖** តើសេចក្តីថ្លែងការណ៍ហ្នឹងត្រូវទេ?

[១៤:២៤:០០]

**ឆ៖** អរគុណលោកសហព្រះរាជអាជ្ញាដែលសួរខ្ញុំ ។ រឿងនេះ ខ្ញុំនៅចងចាំមួយជីវិត ជាអំពើដែលខ្ញុំខំធ្វើដើម្បីសង្គ្រោះជីវិតកុមារ ។ ប៉ុន្តែក្រោយមក ខ្ញុំសុខចិត្តចុះចាញ់ថ្នាក់ដឹកនាំអំពីគោលគំនិតថា "ខ្លាចសងសឹក" ។ ដូច្នេះ ខ្ញុំពិតជាបានខំចិញ្ចឹមកុមារបីនាក់របស់ជនរងគ្រោះម្នាក់ដែលទៅជាប់នៅនុំងឈ្មោះ សាំង អ៊ុន ហើយដល់ក្រោយមកខ្ញុំខ្មាសខ្លួនឯង ដោយសារឃើញអង្គភាពមួយទៀតគេចិញ្ចឹមកុមាររស់ គេប៉ានទុក គេមិនកំសាកដូចខ្ញុំ ។ ខ្ញុំខ្មាសអៀន ដូច្នេះរឿងនេះវាៗមានអារម្មណ៍ជាប់ពិត ។

**ស៖** ប្រហែលជាសំណួរខ្ញុំមិនច្បាស់ ។ អ៊ីចឹងកុមារបីនាក់ នោះគឺថាក្រោយមកបានស្លាប់មែនឬមិនមែន?

**ឆ៖** កុមារបីនាក់ហ្នឹង ស្លាប់ដោយជំងឺ ។ ជំងឺហើមបន្តបន្ទាប់ ហើយខ្ញុំមើលទៅដូចមកពី-- ខ្ញុំវិភាគកាលពីជំនាន់នុំង ។ តាមសមត្ថភាពវិភាគរបស់ខ្ញុំ ខ្ញុំថាមកពីខ្វះមនោសញ្ចេតនា ដើម្បីចិញ្ចឹមកុមារ

ត្រូវមានម្ហូបអាហារ ក៏ប៉ុន្តែត្រូវមានមនោសញ្ចេតនាដែរ ពីព្រោះខ្ញុំចិញ្ចឹមក្មេងបីនាក់នោះ ទន្ទឹមគ្នានឹងខ្ញុំចិញ្ចឹមកូនរបស់ KW០៨ ។ ដល់យប់កូនរបស់អ្នកទាំងបីនាក់នោះទៅនៅក្នុងត្រង់សេ ក្នុងរណ្តៅ ដល់យប់កូនរបស់ KW០៨ មកនៅជាមួយម្តាយវា ។ គេថ្នាក់គេថ្នម គេបបោសអង្អែលគេៗអីទៅ ។ បានពេលនោះ គំនិតរបស់ខ្ញុំ ខ្ញុំថាចិញ្ចឹមមនុស្ស ចិញ្ចឹមកុមារវាទាមទារពីរ ។ ទីមួយ ម្ហូបអាហារអនាម័យ ក៏ប៉ុន្តែទីពីរ ត្រូវមានមនោសញ្ចេតនា ។ ដល់រឿងនេះ ឯងហើយខ្ញុំយកទៅរាយការណ៍ជូនមេខ្ញុំគឺលោកគ្រូ សុន សេន គាត់ថាហ្នឹងហើយ មិត្តមើលចុះ មិត្តត្រូវចាំប្រយ័ត្នគំនុំ ខ្ញុំក៏សុខចិត្តចុះចាញ់គេពីពេលនោះមក ។ ដូច្នេះ ពិតជាស្លាប់ដោយជំងឺហើម រោគហើម ។

[១៤:២៦:២១]

**ស៖** ខ្ញុំគ្រាន់តែសួរថា ជាសំណួរជាឧទាហរណ៍នៃកង្វះនៅក្នុងការបកប្រែនៅក្នុងភាសាអង់គ្លេស គឺថាទាក់ទងនឹងជោគវាសនាកុមារនោះ គឺមិនបានបកប្រែទៅជាអង់គ្លេសទេ ។ អ៊ីចឹងនេះជាមូលហេតុដែលខ្ញុំបានសូមការអនុញ្ញាតពីតុលាការ ។ ខ្ញុំអាចចូលទៅដល់ប្រធានបទមួយគឺថា អាចនឹងប្រធានបទដែលយើងបានគ្របដណ្តប់ឲ្យច្បាស់ក្នុងភាសាមួយ ។ ដូច្នេះ សូមលោកបំភ្លឺប្រាប់ខ្ញុំ ឬក៏តុលាការអំពីកាលបរិច្ឆេទប្រហែល ឬក៏កាលបរិច្ឆេទជាក់លាក់អំពីការបង្កើត ហើយនៅម-១៣ តើប្តូរពីកន្លែងម-១៣ ទៅកន្លែងផ្សេងទៅ ទាក់ទងទៅនឹងមានអ្នកយាមនឹងមកផ្តល់សក្ខីកម្មអំពីរយៈកាលនោះ តើសូមលោកបញ្ជាក់ប្រាប់តុលាការនេះ អំពីកាលបរិច្ឆេទនៃការបង្កើត ការផ្លាស់ប្តូរទីកន្លែង តើម-១៣ “ក” ប្តូរចេញពីកន្លែងមួយទៅកន្លែងមួយបីដងហ្នឹង កាលបរិច្ឆេទដូចម្តេចខ្លះ?

[១៤:២៧:៣៥]

**ឆ៖** ម-១៣ “ក” វាទៅតាំងទីនៅកន្លែងដែលគេហៅថា TC១ ហ្នឹង គាត់ហៅថា អន្លង់វែងនោះ ចាប់តាំងពីកកើត ។ យើងមិននិយាយថា ចាប់តាំងពីកកើតទេ យើងនិយាយថា ក្រោយកកើតបន្តិចទៅនៅនុំងរហូតដល់រវាងខែ១ ខែ២ ដើមឆ្នាំ១៩៧២ ខ្ញុំបានផ្លាស់ទីកន្លែងទៅរកពន្លឺព្រះអាទិត្យ ព្រោះឃើញចំណុចខ្សោយនៅទីនោះវាអត់ពន្លឺព្រះអាទិត្យ ។ ជនរងគ្រោះស្លាប់បន្តបន្ទាប់ដោយសារខ្វះពន្លឺព្រះអាទិត្យ អនាម័យអាប់អួរ ដល់បានពន្លឺព្រះអាទិត្យហើយឆ្ងាយស្រុក ឆ្ងាយភូមិមានដីធ្វើស្រែខ្ញុំរត់ទៅរកកន្លែងនុំង ។ កន្លែងនុំងសូមបញ្ជាក់មួយម៉ាត់ទៀត គេហៅថា “តាលាវ” ឬ ហៅមួយម៉ាត់ទៀត ទួលមួយនៅក្បែរនុំងដែរ គេហៅ “ទួលស្វាយមាស” នៅជាប់នឹងជើងភ្នំពីស ក្នុងឃុំអមលាំងដដែលហ្នឹង ។ យើងខ្ញុំនៅទៅនោះយូរប្រហែលជាដល់ទៅខែ៦ ឆ្នាំ៧០ (សូមទោស) ប្រហែលជាខែ៣ ខែ៤ ឆ្នាំ១៩៧៣

បានមានកើតរឿងគេរើមន្ទីរ ។ យើងខ្ញុំក៏រត់ពីនោះមកតាំងទីមួយកន្លែងទៀតសិន តែខ្លីទេ ។ កន្លែងនុ៎ងគ្រាន់តែតាំងទីធ្វើស្រែ នៅភូមិព្រៃក ឃុំគោក ។ បានមួយខែពីរ បានតាម៉ុកគាត់ដេញ បានខ្ញុំទៅនៅជាប់ស្លាពរនៅនឹងភ្នំណិច ត្រពាំងច្រាប ។

ដូច្នេះ កន្លែងពិតប្រាកដនឹងវាបីកន្លែងយូរៗ កន្លែងមួយកន្លែងហ្នឹង គឺតិចទេ គឺនៅភូមិព្រៃកហ្នឹងមួយខែពីរអីប៉ុណ្ណឹងទេ ។

**សៈ** អ៊ីចឹងតាមខ្ញុំៗយល់ថា ទីតាំងចុងក្រោយនោះ គឺប្រហែលជាក្នុងខែមិថុនា ឆ្នាំ៧៣ អ៊ីចឹង?

[១៤:២៩:៥០]

**ឆៈ** បាទ, បើទីតាំងចុងក្រោយហ្នឹង ប្រហែលជាខែមិថុនា ឬក៏ខែមេសាអីនុ៎ង ៧៣មក រហូតមកដល់ចប់ចុងចប់ដើម ។

**សៈ** បើខ្ញុំស្តាប់យល់ច្បាស់អំពីសក្ខីកម្មព្រឹកមិញនេះ ។ ក្នុងដំណាក់កាលដែលដំណើរការរបស់មន្ទីរហ្នឹងសូមកែខ្ញុំ បើសិនជាខ្ញុំខុស គឺថាវាប្រហែលជាមាន២០នាក់ ឬ៣០នាក់នៃអ្នកឃុំខ្លួន គឺគេនាំចូលមន្ទីរហ្នឹងរៀងរាល់ថ្ងៃ ។ ត្រឹមត្រូវទេក្នុងព័ត៌មានហ្នឹង ?

**ឆៈ** បើនិយាយថា គេបញ្ជូនមនុស្សចូលមក ១៣ “ក” មួយថ្ងៃ២០ទៅ៣០នាក់ ពិតជាមិនត្រឹមត្រូវ ។ ខុសហើយ ។ យូរៗមកមួយពីរ បួនដប់ថ្ងៃមកមួយពីរ ហើយដែលមកទាំងឈុត ដូចខ្ញុំជម្រាបចៅក្រមឡាវែន៍ ព្រឹកមិញ គឺមកនៅពេលគេវាយបែកឧដុង្គម្តង គេឲ្យមកស្នាក់នៅពីរ-បីថ្ងៃ ហើយមេខ្ញុំគាត់បញ្ជូនទៅបាត់ដំបង ។ ហើយនៅពេលដែលមេខ្ញុំគាត់រើរុះភូមិមួយ ដែលគាត់ហៅថាភូមិសន្តិសម្ព័ន្ធនោះ ភូមិពោធិ៍ ឈ្មោះភូមិពោធិ៍ ឃុំមិនដឹងឃុំអីទេ ចាប់មកទាំងឈុត២០ - ៣០នាក់ដែរ ។ ក៏ប៉ុន្តែ គាត់ទុកប្រហែលជា៥នាក់នៅ ម-១៣ ហើយក្រៅពីនោះគាត់បញ្ជូនទៅបាត់ដំបងទៀតទៅ ។

ដូច្នេះ បើនិយាយពាក្យថា ហឹស! ចូល ម-១៣ មួយថ្ងៃពី២០ទៅ៣០នាក់ ។ ខុស ។

**សៈ** អ៊ីចឹងហើយ យើងកត់ត្រា និងការបកប្រែត្រឹមត្រូវ កែតម្រូវ ។ អ៊ីចឹងជាមធ្យមថាគឺមួយនាក់ ឬពីរនាក់ក្នុងមួយថ្ងៃ ដែលបញ្ជូនមក អ៊ីចឹងត្រូវទេ?

**ឆៈ** ប្រហែលជាអ្នកបកប្រែទេ ប្រែមិនចំទៀត លោកព្រះរាជអាជ្ញា ។ យូរៗមកមួយពីរយូរៗបួនដប់ថ្ងៃមកមួយពីរ ទម្រាំហ្នឹងតែបាន៣០នាក់ ដែលរត់នៅតាលាវ យូរដែរ ។

**សៈ** តើលោកនៅចាំថា គ្រួសារទាំងមូលមួយត្រូវបានគេបញ្ជូនមក ម-១៣ វាមានកុមារ ហើយឪពុកម្តាយ ហើយនឹងជីដូនជីតា តើធ្លាប់មានអ៊ីចឹងទេ? មកជាមួយ ។

[១៤:៣៣:០៩]

**ឆ៖** មាន១ពីខាងឃុំយាយអង្គមកមួយ ។ ប៉ុន្តែគ្រួសារនេះមកនៅ ម-១៣ បានប្រហែលជាពីរខែ មេខ្ញុំឲ្យបញ្ជូនទៅខាងបាត់ដំបងបាត់ទៅ ខាងឃុំយាយអង្គ មិនមែនខាងឃុំអមលាំងនោះទេ ។ ខាងឃុំអមលាំង មកទាំងឪពុក មកទាំងម្តាយ មកទាំងកូន ។ ក៏ប៉ុន្តែ កំលោះអស់ហើយ ហ្នឹងម៉ា--គេឲ្យខ្ញុំកម្ទេចតែឪពុកទេ ម្តាយហើយនិងអាកូនពីរនាក់ទៀតបញ្ជូនទៅបាត់ដំបង អាកូនច្បងកម្ទេច ។ នេះមាន ខ្ញុំនៅចាំបាន កូនរបស់មេឃុំចាស់ ឈ្មោះ ភឿង កូនមេឃុំ ភឿង ។ ឯចំណែកពួកនៅខាងយាយអង្គ ហ្នឹង ឪពុកឈ្មោះ ក្រែក ម្តាយឈ្មោះ ប៉ម ។

**ស៖** ឥឡូវនេះ ខ្ញុំសុំសន្និដ្ឋានថាអ៊ីចឹង ដើម្បីឲ្យលោកធ្វើការងាររបស់លោកបានល្អនៅពេលនោះ លោកពិតជាបានបញ្ជូន ឬក៏ផ្តល់ព័ត៌មានអំពីអ្នកដែលជាប់ឃុំនោះ អំពីបទឧក្រិដ្ឋដែលគេបានចោទប្រកាន់ ឬក៏កំហុសរបស់ពួកគេ ដើម្បីឲ្យលោកចោទសួរគេឲ្យបានត្រឹមត្រូវ ដើម្បីនឹងសម្រេចថាចម្លើយរបស់គេនឹងពិត ឬក៏មិនពិត ថាតើព័ត៌មានអ្វីខ្លះដែលលោកបានផ្តល់ទៅឲ្យអ្នកជាប់នៅ ម-១៣ ? តើមានវាទម្រង់ដូចម្តេច?

**ឆ៖** ខ្ញុំជម្រាបលោកព្រះរាជអាជ្ញាដោយត្រង់ ខ្ញុំអត់ទាន់យល់ជម្រៅនៃសំណួរនេះទេ ។ ឮហើយជាពាក្យសម្តី ក៏ប៉ុនជម្រៅនៃសំណួរឲ្យខ្ញុំចង់ ឲ្យខ្ញុំបញ្ជាក់យ៉ាងម៉េច? សូមព្រះរាជអាជ្ញា លោកមានប្រសាសន៍ម្តងទៀត ។

**ស៖** តើអ្វីលោកបានដឹងទេ ថាអ្នកដែលគេនាំមកឲ្យលោកហ្នឹង? ពេលដែលគេមកដល់ ម-១៣ តើគេផ្តល់ឯកសារមកជាមួយទេដែលនិយាយពីអ្នកទាំងនោះ? ថាតើនិយាយថា បទឧក្រិដ្ឋហ្នឹងគេប្រព្រឹត្តអី? ថាអ្នកណាជាអ្នកបញ្ជូនមក? តើព័ត៌មានអ្វីដែលលោកបានទទួលបាន អំពីអ្នកទោសដែលគេបញ្ជូនមក ដើម្បីឲ្យលោកធ្វើការងារសួរចម្លើយ ឬក៏ធ្វើកិច្ចការបន្តបានច្បាស់លាស់នោះ?

**ឆ៖** មនុស្សដែលគេបញ្ជូនមក មានការផ្តល់ព័ត៌មានពីលើមកខ្ញុំ ។ ក៏ប៉ុន្តែ មិនជាលាយលក្ខណ៍អក្សរទេ ។ កាលណាជួនអីមនុស្សមកដល់កន្លែងខ្ញុំហើយ ខ្ញុំសួរបានម៉ាភ្លែតទៅ ខ្ញុំរត់ទៅរាយការណ៍សុំយោបល់គេ តើអាមនុស្សនុំងបែបម៉េច ?

ឧទាហរណ៍ជាក់ស្តែងមកជាមួយនឹងសាក្សី ហាម អ៊ីម នេះមានគ្នា៥នាក់ ប្រុស២ ស្រី៣ មកដល់ខ្ញុំសួរមួយព្រួសហ្នឹងទៅ ខ្ញុំឃើញកលការមិនស្រួល ខ្ញុំរត់ទៅរាយការណ៍ សុំដោះលែង ហាម អ៊ីម ទុកអ្នកផ្សេងទៀត ។ ទៅដល់ហ្នឹងខាងណោះគេបញ្ជាក់ គេថាពួកនេះជាពួកក្រុមសិល្បៈ វាទៅដើរ

ឃោសនាពាសវាលពាសកាល ។ ឃោសនាថា យើងបំបាត់ព្រះពុទ្ធសាសនា ដល់ចុងបញ្ចប់ អាមេនោះពួកម៉ាក់របស់ ហាម អ៊ីម ឈ្មោះកឿន ស្អី កឿន ទេ ។ ន៎ែ អ្នកឯងខ្ញុំទុកឲ្យបួសមួយខែទៀត ហឹស! អ្នកឯងខ្ញុំឲ្យបួសពីរខែទៀត សុទ្ធតែលែងធុនហ្នឹង ។ ម្ល៉ោះហើយខាងមូលដ្ឋានគេចាប់ គេចាប់គេបញ្ជូនមកយើងខ្ញុំ ហឹស! ពួកសិល្បៈខាងមូលដ្ឋាន គេចាប់គេបញ្ជូនមក គេអត់ទាន់ផ្តល់ព័ត៌មានអីទេ យើងខ្ញុំសួរម៉ាផុស ខ្ញុំរត់ទៅសុំដោះលែង ហាម អ៊ីម ។ ដល់ទៅគេប្រាប់ព៏ត៏មានហ្នឹងមក ថាវាធ្វើសកម្មភាពប្រឆាំងអញ្ចេះៗឲ្យយើងខ្ញុំសួរទៅកុំវារែក ខ្ញុំសួរ ហើយជាមួយស្អី កឿន នោះពិតជាខ្ញុំឲ្យគេធ្វើទារុណកម្មមែន ។ ឯចំណែក ហាម អ៊ីម អត់ទេ ក្រៅពីនោះស្រីៗ៣នាក់ ។

[១៤:៣៧:៣៣]

**ស៖** តើជាសក្ខីកម្មរបស់លោកដែលថា អ្នកជាប់ឃុំនោះគេបញ្ជូនមកកន្លែងរបស់លោក ហើយលោកមិនមានព័ត៏មានអ្វីទាក់ទងនឹងអ្នកទាំងនោះទេ ហើយមុនពេលនឹងធ្វើទារុណកម្ម និងសួរចម្លើយគេនោះ?

**ឆ៖** មកភាគច្រើនខ្ញុំបានព័ត៏មាន ។ ឧទាហរណ៍ ដូចជាភូមិពោធិ៍ អ៊ីចឹង មេប្រាប់ ន៎ែ! អាពួកហ្នឹងភូមិសន្តិសម្ព័ន្ធ មិត្តឯងមើលសួរចម្លើយ៥នាក់ ។ គាត់ប្រាប់មក ប្រាប់ឈ្មោះ ក្រៅពីនោះទុកឲ្យខ្ញុំហើយដល់មួយសន្ទុះមែន គាត់ដោះលែងទៅបាត់ដំបងបាត់ទៅ ។ ដូច្នេះ គាត់ប្រាប់អ៊ីចឹង ឯចំណែកខាងនិរតីច្រើនតែច្រេចច្រូចបន្តិច ។

**ស៖** ដូច្នេះ ថាតើព័ត៏មានបែបនោះគេផ្តល់មកឲ្យលោកតាមរបៀបណា? តើជាប់អ្នកទោសគេផ្តល់ឲ្យ ឬក៏មានអ្នកផ្សេងទៀត ជាអ្នកផ្តល់ព័ត៏មានឲ្យ ឬក៏ផ្តល់តាមវិធីណា? តើរបៀបទទួលៗរបៀបណា?

**ឆ៖** បើជាមួយនឹងភូមិភាគពិសេស មេខ្ញុំម្តងប្រាប់ ឬផ្ទាល់មាត់គាត់ ឬតាមរយៈ ចេង អន គឺសុន សេន ប្រាប់អត់ដែលខានទេ ។ ឯចំណែកខាងភូមិភាគនិរតី យើងខ្ញុំសួរមួយម៉ាត់ហើយ បានស្ទុះរត់ទៅរក គេថាអានេះយ៉ាងម៉េច? គេប្រាប់មកក្រោយ ។

ដូច្នេះ គេប្រាប់ ។ សរុបម៉ាមាត់ ។ យូរឬឆាប់គង់តែគេប្រាប់ទេ ។ ប៉ុន្តែ គោលការណ៍តែគេមកដល់ហើយគឺត្រូវតែដាក់ឲ្យគេសិន ។ ដាក់ខ្នោះ ។ ហើយយើងសួរប្រវត្តិរូបបន្តិចសិនទៅ អានេះខាងនិរតី ។ ឯចំណែកខាងភូមិភាគពិសេស បើជាមួយលោកគ្រូ សុន សេន គាត់ប្រាប់ហើយមុន ។ មិត្តត្រៀម ។ ខ្ញុំឲ្យទៅប៉ុណ្ណោះ ។ សួរអានេះ អាផ្សេងទៀតទុក ។ ចាំខ្ញុំបញ្ជូនទៅ អានេះ ឧទាហរណ៍មក

ច្រើនៗ ។

[១៤:៣៩:៥៣]

**ស៖** តើលោកបានទទួលការណែនាំ ឬក៏ព័ត៌មាននោះ ឬក៏ឯកសារ ឬក៏ការទំនាក់ទំនងតាមផ្ទាល់មាត់ឬក៏តាមទូរស័ព្ទ ថាតើទទួលព័ត៌មានដូចម្តេច? អំពីអ្នកជាប់ឃុំឃាំងដែលគេបញ្ជូនមកឲ្យលោកនោះ ?

**ឆ៖** គឺចាត់តាមមាត់ៗ ។ គាត់ប្រាប់មកខ្ញុំកត់ក្នុងសៀវភៅរបស់ខ្ញុំ ។ តាមមាត់ អត់មានទូរស័ព្ទប្រើទេជំនាន់ហ្នឹង ។ មានឯងតេអូដែលគេហៅថាស្ទី វ៉ាដ្យូតេឡេហ្វូន នោះ អាហ្នឹងគេប្រើតែកងទ័ពទេ ។ ចំណែកខ្ញុំៗអត់មានទេ គឺមេប្រាប់មក ខ្ញុំកត់ ។

**ស៖** ដូច្នេះដើម្បីបញ្ជាក់ លោកត្រូវជួបជាមួយ សុន សេន ឬក៏ជួបជាមួយថ្នាក់លើណាមួយផ្សេងទៀត ឬក៏មកកត់ត្រានៅក្នុងសៀវភៅនូវព័ត៌មានអំពីអ្នកឃុំខ្លួន ដែលមកដល់ ម-១៣ ហើយ ឬក៏ដែលនឹងត្រូវបញ្ជូន អ៊ីចឹងត្រូវទេអ៊ីចឹង?

**ឆ៖** បញ្ជូន ។ សូមបញ្ជាក់ជូនលោកព្រះរាជអាជ្ញាថា ដែលនឹងត្រូវបញ្ជូន ។ ឯចំណែកខាងភូមិភាគនិរតី គេបញ្ជូនមកហើយ ខ្ញុំទៅរាយការណ៍ បានគេផ្តល់ព័ត៌មានថែមក្រោយ ។ ឯចំណែក ជាមួយ សុន សេន មេខ្ញុំ គាត់ផ្តល់ព័ត៌មាន មនុស្សដែលនឹងត្រូវបញ្ជូន ។

[១៤:៤១:៣០]

**ស៖** សុំទោស, ជាសំណួរសាមញ្ញ តើលោកកត់ត្រានៅក្នុងសៀវភៅអំពីអ្នកទាំងអស់នេះ ដើម្បីឲ្យបានព័ត៌មានពីអ្នកទោសអ៊ីចឹងមែនទេ?

**ឆ៖** ដល់មេដាក់ឲ្យមក ខ្ញុំកត់នឹងសៀវភៅរបស់ខ្ញុំ ដែលធ្វើការជាមួយនឹងមេ ។ ដល់កាលណាយើងខ្ញុំសួរចម្លើយគេ យើងខ្ញុំសរសេរនៅលើក្រដាស ដូចខ្ញុំបានជម្រាបជូនលោកចៅក្រម ឡាវែន៍ ហើយយើងខ្ញុំយកមកក្រដាសហ្នឹង សរសេរនឹងខ្មៅដៃ ប៉ុន្តែក្រដាសហ្នឹង ក្រដាសគេបោះពុម្ពកាសែត ។ យើងខ្ញុំយកមកហែកឲ្យបប៉ុនៗក្រដាសរ៉ាម ប៉ប៉ុនៗណេះ ហើយយើងខ្ញុំសរសេរនឹងខ្មៅដៃ ។ ហើយដល់បានចម្លើយយ៉ាងម៉េចៗ ខ្ញុំជូនអាហ្នឹងទៅ ក្រដាសនឹងទៅគេ ហើយចំណែកឯសៀវភៅការងារ ខ្ញុំធ្វើជាមួយនឹងមេនៅផ្សេង ។

[១៤:៤២:២៩]

**ស៖** តើញឹកញាប់ប៉ុនណា? ដែលលោកត្រូវរាយការណ៍អំពីការសួរចម្លើយរបស់លោកទៅថ្នាក់

លើ ថាតើត្រូវផ្តល់ចម្លើយសារភាពទៅថ្នាក់លើហ្នឹង ផ្តល់តាមរបៀបណា? វិធីណា?

**ឆ៖** ជាមួយភូមិភាគនិរតី អ្នកនៅប្រចាំ ខ្ញុំស្រួលទៅរកទេ មនុស្សនោះអត់ចេះច្បាំងនឹងគេទេ ។ បងស៊ី ឈ្មោះដើម ជូ ជេត ហ្នឹងអនុលេខា ។ ខ្ញុំចង់ទៅជួបគាត់ថ្ងៃណា ខ្ញុំទៅជួបបាន មិនជាពិបាកទេ មិនសូវដែលមិនជួបទេ តែទៅជួប។ ចំណែកមេខ្ញុំលោកគ្រូ សុន សេន ច្រើនតែរវល់ការងារ ។ គាត់ហៅនិរសារឲ្យមក ឬក៏គាត់ណាត់ប្រាប់ប៉ុន្មានថ្ងៃទៀត៥ថ្ងៃទៀត មិត្តឯងមក អាហ្នឹងខ្ញុំត្រូវទៅទៅជួប ។ ឯចំណែកជាមួយ សុន សេន ការងារល្អិតណាស់ ។ ទៅដល់ខ្ញុំត្រូវទៅនៅកន្លែងនិរសារ ដោះកាំភ្លើងខ្លីទុក ពេលឃើញកម្មាភិបាលពីរ-បីនាក់ទៀតចេញ បានខ្ញុំចូលទៅ ។ ដល់ម៉ោងអាកម្មាភិបាលផ្សេងទៀតគេចេញ ហើយបានគេមកហៅខ្ញុំចូលទៅ ធ្វើការចប់ម៉ោងខ្ញុំចេញ អ្នកផ្សេងទៀតចូល ។ ដូច្នេះ គេមានកម្មវិធីរបស់គេច្បាស់លាស់ ។ គេហៅខ្ញុំទៅជួប ។

**ស៖** តើលោកធ្លាប់រាយការណ៍ទៅ ឆាយ គឹមហ៊ អំពីចម្លើយសារភាពរបស់អ្នកទោសណាម្នាក់ ឬក៏ច្រើនទេ ?

**ឆ៖** បង គឹមហ៊ គាត់ជាអ្នកនាំពាក្យរបស់ភូមិភាគនិរតី ។ ក្នុងរឿងចាំទទួលមនុស្ស គាត់អាចមកប្រាប់ខ្ញុំបាន ក៏ប៉ុន្តែរឿងទាមទារដោះលែង ខ្ញុំក៏ចង់បុកទៅតាមរយៈគាត់ដែរ ឲ្យតែខាងភូមិភាគនិរតីក៏ប៉ុន្តែដល់ចម្លើយមែនទែន ខ្ញុំត្រូវរាយការណ៍ឲ្យទៅដល់ ជូ ជេត ហៅ ស៊ី ឬក៏ ហួត ហេង ហៅ ប៉ាល់ គាត់គ្មានសិទ្ធិទទួលចម្លើយសារភាពទេ ។ ខាងភូមិភាគពិសេស បង ចេង អន ក៏គ្មានសិទ្ធិទទួលចម្លើយសារភាពដែរ មានតែលោកគ្រូ សុន សេន ឬក៏ វន វ៉េត ។

[១៤:៤៥:00]

**ស៖** អ៊ីចឹងហើយ ថាតើត្រូវទេ ដែលនិយាយថា ម-១៣ ដែលយកចាប់ផ្តើមបង្កើតប្រព័ន្ធនៃរក្សាកំណត់ត្រាអ្នកទោស ហើយហ្នឹងសេចក្តីសារភាព តើអ៊ីចឹងទេ? ត្រូវទេ?

**ឆ៖** ប្រព័ន្ធកំណត់ត្រាសេចក្តីសារភាព ខ្ញុំមិនទាន់យល់ពាក្យហ្នឹងជាជម្រៅទេ សុំលោកសហព្រះរាជអាជ្ញា មេត្តាពន្យល់ខ្ញុំបន្តិច ។

ប្រព័ន្ធកំណត់ត្រា-- ខ្ញុំអត់ទាន់យល់ច្បាស់ពាក្យថា ប្រព័ន្ធកំណត់ត្រាជាជម្រៅន័យរបស់វាយ៉ាងម៉េច? ប្រព័ន្ធកំណត់ត្រានៃសេចក្តីសារភាពអ្នកទោស តើន័យរបស់វាយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

សុំលោកសហព្រះរាជអាជ្ញា រៀបចំតាំងសំណួរសាជាថ្មីឲ្យបានច្បាស់លាស់ ពីព្រោះសំណួរចុង

នេះ លោកជនជាប់ចោទយល់អត់ច្បាស់?

**សួរដោយលោក រ៉ូប៊ឺត ពើទីត៖**

**ស៖** សូមអរគុណ ។ ខ្ញុំរង់ចាំដល់ជនជាប់ចោទនឹងបិទមីក្រូហ្វូន ខ្ញុំនឹងចាប់ផ្តើម ។

សំណួររបស់ខ្ញុំហ្នឹង ខ្ញុំនឹងសម្រួលឡើងវិញ ។ ថាតើជាត្រឹមត្រូវទេ? ដែលអាចនិយាយថា នៅ ម-១៣ ដែលលោកចាប់ផ្តើមកត់ត្រានៅលើក្រដាសនូវព័ត៌មានអំពីអ្នកជាប់ឃុំ ហើយនិងការចូលមកដល់ ការកម្ទេច ហើយនិងកត់ត្រានូវសេចក្តីសារភាព នេះជាសំណួរសាមញ្ញ ។ តើត្រឹមត្រូវទេនៅម-១៣ ដែលលោកចាប់ផ្តើមប្រព័ន្ធនៃការកត់ត្រាព័ត៌មានទាំងអស់នេះ?

**ឆ៖** កត់ត្រាឈ្មោះអ្នកចូលមកដល់ ។ ត្រូវតែកត់ត្រាហើយពេលដែលចូលមកដល់ ។ ក៏ប៉ុន្តែ នៅពេលដែលកម្ទេចជនទាំងនោះហើយ បញ្ជីក៏យើងខ្ញុំកម្ទេចទៅដែរ ។ នេះជាផ្នែកមួយ អាហ្នឹងខាងភាសាច្បាប់-- វិទ្យាសាស្ត្រ គេថាម៉េចខ្ញុំមិនទាន់ដឹងទេ ។ ក៏ប៉ុន្តែ អ្នកដែលចូលមកដល់ ខ្ញុំត្រូវតែសួរចម្លើយ បានចម្លើយ ខ្ញុំរាយការណ៍ទៅលើ ចម្លើយខ្ញុំអត់តម្កល់ច្បាប់ដើមដូចនៅ ស-២១ ទេ នេះទីពីរ ។

ដូច្នេះ សភាពការណ៍ដំណើរការវាអ៊ីចឹង ។ ដល់កាលណាជូនចម្លើយចប់ហើយ មនុស្សកម្ទេចចប់ហើយ អស់ហើយសំណល់ ។ ជាភស្តុតាង អត់មានសល់ទេ ។

**ស៖** ហេតុអ្វីក៏ត្រូវបំផ្លាញចោលនូវឯកសារនោះ?

**ឆ៖** អត់មានសេចក្តីណែនាំឲ្យទុក ។ ហើយមនុស្សយើងកម្ទេចរួចទៅហើយ គ្មានអ្នកណាទាមទារអីទៀតទេ ចង់ដឹងអីទៀតទេ ។ ភារកិច្ចរបស់គេ គេប្រគល់មនុស្សមកឲ្យស-២១ ឃុំឃាំងសួរចម្លើយ ហើយកម្ទេច ។ កម្ទេចហើយយើងខ្ញុំចប់ភារកិច្ចហើយ អត់មានអីទុកជាឯកសារ ទុកជាភស្តុតាងអីសម្រាប់ទៅអនាគតអីទៀតទេ ។

**ស៖** អ៊ីចឹងហើយ លោកមិនមានមធ្យោបាយបង្ហាញភស្តុតាងទៅថ្នាក់លើក្រៅពីពាក្យពេចន៍ទេ ដែលថាពិតជាបាននូវអនុវត្តការបញ្ជានោះ តើត្រូវទេ? ប្រសិនបើមិនមានកំណត់ត្រាហ្នឹងទៀតទេ យើងប្រើ តែពេចន៍ដើម្បីបញ្ជាក់ថា កម្ទេចហើយ ឬក៏យ៉ាងម៉េច?

**ឆ៖** បើនិយាយអំពីភស្តុតាងដែលសម្រាប់បញ្ជាក់ប្រាប់ថ្នាក់លើថា កម្ទេចហើយ គ្មានភស្តុតាងបញ្ជូនគេទេ នេះជារឿងពិត ។ ក៏ប៉ុន្តែបើតាមយើងខ្ញុំសរុបមក អារឿងអស់ហ្នឹង គេដូចជាទុកចិត្តខ្ញុំ ថ្នាក់លើដូចជាទុកចិត្តខ្ញុំ ពីព្រោះខ្ញុំត្រង់ ត្រង់ណាស់ រត់រួចប្រាប់ថារត់រួច ។ កម្ទេចគឺប្រាប់ថាកម្ទេច ខ្ញុំមិន

ដែលមានបត់បែនទេ ។

ក្នុងមួយជីវិត ម-១៣ ខ្ញុំមិនដែលឃើញថ្នាក់លើបង្ហាញចំណែកណាមួយថា គេមិនទុកចិត្តខ្ញុំ ខ្ញុំឃើញតែគេបង្ហាញអាកប្បកិរិយារបស់គេ ថាគេទុកចិត្តខ្ញុំ ។

**លោក រ៉ូប៊ឺត ពើទីត៖**

[១៤:៤៩:៥៨]

លោកប្រធាន ខ្ញុំមានប្រហែលជាបី ឬក៏បួនសំណួរទៀត ។ ប៉ុន្តែខ្ញុំសួរលោកប្រធាន ថាតើលោកចង់ឲ្យខ្ញុំសួរបន្ទាប់ពីការសម្រាក ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

គឺចាំសម្រាកសិនទៅ ក្រោយមកវិញ សិមបន្តសួរទៀត ។

ឥឡូវ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃមីនុត រហូតដល់ម៉ោង៣ និង២០នាទី សុំអញ្ជើញចូលត្រឡប់មកវិញ ដើម្បីបន្តដំណើរការសវនាការ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ ។

*[សវនាការសម្រាកពីម៉ោង១៤:៥០នាទី រហូតដល់ម៉ោង ១៥:១៦នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តដំណើរការនីតិវិធី សវនាការតទៅទៀត ។ សូមផ្តល់វេទិកានេះជូនទៅសហព្រះរាជអាជ្ញា ដើម្បីបន្តតាំងសំណួរដល់ជនជាប់ចោទ ។ សូមអញ្ជើញសហព្រះរាជអាជ្ញា ។

**សួរដោយលោក រ៉ូប៊ឺត ពើទីត៖**

អរគុណលោកប្រធាន ។ ជាថ្មីម្តងទៀត កែខ្ញុំ ប្រសិនបើខ្ញុំលើកឡើងខុស ប្រសិនបើខ្ញុំយល់ត្រូវចំពោះចម្លើយរបស់លោក និងយោបល់របស់លោក ។

**ស៖** សំណួររបស់ខ្ញុំលោកបានលើកឡើងថា លោកតែងតែទៅទីកន្លែងរបស់លោក មិត្តស៊ី ដើម្បីយកសេចក្តីណែនាំ ឬក៏រាយការណ៍អំពីចម្លើយសារភាព ដើម្បីទាក់ទងជាមួយនឹងកម្មាភិបាល ដោយសារតែលោកធ្វើដំណើរទៅជួបគាត់ ដោយសារវានៅកន្លែងគាត់នៅជិត ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំត្រូវតែទៅជួបខាងលើដើម្បីរាយការណ៍ វាជារឿងចាំបាច់ ។ ដើម្បីជៀសវាងយថាហេតុផ្សេងៗ ដែលធ្លាប់មកដល់ខ្លួន នេះជារឿងមួយ ។

បើប្រៀបធៀបខាងនិរតី តាម៉ុក ដែលមេបងស៊ី ទៅទៀតនោះ គាត់ទៅច្បាំង មិនដែលនៅកន្លែងទេ មិនងាយជួបគាត់ទេ យូរៗជួបម្តង ។ បងស៊ី គាត់នៅហ្នឹងកន្លែងជាប្រចាំ ហើយកន្លែងនោះមិនឆ្ងាយពីមន្ទីរម-១៣ "ក" ប៉ុន្មានទេ ប្រហែលជាដប់គីឡូប៉ុណ្ណឹង ។ ដូច្នេះ ខ្ញុំជិះកង់ទៅបាន ។ ដូច្នេះ ខ្ញុំជួបគាត់ញឹកញាប់បាន ហើយគាត់គ្មានកម្មវិធីអីហ្មត់ចត់របៀប សុន សេន ទេ ។ យើងមានការអីចាំបាច់ស្ទុះរឹងទៅ អាចជួប ភាគច្រើនបានជួប ។

**ស៖** តើជាញឹកញាប់ប៉ុនណាដែលលោកធ្វើដំណើរទៅជួបលោក ពីទីកន្លែងលោកទៅជួបមិត្តស៊ីនោះ ។ តើញឹកញាប់ប៉ុនណាក្នុងមួយអាទិត្យ ក្នុងមួយថ្ងៃហ្នឹង?

**ឆ៖** ជួនអីមួយអាទិត្យ ។ ជួនអីប្រហែលជាដប់ថ្ងៃ មិនដែលងាយឆាប់ជាងហ្នឹងទេ ប្រហែលជាប្រាំថ្ងៃយ៉ាងឆាប់បំផុតប្រាំថ្ងៃ ។ ដូច្នេះ ប្រហែលជាមួយអាទិត្យទៅដប់ថ្ងៃ ។ រួចប៉ុន្តែពេលខ្លះអត់មានមនុស្សពីនិរតីមក ដល់មួយខែដែរ ដែលខ្ញុំទៅ ។ វាអាស្រ័យនឹងមនុស្សដែលពីខាងនិរតីមកនៅហ្នឹងកន្លែងខ្ញុំ ។

**ស៖** ដូច្នេះ លោកត្រូវធ្វើដំណើរទៅទីកន្លែងរបស់ តាម៉ុក ដើម្បីជួប ប្រសិនបើមានអ្នកទោសមកពីតំបន់និរតីចូលមក ម-១៣ ។ អីចឹងនេះជាចម្លើយរបស់លោក ឬយ៉ាងម៉េច?

[១៥:១៩:៥០]

ឆ៖ តាម៉ុកមុនឆ្នាំ១៩៧៣ ក៏គាត់មិនសូវនៅកន្លែង គាត់ទៅច្បាំង ។ ដល់ក្រោមមកគាត់នៅផ្នែកខាងត្បូងនេះ ច្បាំងរហូត ។ គាត់មិនដែលងាយទៅខាងជើង ហើយមិនដែលឲ្យ ម-១៣ ជួបគាត់ងាយទេ ។ ទាល់តែដឹងគាត់ភ្លាម ទៅភ្លាមបានទាន់ ។ ដូច្នេះ តាម៉ុក ខ្ញុំមិនងាយបានជួបទេ មួយជីវិតមន្ទីរ-១៣ នេះ ជួបគាត់ដូចជាបានបីបួនដងប៉ុណ្ណឹងឯង ។ អើយ! យើងថាយ៉ាងច្រើនដប់ដងទៅចុះ ។

**ស៖** បានន័យថា ដប់ដងក្នុងអំឡុងពេលបួនឆ្នាំដែលលោកបំពេញការងារនៅទីនោះ ឬយ៉ាងម៉េច?

**ឆ៖** មែន! ខ្ញុំជួបបង ម៉ុក តែប៉ុណ្ណោះ ប្រហែលប៉ុណ្ណោះ មិនងាយជួបគាត់ទេ ។

**ស៖** បើសិនបើខ្ញុំយល់ត្រឹមត្រូវនោះ ចម្លើយប្រសិនបើ ខ្ញុំយល់ត្រឹមត្រូវលើចម្លើយរបស់លោក លោកធ្វើដំណើររាល់អាទិត្យ ដើម្បីធ្វើការជួបជាមួយកម្មាភិបាលនៅតាមភូមិភាគផ្សេងៗទៀត តើត្រឹមត្រូវដែរឬទេ? រៀងរាល់អាទិត្យ ឬរៀងរាល់ពីរអាទិត្យ?

**ឆ៖** ជាគោលការណ៍កំណត់ជាមួយនឹងភូមិភាគនិរតី ដូចខ្ញុំបានជម្រាបលោកព្រះរាជអាជ្ញារួចហើយ ពេលណាមានមនុស្សមកត្រូវការបន្ទាន់ប្រាំថ្ងៃ ខ្ញុំទៅហើយ ។ ស្រេចនឹងការងារដែលខ្ញុំធ្វើល្អមតែរាយការណ៍ឲ្យគេ សូមយោបល់គេ ប៉ុន្តែយ៉ាងយូរណាស់ដប់ថ្ងៃ ។ ប៉ុន្តែដល់កាលណា គ្មានមនុស្សមកកាន់ខែដែរ ច្រើនខែបានខ្ញុំទៅជួបគាត់ ។ ដូច្នេះ អាស្រ័យនឹងមនុស្សខាងនិរតីមកនៅជាមួយនឹងខ្ញុំ ។

ឯចំណែកជាមួយ សុន សេន ក៏អ៊ីចឹង កាលណាមានមនុស្សមកពីភូមិភាគពិសេសមកនៅជាមួយនឹងខ្ញុំច្រើន ហើយគាត់ត្រូវការបន្ទាន់ គាត់ណាត់ហើយ ប៉ុន្មានថ្ងៃគាត់មក ខំធ្វើប៉ុណ្ណឹងថ្ងៃ ហើយមកជួបខ្ញុំ ។

**ស៖** គឺជាចម្លើយរបស់លោក គឺថាមិនមានការកំណត់ពេលវេលាអចិន្ត្រៃយ៍ ឬក៏ទៀងទាត់ទេ ដែលលោកត្រូវៗទៅជួបជាមួយនឹងកម្មាភិបាលនៅភូមិភាគហ្នឹង គឺអត់មានការកំណត់ទៀងទាត់ទេ ឬយ៉ាងម៉េច?

[១៥:២២:៣៣]

**ឆ៖** វាពិតជាគ្មានការកំណត់ទៀងទាត់ អាស្រ័យលើមនុស្សដែលនៅក្នុងដៃខ្ញុំ ដែលគេឲ្យសួរ ។

**ស៖** លោកបានឆ្លើយថា លោកទៅខ្លួនឯង ទៅជ្រើសរើសបុគ្គលិកតាមប្រភេទឋានៈ គឺជ្រើសរើសក្មេងៗពីឃុំមក ម-១៣ ដើម្បីឲ្យពួកគេក្លាយទៅជាបុគ្គលិកនៅ ម-១៣ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** មិនមែនទៅខ្លួនឯងទេ ។ ថាខ្លួនឯងក៏បាន ព្រោះខ្ញុំទាក់ទងនឹងបុគ្គលិកចាស់របស់ខ្ញុំ ដែលខ្ញុំពេញចិត្តឲ្យគេទៅរកគ្នាគេ ។ ដូច្នេះ កាលណាខ្ញុំបានឈ្មោះបានអីហើយ ខ្ញុំឡើងទៅសុំពីខាងលើ ឲ្យខាងលើគេអនុញ្ញាត ។ ដូច្នេះ គំនិតផ្តើមពីខ្ញុំឲ្យបុគ្គលិករបស់ខ្ញុំដែលខ្ញុំស្គាល់គេទៅរកអ្នកថ្មីមក ។ កាលណាខ្ញុំបានឈ្មោះបានអី បានការយល់ស្របពីម្ចាស់ខ្លួនគេហើយ ខ្ញុំឡើងទៅសុំយោបល់ពីខាងលើ។ នេះពិត ។

**ស៖** ហើយបុគ្គលិក គឺគាត់នឹងនាំមនុស្សមកច្រើនជាងការកំណត់ឈ្មោះ ដើម្បីថាឲ្យត្រឹមត្រូវចំពោះមនុស្សដែលទៅយកនោះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមបញ្ជាក់ មុននឹងខ្ញុំទៅសុំគេទាល់តែឯកភាពគ្នាជាមួយនឹងបុគ្គលិកចាស់របស់ខ្ញុំ ខ្ញុំមើល

ទៅមនុស្សនោះល្អ ម៉ែឪក្រ ម៉ែឪស្លូតត្រង់ ម៉ែឪមិនដែលមានរឿង ។ ខ្ញុំទៅថាឈ្មោះនេះសមរម្យហើយ ខ្ញុំស្នើសុំទៅខាងលើ ដល់ខាងលើគេអនុញ្ញាតហើយ បាន១មក ដូច្នេះគ្មានលើសទេ ។ គឺតែមក គឺកំណត់ ដែលខ្ញុំសុំគេ ក៏ប៉ុន្តែគ្រាន់តែអ្នកដែលសុំរួចមកហើយហ្នឹង ពេលខ្លះយកមកធ្វើការជាមួយខ្ញុំ ខ្ញុំឃើញមាន លក្ខណៈមិនអំណោយ ខ្ញុំក៏រកវិធានការឲ្យគេត្រឡប់ទៅភូមិវិញ ។

ឧទាហរណ៍ KW៣២ របស់យើង ។ KW៣២ របស់យើងគាត់ធ្វើការជាមួយខ្ញុំ គាត់ត្រង់ គ្រាន់តែមាឧគាត់តូច សម្តីគាត់វាឆេវឆាវបន្តិច ។ ហើយជាពិសេស ជីតាគាត់ម្នាក់ទៅរងគ្រោះនៅទុំង ខ្ញុំក៏រិះរកមធ្យោបាយឲ្យ KW៣២ ត្រឡប់ទៅផ្ទះវិញ ។

[១៥:២៥:១១]

**ស៖** តើលោកចាំដែរឬទេ ថាយ៉ាងហោចណាស់នៅពេលមួយចំនួន គឺលោកបានជួបជាមួយនឹង ប្រធានភូមិជុំវិញ ម-១៣ លោកទៅតាមភូមិ ទៅនិយាយជាមួយអាជ្ញាធរភូមិនៅទីនោះ?

**ឆ៖** ខ្ញុំជាមួយនឹងប្រធានភូមិ ជាមួយៗនឹងគណៈកម្មាធិការឃុំអមលាំង មានការជិតស្និតគ្នា ។ ឪពុករបស់ KW៣២ ហ្នឹង ទៅអញ្ជើញទៅលេងនៅទុំងម្តងពីរដែរ ។ ដូច្នេះ ខ្ញុំមានការជិតស្និទ្ធនឹង គ្នារាប់អានគ្នា ។ ពិត ។ ហើយសូមបញ្ជាក់លោកព្រះរាជអាជ្ញាថែមបន្តិចទៀតចុះ ខ្ញុំមានទាំងម្តាយធម៌ ឪពុកធម៌ នៅនឹងឃុំអមលាំង ភូមិថ្មគុប នេះទៅទៀត ។

**ស៖** ដូច្នេះលោកក៏ធ្វើដំណើរទៅអមលាំង និងភូមិផ្សេងៗទៀតនៅពេលផ្សេងៗទៀត តើត្រឹម ត្រូវដែរឬទេ សម្រាប់គោលបំណងផ្សេង?

**ឆ៖** ខ្ញុំទៅជាមួយនឹងផ្ទះផ្សេងទៀតនៅក្នុងឃុំដែលខ្ញុំ--ជិតមន្ទីរខ្ញុំនេះ ជាមនោសញ្ចេតនាធម្មតា មាន ។

**ស៖** នៅពេលដែលលោកចាកចេញពី ម-១៣ ថាតើអ្នកណាគេ ជាអ្នកដែលលោកទុកឲ្យទទួល ខុសត្រូវនៅទីនោះ?

**ឆ៖** ខ្ញុំចាកចេញពីមន្ទីរ-១៣ ទៅធ្វើការ ។ ជាទូទៅ ខ្ញុំទុកឲ្យពីរនាក់ ម្នាក់ គឺមិត្តប៉ុន ម្នាក់ទៀត គឺ KW០៨ ។ KW០៨ ទទួលភារៈខាងមើលកុំឲ្យមនុស្សរត់ ។

**ស៖** ថាតើមានការកើតឡើងដែរឬទេ? ថានៅពេលដែលធ្វើដំណើរនោះ គឺថាលោកនឹងចំណាយ ពេលមួយយប់ៗ នៅពេលធ្វើដំណើរ ពេលខ្លះទៅមិនអាចមកវិញក្នុងពេលមួយថ្ងៃទេ ។ ដូច្នេះនៅតាម ផ្លូវលោកបានចំណាយពេលគេងនៅតាមផ្លូវមួយយប់អ៊ីចឹងជួនកាល?

[១៥:២៧:៤៨]

**ឆ៖** បើមានៗនៅពេលដែល បងវន គាត់នៅមន្ទីរនៅក្នុងភូមិពាម ខ្ញុំរក្សាទៅសម្រាកនៅមន្ទីរ បងវន ។ នៅពេលដែលជាមួយលោកគ្រូ សុន សេន ខ្ញុំមិនដែលសម្រាកទេ។ អត់សោះ ។ ទៅ គាត់លៃពេលសម្រាប់ខ្ញុំត្រឡប់មកវិញទាន់ពេល ។

ដូច្នេះ ជាមួយនឹងលោកគ្រូ សុន សេន ផ្សេង ជាមួយនឹង វន វ៉េត ផ្សេង ។

**ស៖** ដូច្នេះបើសិនជាខ្ញុំយល់ត្រឹមត្រូវនោះ គឺវាមានអ៊ីចឹងមែន គឺថាលោកចាកចេញពី ម-១៣ ហើយនៅទីកន្លែងណាមួយ មួយយប់ដោយមិនបានត្រឡប់មកវិញទេ តើត្រឹមត្រូវដែរ ឬទេ?

**ឆ៖** កាលពីដើមសម័យ ម-១៣ មាន មានខ្ញុំចេញដោយមិនបានត្រឡប់មកវិញ ។

**ស៖** ប្រសិនបើខ្ញុំយល់ចម្លើយរបស់លោកនោះ នៅ ម-១៣ គឺលោកអត់មានមធ្យោបាយក្នុងការទំនាក់ទំនង មិនមានវិទ្យុទាក់ទង មិនមានទូរស័ព្ទទាក់ទង ដូចដែលលោកមាននៅ ស-២១ ទេ ។ តើត្រឹមត្រូវដែរទេ?

**ឆ៖** ប្រាកដជាត្រឹមត្រូវ ។

**ស៖** ហើយនៅពេលដែលលោកត្រូវធ្វើដំណើរ លោកនិយាយថាលោកមានកង់ ។ តើលោកមានមធ្យោបាយផ្សេងដែរឬទេ? ឧទាហរណ៍ថា នៅពេលដែលទៅភូមិភាគនិរតីថា តើលោកទៅទីនោះយ៉ាងម៉េច?

[១៥:២៩:៣៧]

**ឆ៖** ខ្ញុំដំបូងមានតែត្រឹមកង់ទេ ។ ដល់វាយបែកឧដុង្គ ដល់វាយឈ្នះឧដុង្គ មេខ្ញុំមិនប៉ានឲ្យម៉ូតូស្ទីទេ ឲ្យ *ម៉ូប៊ីឡេត* កញ្ចាស់មួយ ។ ដល់ក្រោយមកថ្ងៃ៣០ ខែមេសា ហ្នឹង គាត់ឲ្យម៉ូតូ មិនប៉ានទាំងឲ្យ *សេអិល៩០* ទៀត ឲ្យម៉ូតូ *បេសេ* ។ ខ្ញុំយកបាន *យ៉ាម៉ាហា* មួយថ្មី ។

ដូច្នេះ មធ្យោបាយធ្វើដំណើររបស់ខ្ញុំមានការផ្លាស់អ៊ីចឹង ពីកង់ មក *ម៉ូប៊ីឡេត* កញ្ចាស់មួយ ហើយពី *ម៉ូប៊ីឡេត* កញ្ចាស់មក *យ៉ាម៉ាហា* លេខ៨០ ។

**ស៖** លោករំឭកយើងទៅមើល ថាតើលោកខ្លួនឯងហ្នឹងធ្វើដំណើរដោយសេរីយ៉ាងម៉េច? តើលោកមានលិខិតពិសេសណាមួយដើម្បីធ្វើការដើរផ្លូវទេ ឬក៏លោកពឹងផ្អែកទៅលើតួនាទីរបស់លោក?

**ឆ៖** លិខិតដើរផ្លូវត្រូវតែមាន។ លិខិតដើរផ្លូវរបស់ខ្ញុំ នៃប្រធានមន្ទីរ៣០៥គេជាអ្នកចេញឲ្យ។ ហើយលិខិតដើរផ្លូវខាងភូមិភាគនីរតី មន្ទីរ២០១គេចេញឲ្យ ។ លិខិតដើរផ្លូវរបស់ខ្ញុំ នៅខាងភូមិភាគ

ពិសេស មន្ទីរ៣០៥ចេញឲ្យ ហើយដល់ក្រោយមករំសាយមន្ទីរ៣០៥ ទៅបង ចេង អន ចេញឲ្យ។ ឯចំណែកនៅខាងភូមិភាគនិរតីខ្ញុំត្រូវដើរនៅភូមិភាគនីរតី ខ្ញុំមានលិខិតដើរផ្លូវមួយរបស់មន្ទីរ២០១ គឺមន្ទីរភូមិភាគនីរតីជាអ្នកចេញឲ្យ ។ ត្រូវតែមាន ក៏ប៉ុន្តែដល់យូរទៅគេស្គាល់ខ្ញុំ រោងយាមគេស្គាល់ខ្ញុំ គេអត់ឆែកទេៗ យូរទៅរោងយាមគេស្គាល់ខ្ញុំគេអត់ឆែកទេ ដំបូងគេឆែក ។

**ស៖** បន្ទាប់ពីយូរមកគឺថា លោកធ្វើដំណើរអ៊ីចឹង នៅពេលក្រោយមកទៀតហ្នឹងគឺថាលោកធ្វើដំណើរដោយសេរី ដោយសារតែគេស្គាល់លោក ថាត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមជម្រាបបញ្ជាក់លោកសហព្រះរាជអាជ្ញា អ្នកដែលស្គាល់ខ្ញុំ គឺតាមតែផ្លូវដើរពីម-១៣ ទៅសំរោងទៅរ៉ាដំណាក់ស្នាច់ ដែលជាទីតាំងរបស់មេខ្ញុំ ។ អាហ្នឹងគេស្គាល់ខ្ញុំ គេអត់ឆែក ។ ផ្លូវខុសពីនោះ ប្លែកហើយគេឆែកហើយ តែបើបានផ្លូវខុសពីនោះគេឆែកហើយ ។

**ស៖** ដូច្នេះហើយ លោកត្រូវមានលិខិតដើរផ្លូវ សម្រាប់លោកប្រសិនបើគេអត់ស្គាល់លោក?

[១៥:៣៣:១៣]

**ឆ៖** បើកាលណាគេមិនស្គាល់គេឆែក ត្រូវតែហុចលិខិតដើរផ្លូវឲ្យគេ ។

**ស៖** អ៊ីចឹងនិយាយត្រឡប់ទៅវិញ និយាយអំពីគោលបំណងរបស់ម-១៣ ។ ជាថ្មីម្តងទៀត ប្រហែលជាដោយសារតែខ្វះចន្លោះការបកប្រែ គឺថាចម្លើយរបស់លោកក្នុងកំឡុងពេល៤ឆ្នាំជាប្រធានម-១៣ ។ លោកបានចាំធ្វើទារុណកម្មដោយខ្លួនឯងលើបុគ្គលចំនួនតែពីរទេ យ៉ាងតិចបំផុត ។ បានន័យថា៤ឆ្នាំហ្នឹង គឺលោកធ្វើទារុណកម្ម ដោយខ្លួនឯងលើមនុស្សយ៉ាងតិចបំផុតតែពីរនាក់ទេ តើត្រឹមត្រូវដែរឬទេចំពោះចម្លើយនេះ?

**ឆ៖** ផ្ទាល់ដៃមែន យ៉ាងតិចពីរនាក់ ។ អ្នកផ្សេងទៀត ខ្ញុំមិនចាំទេ ។ ប៉ុន្តែ ពីរនាក់ហ្នឹងខ្ញុំចាំទាំងរឿងរ៉ាវល្អិត លោកព្រះរាជអាជ្ញាចង់ឲ្យខ្ញុំបញ្ជាក់ឲ្យល្អិតក៏បានដែរ ។ ប៉ុន្តែ អ្នកផ្សេងទៀត ប្រហែលជាខ្ញុំធ្វើដែរតែ ប្រហែលជាមិនចាំល្អិតទេ ។

**ស៖** ដូច្នេះវាអាចដែរថា ក្នុងពេល៤ឆ្នាំហ្នឹង គឺលោកធ្វើទារុណកម្មលើសពី២នាក់ ប៉ុន្តែលោកអត់ចាំ តើនេះជាចម្លើយរបស់លោកដែរឬទេ?

**ឆ៖** ពិតៗ ។

**ស៖** ហើយព្រឹកនេះចៅក្រម ឡាវែន៍ បានសួរលោក ហើយខ្ញុំគិតថា វាជាសំណួរមួយច្បាស់ពីចៅក្រម ថា លោកខ្លួនឯងបានចូលរួមនៅក្នុងការកំទេចនរណាម្នាក់ដែរឬទេ? គឺក្នុងពេលបកប្រែយើង

អត់ទទួលបានការឆ្លើយតបទៅនឹងសំណួររបស់លោកចៅក្រម ។ ដូច្នេះ ខ្ញុំសួរដោយសាមញ្ញក្នុងពេល ៤ឆ្នាំ នៅមន្ទីរ ម-១៣ ថាតើលោកខ្លួនឯងបានសម្លាប់នរណាម្នាក់ដោយមូលហេតុណាមួយដែរឬទេ?

**ឆ៖** ខ្ញុំសូមនិយាយសរុបតែម្តងទៅ ។ ផ្ទាល់ដៃខ្ញុំ ខ្ញុំមិនសម្លាប់មនុស្សទេ ទាំងនៅម-១៣ ទាំងនៅស-២១ ។ ក៏ប៉ុន្តែ បើបញ្ជានៅម-១៣ គឺពិតជាចេញពីខ្ញុំទាំងអស់ ។ នៅស-២១ ខ្ញុំយល់ស្រប ហើយនិងពេលខ្លះខ្ញុំបញ្ជាដែរ ។

[១៥:៣៦:១៥]

**ស៖** លោកចាំទេថាលោកនៅម-១៣ លោកមានអាវុធកាន់ទៅដើរជាមួយ ថាតើត្រឹមត្រូវដែរឬទេជានិច្ចកាល?

**ឆ៖** កាំភ្លើងខ្ញុំមាន ប្តូរញឹក ។ ប្តូរសឹងតែគ្រប់ម៉ាក ជម្រាបលោកចៅក្រម-- អ៊ូនែ លោកព្រះរាជអាជ្ញាឲ្យច្បាស់ ។ មុនដំបូងខ្ញុំ មាន *អ៊ែកស្គាល់* ក្រោយមកខ្ញុំមាន *ស្ទីតអេប៊ីសិទ្សរ៉ូវែរ* ។ ដល់ក្រោយមកខ្ញុំប្តូរមកកាំភ្លើងចិន ខ្ញុំប្តូរទៅកាំភ្លើងសូវៀត ខ្ញុំប្តូរគ្រប់តែម៉ាក ។ ក៏ប៉ុន្តែ ខ្ញុំមិនដែលបានកាន់ជាប់នឹងខ្លួនទេ មិនងាយទេ ។ ហើយដល់ក្រោយមកខ្ញុំប្តូរ *ប៉េប៊ីអ៊ែកសាល* តូច ។ *កាលីពេ*តូច ។ ខ្ញុំប្តូររហូត ។ ហើយកាំភ្លើងខ្ញុំមិនដែលឲ្យគេឃើញទេ លាក់តែក្នុងខោ ។ ខ្ញុំដើរទៅភូមិឃុំខ្ញុំមិនដែលទាំងកាន់កាំភ្លើងផង ។ ទៅលេងផ្ទះបុគ្គលិកខ្ញុំម្នាក់នៅភូមិកុមារមាស ខ្ញុំមិនដែលទាំងកាន់កាំភ្លើងទៅផង នេះខ្ញុំជម្រាបត្រង់ ។ ខ្ញុំអត់បង្ហាញកាំភ្លើងឲ្យគេឃើញទេ មិនដែលងាយអ្នកណាឃើញកាំភ្លើងខ្លីខ្ញុំទេ ។ ខ្ញុំមាន មានតាំងពីទើបនឹងកកើតម-១៣ ម្លេះ ។ មានកាំភ្លើង ។

**ស៖** ថាតើនៅម-១៣ នោះដែលលោកជឿថា លោកត្រូវតែជ្រើសរើសក្មេងៗដើម្បីធ្វើការងារទាំងអស់នេះដូចជាការសួរចម្លើយ ការធ្វើទារុណកម្ម ការឃុំខ្លួន និងការកម្ទេច។ ក្មេងៗគឺវាងាយស្រួលក្នុងការហ្វឹកហាត់ ដោយសារតែគាត់គឺជាក្រដាសសមួយ គឺនៅម-១៣ ហើយដែលលោកសន្និដ្ឋាន អ៊ីចឹងឬក៏យ៉ាងម៉េច?

**ឆ៖** គោលគំនិតនេះមិនមែនជាគោលគំនិតថ្មីសម្រាប់អ្នកបដិវត្តន៍ទេ ។ ជាគោលគំនិតរបស់អ្នកបដិវត្តន៍សាកលលោក ។ ប្រទេសចិនគេមានរឿងមួយឈ្មោះរឿងនែ៎ "ចង្កៀងក្រហម" គេនិយាយថា "កូនអ្នកក្រឆាប់ដឹងក្តី ដាក់ពូជអីដុះពូជហ្នឹង" ។ យើងខ្ញុំទទួលពិសោធន៍របស់គេហ្នឹងមកអនុវត្តមែនតាមពិត ។ ដូច្នេះ យកគេមកដូចខ្ញុំបានជម្រាបលោកចៅក្រម ឡាវែន៍ ព្រឹកមិញអ៊ីចឹង ដើម្បីឲ្យគេយឺតយោងខ្ញុំ ។

[១៥:៣៨:៥៨]

វណ្ណភាពរបស់ខ្ញុំបក្សមិនសូវពេញចិត្តទេ គេហៅថា *សឺមី អាំងតេលិចអ៊ែល* (*Semi-intellectuelles*) នោះ អាមូលធន នោះ ។ បក្សមិនសូវពេញចិត្តទេ ដូច្នេះយើងខ្ញុំជ្រើសរើសកសិករក្រមកដែលម្តាយឪពុកគេដែលមិនដែល មានរឿងយកមកចិញ្ចឹមបីបាច់ថែរក្សា ហើយអប់រំគេឲ្យជួយការងារដើម្បីដល់ទៅអនាគតបក្សមើល ឃើញខ្ញុំ ថាខ្ញុំជ្រើសរើសបុគ្គលិកសុទ្ធតែអ្នកក្រីក្រមែន បក្សជឿទុកចិត្តខ្ញុំជ្រុងហ្នឹងមួយ នេះជាប្រាកដ ។ ដូច្នេះ អារឿងក្រដាសសអីៗ ខ្ញុំឆ្លើយប្រាកដណាស់ជាគោលជំហរខ្ញុំដែលខ្ញុំបានបណ្តុះបណ្តាលមកយូរហើយជំនឿជឿជាក់លើវណ្ណៈក្រីក្រហ្នឹង ពិតហើយ ក្មេងហ្នឹងពិត យកមកដើម្បីឲ្យគេ ជួយយឹតយោងខ្ញុំ ពិត ។

**ស៖** ប៉ុន្តែជាថ្មីម្តងទៀត ពួកគេមិនមែនជាអ្នកសម្លាប់ល្អទេ ដោយសារតែវណ្ណៈរបស់គេ ។ គឺថាពួក គេគឺក្មេង ហើយលោកអាចបង្ខំគេឲ្យធ្វើការសម្លាប់ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បើនិយាយអំពីរឿងហ្នឹង ច្បាស់ហើយវណ្ណៈគេល្អយើងចាប់គេឲ្យបំពេញឧក្រិដ្ឋកម្មវាតិចឬច្រើន ទម្ងន់បទឧក្រិដ្ឋនោះវាធ្លាក់មកលើខ្ញុំមួយជាន់ហើយមួយជាន់ទៀត ឥតប្រកែកទេ នេះជាការពិតខ្ញុំទទួល ប្រាកដ ។

**ស៖** អ៊ីចឹងចម្លើយបានន័យថាពិតមែន?

**ឆ៖** មែនៗ ។

**លោក រ៉ូប៊ឺត ពើទីត៖**

សូមជម្រាបថា ខ្ញុំអស់សំណួរហើយលោកចៅក្រម ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត សូមជូនវេទិកានេះទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដោយសុំធ្វើតាមលំដាប់ ពីក្រុមមេធាវីតំណាងក្រុមមួយ ។ សូមអញ្ជើញបាទ សូមជម្រាប សូមប្រាប់ឈ្មោះផង ។

[១៥:៤១:២៧]

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សូមគោរពលោក លោកស្រី ។ ខ្ញុំអាឡាំងវ៉ែនណឺ ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ខ្ញុំសូមសួរសំណួរពីរ ។

**សៈ** ថាតើ ម-១៣ នេះមានន័យយ៉ាងម៉េច ហេតុអ្វីបានវាហៅឈ្មោះ ទីបី ហើយវាជាមន្ទីរក្នុងពិសេស ដែលគេយោងដល់ទីបីនោះ ឬក៏មានមូល ហេតុអីដែលគេហៅ ម-១៣ នេះ ។

**ឆៈ** សុំទោស មេក្រូដាច់ៗ សូមលោកមានប្រសាសន៍ម្តងទៀត ។ សុំទោសអានេះវាដាច់ៗ ឮមិនច្បាស់ ។

**សៈ** សំណួរគឺថា តើម-១៣ នេះមានន័យយ៉ាងម៉េចជំនួសឲ្យអីគេ? ហេតុអ្វីបានគេយោងឈ្មោះថាអ៊ីចឹង? ដោយសារតែវាជាមន្ទីរនៅក្នុងមន្ទីរក្នុងភូមិភាគពិសេស ឬក៏យ៉ាងម៉េច? ហេតុអ្វីបានជាគេយោង ឈ្មោះថាម-១៣ អ៊ីចឹង?

**ឆៈ** "ម" ហ្នឹងមានន័យថា "មន្ទីរ"។ ចំណែក១៣ ហ្នឹងគឺលេខខាង បងវន ហ្នឹងគាត់ដាក់ឲ្យខ្ញុំវាប្លែកពីគេ ។ មន្ទីរនៅភូមិភាគពិសេសគេសុទ្ធតែមន្ទីរលេខបីខ្ទង់ ។ មន្ទីររបស់ភូមិភាគឈ្មោះ មន្ទីរ៣០៥ ។ មន្ទីរឃោសនាការដែលគេទទួលភារៈសរសេរកាសែតអីៗហ្នឹង មានឈ្មោះមន្ទីរ៣០៦ គ្រប់គ្រងដោយអតីតវិស្វករម្នាក់ ឈ្មោះ ជី គឹមអាន ។ មន្ទីរសេដ្ឋកិច្ចឈ្មោះមន្ទីរ៣០៧ ដែលគ្រប់គ្រងដោយអតីត វិស្វករម្នាក់ដែរ ឈ្មោះ សៀង ប៉ោសែ ។ ឯចំណែកមន្ទីរនីរសារ ឈ្មោះមន្ទីរ៣០៩ ។ ដោយឡែកមន្ទីរខ្ញុំ ដែលមានបក្សជនតែម្នាក់ឯង ហើយមន្ទីរនោះនៅដាច់ឆ្ងាយពីគេ គេដាក់ថាមន្ទីរម-១៣ អ៊ីចឹងទៅ ។ ខ្ញុំឆ្ងល់ដែរថារឿងអី ។ ខ្ញុំមិនអាចពន្យល់បានទេ ឈ្មោះហ្នឹងគេដាក់ឲ្យមកអ៊ីចឹង ។

**សៈ** ក្នុងពេលការងាររបស់លោកនៅទីនោះ ជាប្រធានទទួលបន្ទុកម-១៣ ថាតើមានបុគ្គលណាម្នាក់ ពីជួរដឹកនាំខ្មែរក្រហមគាត់មកទស្សនកិច្ចនៅម-១៣ ដែរឬទេ?

**ឆៈ** អ្នកដែលប៊ានចូលមន្ទីរ១៣ ញឹកញាប់ជាងគេគឺ ឆាយ គឹមហ៊ ។ លោកតា ហួត ហេង ហៅ ប៉ាល់ លេខាតំបន់៣២អញ្ជើញទៅម្តង ។ វស់ ជាថូ ហៅ ជាតិ អតីតអ្នកការទូតប្រធានមន្ទីរ៣០៥ អញ្ជើញទៅពីរដង ក្រៅពីនោះ មិត្តសំ ឈ្មោះដើម ម៉ៃ សុខន ជាមិត្តភក្តិខ្ញុំ ដែលជាប់គុកជាមួយគ្នាតែញឹក ក្នុងឋានៈគេប្រធានមន្ទីរ២០១ ក្រៅពីនោះ គ្មានអ្នកធំណាចូលទៅទេ ។

[១៥:៤៥:៣៤]

**សៈ** ខ្ញុំមានសំណួរមួយ ទាក់ទងទៅនឹងប្រព័ន្ធរាយការណ៍ ហើយគឺការឆ្លើយតបទៅនឹងសំណួររបស់លោក រ៉ូបឺត ពើទីត គឺលោកបានពន្យល់ថា ពន្យល់ពិស្តារទាក់ទងនឹងប្រព័ន្ធនៃការរាយការណ៍គឺព័ត៌មានរបស់អ្នកទោស ចម្លើយសារភាព និងឯកសារផ្សេងៗដែលបញ្ជូនទៅ តាម៉ុក ។ ហើយនៅពេលដែលចៅក្រម ឡាវែន៍ បានសួរសំណួរលោកថ្ងៃនេះ ថាតើមានឧទាហរណ៍ជាក់លាក់ដែរឬទេ ទាក់

ទងទៅនឹងការរាយការណ៍ទៅថ្នាក់លើ។ ឧទាហរណ៍លោកបាននិយាយថា លោកទៅរាយការណ៍នៅពេលដែលមានការលេចជន់ទឹក ហើយលោករាយការណ៍ នៅពេលដែលមានការសម្លាប់ មុនពេលសម្លាប់ជាដើម ហើយលោកបានបាននិយាយថា លោកទៅរាយការណ៍អំពីបញ្ហាបុគ្គលិក និងវិន័យក្នុងចំណោមបុគ្គលិកនៅម-១៣ ។ ដូច្នេះ ចំពោះការរាយការណ៍ ដូច្នេះ ថាតើលោករាយការណ៍ជូនអ្នកណាគេ?

**ឆ៖** សូមជម្រាប លោកមេធាវីថា មានខ្ញុំរាយការណ៍ឲ្យ តាម៉ុក បានតិចណាស់។ ខ្ញុំជួបតាម៉ុកប្រហែលមួយជីវិតនេះតែបួនដងទេកាលនៅម-១៣ ប៉ុណ្ណឹង ។ បួនដង ដូចខ្ញុំនិយាយជូនលោក វ៉ូបឺតពើទីត ព្រឹកមិញ ដូចនិយាយដប់ដងយ៉ាងច្រើនប៉ុណ្ណោះ ។ ភ្លេចអស់ហើយ ។ ប៉ុន្តែតិចណាស់ ញឹកញាប់ខាងភូមិភាគនិរតី យើងខ្ញុំរាយការណ៍ឲ្យ ជូ ជេត ហៅ ស៊ី អនុប្រធាន អនុលេខាភូមិភាគនិរតី ឬក៏យើងខ្ញុំត្រូវការទៅរាយការណ៍ឲ្យលោកតា ហួត ហេង ហៅ ប៉ាល់ នេះខាងភូមិភាគនិរតី ។ លេខាតំបន់៣២ ហួត ហេង ហៅប៉ាល់ ។ ដោយឡែកខាងភូមិភាគពិសេស ដំបូងខ្ញុំត្រូវទៅរាយការណ៍ជូន វន វ៉េត បន្ទាប់មកខ្ញុំត្រូវរាយការណ៍ជូនលោកគ្រូ សុន សេន ។

ដោយឡែក តែការងារផ្ទៃក្នុងបក្ស រឿងផ្ទាល់ខ្លួន រឿងបុគ្គលិក អី១ខ្លះ ដែលធ្វើការងារហ្មត់ចត់ និងមិនហ្មត់ចត់ អាហ្នឹងយើងរាយការណ៍កន្លះខែម្តងរាល់ពេលប្រជុំទិតៀន និងស្វ័យទិតៀន ។ នេះជាការងារបក្សទៅផ្សេង ។ ការងារនគរបាលវាទៅផ្សេង ត្រូវឡើងទៅដល់លើ ការងារបក្ស យើងខ្ញុំរាយ-ការណ៍ជូនលេខាសាខា ។

[១៥:៤៨:៣៨]

**ស៖** នាពេលនេះ ឆ្លើយតបសំណួររបស់លោកចៅក្រម ឡាវ៉ែន៍ ។ លោកបានពន្យល់កាលពីម្សិលមិញថា អ្នកក្រមកពីតំបន់សត្រូវត្រូវបានចាប់ចងនៅតំបន់សេរី ហើយបានបញ្ជូលនៅម-១៣ ហើយនៅថ្ងៃនេះ លោកបានពន្យល់ថា ពន្យល់ម្តងទៀត ចំពោះលោកចៅក្រម ឡាវ៉ែន៍ ថា អ្នកដែលរស់នៅជិតតំបន់សត្រូវនោះគឺបញ្ជូនមកម-១៣ ហើយខ្ញុំដូចជាស្តាប់អត់ច្បាស់ ។ ខ្ញុំចង់បញ្ជាក់ថា ត្រឹមត្រូវដែរឬទេ គឺអ្នកក្រពីរប្រភេទ ដែលលោកបានលើកឡើងកាលពីម្សិលមិញ គឺហើយអ្នកភូមិហ្នឹង គឺអត់មានធ្វើការប្រព្រឹត្តឧក្រិដ្ឋកម្មបទល្មើសទេនៅពេលដែលគេបញ្ជូនមកម-១៣។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** អ្នកក្រដែលចូលពីដីលទ់នលមកដីរំដោះ ធម្មតាតែល្ពបគេចាប់បាន គេបញ្ជូនតាមខ្សែរយៈមកមន្ទីរ១៣ហើយ ឲ្យកម្ទេច ព្រោះគេយល់ថាជាខ្មាំង មកយកការណ៍ដើម្បីឲ្យទ័ពចូលវាយលុក ឬក៏

ដើម្បីឲ្យគ្រាប់បែកកម្ទេច ។ ដូច្នេះ គេចាត់ទុកជាគិញគេបញ្ជូនមកដល់ម-១៣ យើងត្រូវតែកម្ទេច សួរចម្លើយហើយកម្ទេច ។

ចំណែក អ្នកក្រដែលនៅក្នុងតំបន់ប្រទាញប្រទង់ ខ្ញុំសូមបញ្ជាក់ជូនលោកមេធាវីថា ដោយឥត--ពាក្យភាសាខ្មែរដែលហៅថាតំបន់ត្រទាញប្រទង់នេះ គឺព្រឹកខ្មាំងចូល យប់បដិវត្តន៍ចូល ។ ថ្ងៃខ្មាំងចូល យប់បដិវត្តន៍ចូល ឬក៏បដិវត្តន៍ទើបនឹងទៅកាន់កាប់ហ្នឹងហៅថាតំបន់ប្រទាញប្រទង់ មិនដឹងជាថ្ងៃស្អែក ឬខានស្អែក ខ្មាំងមកយកទៅវិញទេ អាហ្នឹងហៅថាតំបន់ប្រទាញប្រទង់ ។

ម្តងនោះ សុន សេន គាត់ចាប់មនុស្សពីភូមិមួយហៅថា ភូមិពោធិ នៅឆ្ងាយពីតំបន់នៅឆ្ងាយពីដីខ្មាំងបន្តិចដែរ ប៉ុនគាត់ហៅថា “ភូមិសន្តិសម្ព័ន្ធ” ។ ភូមិសន្តិសម្ព័ន្ធនោះ គឺភូមិមិនធ្វើសកម្មភាពច្បាំងនឹងខ្មាំងទេ នាំគ្នាបបួលចរចាសន្តិភាព ចុះចូលខ្មាំង ។ ភូមិនោះឈ្មោះភូមិពោធិ ។ គាត់ចាប់មកទាំងអស់មួយភូមិ ហើយប្រគល់មកឲ្យម-១៣ ម៉្ភៃពីរគ្រាន់តែស្នាក់នៅ គិតទម្រាំគាត់រៀបចំឡានអីបញ្ជូនទៅបាត់ដំបង ។ ហ្នឹងក៏អ្នកក្រដែរ មិនជាមានប៉ុន្មានទេ នៅភូមិពោធិនោះ ។ ហើយគាត់ឲ្យទុកតែម្នាក់ពីរប៉ុណ្ណឹងសម្រាប់សួរចម្លើយ ។ ឧបាសង្គ្រាជជាងគេឈ្មោះ តាខាត់ ដែលជាចាស់ទុំនៅក្នុងភូមិនុ៎ងមែន ហ្នឹងក៏អ្នកក្រ ។ រឿងសំខាន់មួយទៀត ដែលមានខ្ញុំនៅមានការតក់ស្លុត ហើយខ្ញុំធ្លាប់ចុះឡើងទៅហូបចុកនៅហ្នឹងញឹកញាប់ គឺនៅភូមិពាម ឃុំអមលាំង ហ្នឹងតែម្តង កណ្តាលផ្សារអមលាំងហ្នឹង មិនជាអ្នកក្រទេ ជាអ្នកមាន ។ ក៏ប៉ុន្តែ ខ្ញុំធ្លាប់ស្គាល់ គេចាប់មកបើតាមខ្ញុំសរុបប្រហែលជាទាំងអស់ក្នុងមួយពេលហ្នឹងជាប់៥០នាក់ ឬឡើងលើស៥០នាក់បន្តិចបន្តួចផង ។ នេះក៏សុទ្ធតែរឿងគេចាប់ចងទាំងអស់សរុបមក វាមានអ្នកក្រមកពីដី លន់ នល់ និងវាមានអ្នកក្រនៅហ្នឹងជាយតំបន់រំដោះ វាមានអ្នកក្រនៅក្នុងតំបន់រំដោះ អ្នកក្រនិងអ្នកមានប្រជាជននៅក្នុងតំបន់រំដោះរួចហើយ ។

នេះរឿងរ៉ាវជាឧក្រិដ្ឋកម្មដែលកើតឡើងនៅម-១៣ ។

[១៥:៥២:៣៩]

**ស៖** ហើយចំពោះមនុស្សប្រភេទទីពីរ គឺលោកមានការធ្វើការសួរយកចម្លើយពីបុគ្គលទាំងអស់នោះដែរឬទេ តាមដែលអ្វីដែលលោកចាំ?

**ឆ៖** គេទុកឲ្យខ្ញុំសួរចម្លើយ មន្ទីរ១៣សួរចម្លើយម្នាក់ជាសំខាន់ ។ ក្រៅពីនោះមានតូចតាចពីរ-បីនាក់ទៀតដែរ ។ តែម្នាក់ជាសំខាន់ឈ្មោះ តាខាត់ ។ តាខាត់ហ្នឹង ខ្ញុំប្រគល់ឲ្យ មិត្តប៉ុន សួរ ដែលជាកម្មាភិបាលសួរចម្លើយជើងឆើតរបស់ខ្ញុំ ។ ខ្ញុំប្រគល់ឲ្យ មិត្តប៉ុន សួរ តាខាត់ ហ្នឹង ។

**ស៖** ចំពោះប្រភេទ មនុស្សប្រភេទទីពីរ ថាតើពួកគេហ្នឹងត្រូវបានរងទារុណកម្មដែរឬទេ?

**ឆ៖** អ្នកដែលយើងមិនសម្លាប់ យើងមិនវាយទេ មិនធ្វើទារុណកម្មទេ អ្នកដែលយើងបញ្ជូនទៅកន្លែងផ្សេងទៀត គឺគ្មានទារុណកម្មសោះ ។

**ស៖** លោកបាននិយាយថា ឆ្លើយតបទៅនឹងសំណួរលោកចៅក្រម ឡាវែន៍ លោកតាមដានការធ្វើទារុណកម្ម យ៉ាងកៀកតែម្តង យ៉ាងប្រកិតតែម្តង ។ លោកអាចចាំទេថា លោកមានវត្តមានប៉ុន្មានដងនៅម-១៣ នៅពេលដែលអ្នកទោសត្រូវបានធ្វើទារុណកម្ម ដោយអ្នកសួរចម្លើយរបស់លោក?

**ឆ៖** តាមដានកិតនេះមិនមែនបានន័យថា ខ្ញុំទៅឈរមើលគេធ្វើហ្នឹងរាល់តែលើកទេ ។ រឿងទៅឈរមើលគេធ្វើដូចជាតិចណាស់ៗ ។ ក៏ប៉ុន្តែ គេធ្វើហើយមករាយការណ៍ឲ្យខ្ញុំនិយាយគ្នា តើវាចំណេញឬវាខាតវាបានប្រយោជន៍ ឬមិនបានប្រយោជន៍អាហ្នឹង អត់ដែលខានទេចំពោះកម្មាភិបាលសួរចម្លើយថ្មី ។ ចំពោះកម្មាភិបាលសួរចម្លើយចាស់របស់ខ្ញុំ ដូចជា មិត្តប៉ុន គេធ្វើទារុណកម្មអី ខ្ញុំមិនសូវដែលបានដេញដោលសួរទេ ច្រើនតែជួនអី យូរៗជួបសួរគេម្តង ។ អាហ្នឹងមែនដូច្នេះបើអ្នកសួរចម្លើយថ្មី គឺគេធ្វើហើយ ខ្ញុំហៅមកសួរហើយ ម៉េច យ៉ាងម៉េច អីយ៉ាងម៉េច សួរតាមដានណែនាំពន្យល់ ។

[១៥:៥៥:១៧]

**ស៖** តើលោកបានដឹងដែរឬទេក្នុងពេលដែលលោកទទួលបន្ទុកម-១៣ថាលោកដឹងថាអ្នកទោសណាមួយត្រូវបានគេកប់ទាំងរស់ តើលោកបានដឹងដែរឬទេ?

**ឆ៖** ខ្ញុំគ្មានបញ្ជាឲ្យអ្នកណាយកអ្នកទោសទៅកប់ទាំងរស់ទេ ។ ដូច្នោះ គ្មាននរណាប៊ានធ្វើរបៀបនេះជាមួយនឹងខ្ញុំទេ ។ អ្នកឯងរឿងឥឡូវហ្នឹង ប៊ានតែធ្វើប៉ុណ្ណឹង ។

**ស៖** ហើយឆ្លើយសំណួរ របស់លោកចៅក្រម ឡាវែន៍ ខ្ញុំគិតថាព្រឹកមិញ ឬក៏ម្សិលមិញ លោកបាននិយាយថា ស្ត្រីត្រូវបានឲ្យមុជទឹកក្នុងស្ទឹងនៅខែរងា ហើយលោកធ្វើការដកបទពិសោធន៍ តើលោក គឺលោកមានន័យយ៉ាងម៉េចនៅពេលដែលលោកថា មិនទទួលបានលទ្ធផលនោះ?

ឆ៖ ខ្ញុំចង់ជៀសវាងមិនរ៉ៃ មិនព្រមរ៉ៃ ។ ដូច្នេះ ចង់លមើលតើទៅមុជទឹកនេះ ហើយមកហាលខ្យល់រងានេះធ្វើឲ្យសាមីខ្លួនគេហ្នឹងសុខចិត្តសារភាពទេ ដែលខ្ញុំថាមិនបានផលពីព្រោះអី? ពីព្រោះការឆ្លើយរបស់គេនៅដដែលៗ ។ ដូច្នេះ ដដែលនេះ វាមិនដឹងជាវាត្រង់ប៉ុណ្ណឹង ឬក៏គេលាក់យើងអត់ទាន់ប៊ានថា ។ ក៏ប៉ុន្តែយើងអត់ប៊ានធ្វើតទៅទៀតព្រោះគេស្រី ។ យើងខ្ញុំទៅពីរនាក់ក៏ដោយ

ស្រួលមិនស្រួលអាចទប់អារម្មណ៍មិនបានដែរណា ខ្លួនគេទទឹក ក្រណាត់ខោអាវគេវារីបទៅនឹងសាច់អស់ទៅ ដូច្នេះ ភ័យខ្លាចភ្លាត់ខ្លួនឯងទៅនឹងសីលធម៌កំបុតកហើយ ដូច្នេះ លែងហ៊ានធ្វើតទៅទៀត ។

**ស៖** ឥឡូវនេះ ខ្ញុំមានសំណួរមួយចំនួនទៀត ។ ចៅក្រម ឡាវែន៍ សួរលោកពិស្តារអំពីត្រង់សេ និងរណ្តៅខ្ញុំចង់សួរ សំណួរជាក់លាក់ អ្វីតាមអ្វីដែលលោកចាំ និងដឹងនៅម-១៣ ថាតើបុគ្គលណាម្នាក់ត្រូវបានគេធ្វើទារុណកម្មនៅក្នុងរណ្តៅដែរឬទេ?

[១៥:៥៨:២៥]

**ឆ៖** បើតាមខ្ញុំចាំ គ្មានបុគ្គលណាម្នាក់ធ្វើទារុណកម្មនៅក្នុងរណ្តៅទេ ។ ក៏ប៉ុន្តែខ្ញុំជឿថា មានមនុស្សដែលចូលទៅក្រោយអាចច្រឡំ អារណ្តៅដែលជីក ខ្ញុំជីកម្ខាងស្មឹងណា ជិតរណ្តៅកប់សពនោះ ។ ខ្ញុំបោះបង្គោលពីរសម្រាប់ចងអង្រឹងខ្លួនឯងដេក អាបង្គោលពីរនោះ ខ្ញុំបោះសម្រាប់ចងអង្រឹងខ្លួនឯងដេកវរៗ គេច្រឡំថា ជារណ្តៅព្យួរមនុស្សអីៗឯណានោះក៏មិនដឹង ។ តាមពិតជារណ្តៅដែលខ្ញុំចងអង្រឹងដេក ហើយខ្ញុំត្រូវការសួរចម្លើយ ពេលដេកថ្ងៃ ការពារខ្លួនផង គ្រាប់ផ្លោង-- អ៎ន៎ែ ពីបេហាពីរនោះ ។

**ស៖** ចុងក្រោយ ខ្ញុំមានសំណួរនៅម-១៣“ខ” ដែលលោកឆ្លើយសំណួរលោកចៅក្រម ឡាវ៉ែន៍ លោកបាននិយាយថា បុគ្គលត្រូវបានបញ្ជូនទៅឲ្យរៀនសូត្រ នៅពេលដែលលោកនិយាយថា រៀនសូត្រឡើងវិញនេះ តើមានន័យយ៉ាងម៉េច?

**ឆ៖** ដែលហៅថារៀនសូត្រឡើងវិញ ឬអប់រំ គេយកទៅអប់រំនេះ គឺយកទៅទុកចោលនៅនុ៎ងយប់មនុស្សមួយចំនួនដេកតាមផ្ទះ ក៏ប៉ុន្តែមនុស្សមួយចំនួនដែលគេចាប់អារម្មណ៍សង្ស័យខ្លាំង ដេកនៅក្នុងមន្ទីរឃុំឃាំង ។ មន្ទីរឃុំឃាំងហ្នឹងជាផ្ទះមួយវែង ទទឹងប្រហែលជា២ម៉ែត្រកន្លះ បណ្តោយប្រហែលជា១០ម៉ែត្រអីហ្នឹង ។ មិត្តស៊ុំ គាត់ទិញឈើអាឈើមេ កម្រាស់ ៥ហ៊ុន ហើយទទឹងមួយតឹក យកទៅវ៉ៃ ។ ដូច្នេះ អ្នកណាដែលមានលក្ខណៈដែលគេភ័យខ្លាចរត់ គេដាក់ឲ្យនៅអាក្នុងផ្ទះហ្នឹង ។ ឯចំណែកអ្នកផ្សេងទៀត ដែលគេមិនភ័យខ្លាចរត់គេដាក់ឲ្យនៅក្រៅផ្ទះឃុំឃាំងហ្នឹង យប់គេមិនចាក់សោរទេ តែគេយាមពីក្រៅ គេមិនឲ្យដើរទេ វាស់ដីឲ្យដើរយប់ ។

[១៦:០០:៤៧]

សរុបមក ថ្ងៃពួកនេះធ្វើចម្ការដំឡូងមី ហើយយប់អ្នកដែលត្រូវដេកក្នុងឃុំឃាំងក៏ដេកទៅ តែអត់មានដាក់ខ្នោះជើងទេ គ្រាន់តែគេចាក់សោរ ។ មួយរយៈដែល បងអន គាត់យល់ឃើញថា គួរដោះលែង

ទៅវិញ គាត់ដោះលែង ។ ប្រធានតំបន់ជាអ្នកដោះលែង ប្រធានតំបន់ជាអ្នកចាប់ប្រគល់ឲ្យ ម-១៣“ខ” ទុកមួយរយៈសិន គេតាមដានមើល ហើយដាំដំឡូងមី ហើយដល់កាលគេត្រូវដោះលែង ប្រធានតំបន់គេដោះលែងទៅវិញ ។ អាម-១៣“ខ” នេះវាចាំតែឃុំឃាំង ហើយនឹងដោះលែងទៅឲ្យគេប៉ុណ្ណឹង ហើយកុំឲ្យរត់រួច ប៉ុណ្ណឹងឯង ។ ក៏ប៉ុន្តែបើសិនជា អ្នកខ្លះដែលប្រធានភូមិភាគគេយល់ថា ត្រូវបញ្ជូនពីម-១៣“ខ” មក ម-១៣“ក” អា ម-១៣“ខ” វាបញ្ជូនមកឲ្យ ម-១៣“ក” តាមសេចក្តីសម្រេចពីខាងលើ ។ នេះរឿង ម-១៣“ក”, “ខ” វាប៉ុណ្ណឹង ។

**ស៖** ដូច្នេះយោងតាមលោក គឺមិនមែនជនរងបង្ខំធ្វើការទេ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ថាបង្ខំក៏ថាបាន ព្រោះយើងខ្ញុំកកំណត់ពេលវេលាធ្វើការៗ យើងថាបង្ខំឲ្យធ្វើការក៏ថាបានដែរ ព្រោះធ្វើការដែលបានផលមកមិនមែនទៅឲ្យបុគ្គលហ្នឹងទេ គឺទុកឲ្យ ម-១៣“ខ” ។

**ស៖** លោកចៅក្រម ខ្ញុំមានសំណួរមួយទៀត តើខ្ញុំអាចសួរសំណួរថែមមួយទៀតបានដែរឬទេ? អរគុណលោកប្រធាន ។

តាមអ្វីដែលលោកដឹង តើមាននរណាស្លាប់ដោយសារធ្វើការងារហួសកម្លាំងនៅ ម-១៣ “ខ” ដែរឬទេ?

[១៦:០៣:១២]

**ឆ៖** តាមខ្ញុំចាំដូចគ្មាន ។ នេះតាមខ្ញុំចាំទេ ជាក់ស្តែងអាហ្នឹង វាអត់ទាន់មានភស្តុតាងអីបញ្ជាក់ទេ ។ តាមខ្ញុំចាំដូចគ្មាន ។

**លោក អាឡាំង វ៉ែនណឺ៖**

អរគុណៗលោក លោកស្រីចៅក្រម ខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ប្រសិនជាមានសូមអញ្ជើញ ។

**សួរដោយលោក យុង ផានិត៖**

អរគុណលោកប្រធាន ខ្ញុំមេធាវី យុង ផានិត ហើយមានសំណួរ ពីរសំណួរសម្រាប់សួរទៅជនត្រូវចោទ ។

ស៖ សំណួរទីមួយ ខ្ញុំសុំសួរឡើងវិញទាក់ទងទៅនឹងបញ្ហាដែលគាត់ គាត់បានជម្រាបថា គាត់បានចូលបក្ខជនត្រៀមហ្នឹង ដែលលោក កែ ពក អ្នកបញ្ចូល។ ហើយក្រោយមកគាត់បានជាប់ពន្ធនាគារ

នៅតែ៣ ។ ហើយគាត់បញ្ចូលបក្ខជននៅក្នុងពន្ធនាគារ គឺចង់ដឹងថា តើការបញ្ចូលបក្ខជនរបស់គាត់ពេញសិទ្ធិនៅក្នុងពន្ធនាគារបញ្ចូលដោយវិធីណា? ហើយអ្នកណាបញ្ចូលនៅពេលនោះ?

សំណួរទីពីរ ខ្ញុំចង់ជម្រាបសួរគាត់ថា តើរឿង ម-១៣ និងតំបន់ដែល លន់ នល់ គ្រប់គ្រងហ្នឹង នៅចម្ងាយគ្នាប៉ុន្មាន? ជាពិសេសតំបន់ដែលគ្រប់គ្រងដោយ នរោត្តម ច័ន្ទរង្សី ដែលគាត់នៅច្បាមនតើចម្ងាយព្រំប្រទល់នៃការតំបន់ហ្នឹង វាចម្ងាយគ្នាប៉ុន្មាន? សូមអរគុណ ។

[១៦:០៥:០០]

**ឆ៖** សូមបញ្ជាក់លោកមេធាវី យុង ផានិត ដូចតទៅ៖

ខ្ញុំចូលធ្វើបដិវត្តន៍យ៉ាងប្តូរផ្តាច់នៅថ្ងៃ-- នៅខែតុលា ១៩៦៤ ។ ប្រហែលជានៅក្នុង-- ខ្ញុំភ្លេចហើយ ។ ខ្ញុំបានចូលបង្គោលដូចក្នុងឆ្នាំ១៩៦៦ គេហៅអង្គការបង្គោលនោះ ។ ហើយដល់ឆ្នាំ១៩៦៧ វន វ៉េត គាត់ហៅខ្ញុំទៅធ្វើការ។ ទីមួយ គាត់ឲ្យឧទ្ទេសនាមថា មិត្តបក្សអនុញ្ញាតឲ្យមិត្តចូលបក្ស ជាបក្ខជនត្រៀម តែកន្លែងនេះខ្ញុំមិនទាន់ទេ មិត្តទៅដល់ប្រាប់គេថា ខ្ញុំអនុម័តហើយ ថាបក្សខាងលើអនុម័តហើយ ឲ្យគេបញ្ចូលមិត្តបក្ខជនត្រៀមទៅ ។ ទៅដល់ខ្ញុំសិសាក់នៅកំពង់ធំ-- អូ!សុំទោស នៅបឹងធំ ចូវទូកឲ្យ កុយ ធួន ធ្វើការរហូតយូរដែរ ។ ទាល់តែជួបបង ពក ធ្វើជាការគ្នាមានសាខាមានអីស្រួលប្រួលបាន បង ពក គាត់បញ្ចូលបក្សខ្ញុំតាមសេចក្តីសម្រេចរបស់បក្សពីខាងលើ ។ គឺតាមគណៈកម្មាធិការក្រុងដែលមានបង វន ជាប្រធាន ។ ហ្នឹងខ្ញុំសូមបញ្ជាក់ជូនលោកមេធាវីថា ខ្ញុំជួបបង វន ពេលហ្នឹងឯងជាលើកទីមួយ ។

ដល់ខ្ញុំចេញទៅព្រៃ-- អូ!ដល់ថ្ងៃ៥ មករា ១៩៦៨ ខ្ញុំជាប់គុក ។ ជាប់គុក ក៏ពិតមែនតែខ្ញុំដែលដាច់ខ្សែបក្សទេ ការងារខ្ញុំមានជាប់ សំបុត្រឆ្លងឆ្លើយបញ្ជូនចេញជាប់ ។ មកដល់គុកធំ មានសាខាបក្សគេនៅនុ៎ង គ្រប់គ្រងដោយបង ទេព សឿន ។ ខ្ញុំសូមបញ្ជាក់លោកមេធាវីថា បង ទេព សឿន នេះឈ្មោះកាលនុ៎ង នៅនុ៎ងដែលជាប់គុក ដល់ក្រោយ១៧ មេសា ១៩៧៥ គាត់ប្រែឈ្មោះទៅ សរ សឿន សមាជិកអាចិន្ត្រៃយ៍សភាប្រជាជនកម្ពុជា ដែលនៅតែស្លាកនុ៎ង ។ ហើយមកដល់២០ កក្កដា ១៩៦៩ហ្នឹង ហើយដែលបង សរ សឿន បញ្ចូលបំពេញសិទ្ធិឲ្យខ្ញុំ នេះជាប្រវត្តិពិតខាងផ្នែកការងារបក្សរបស់ខ្ញុំ ។

[១៦:០៧:៣០]

**ស៖** បាទសូមឆ្លើយនូវសំណួរមួយទៀតទាក់ទងទៅហ្នឹង ចម្ងាយដែលពីតំបន់ ។

**ឆ៖** ខ្ញុំអត់ដឹងទេលោក យុង ផានិត ។ ខ្ញុំអត់ដឹងទេចម្ងាយ ។ ខ្ញុំដឹងថា ច័ន្ទរង្សី គាត់នៅច្បាមនមែន ។ ឯមន្ទីរខ្ញុំនៅអមលាំង ខ្ញុំអត់ដឹងទេ អត់ដែលបានវាស់នឹងផែនទីទេ នេះជម្រាបត្រង់ ។ មិនតិចជាង៥០គីឡូទេដឹង អានេះយើងតាមផ្លូវកាត់ជើង ។ យើងខ្ញុំអត់គិតផ្លូវខ្សែកាត់ត្រង់ ដូច្នេះខ្ញុំអត់ដឹងទេ ។

**ប្រធានអង្គជំនុំ៖**

ជាបន្ត តើមានមេធាវីក្រុមបន្តបន្ទាប់ហ្នឹង មានសំណួរអ្វីចង់សួរដល់ជនជាប់ចោទរូបនេះទេ? សូមអញ្ជើញ ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

លោកប្រធានលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយ ដោយសារតែម៉ោងវាយឺតហើយ ខ្ញុំចង់សួរជនជាប់ចោទនៅថ្ងៃស្អែក ដើម្បីឲ្យរៀបចំសំណួររបស់ខ្ញុំរួមគ្នាតែម្តង ។ ដូច្នេះខ្ញុំចង់ៗចាប់ផ្តើមសួរនៅថ្ងៃស្អែកពេលព្រឹក ។

[១៦:០៩:៣៦]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តសូមជម្រាបជូនថា អង្គជំនុំជម្រះនឹងពន្យារពេលបន្តិចនៅថ្ងៃនេះ ដោយអនុញ្ញាតឲ្យភាគីមេធាវីតំណាងបណ្តឹងរដ្ឋប្បវេណីហ្នឹង សួរសំណួរអាចពន្យារពេលត្រឹមម្ភៃមីនុត ទៀត ដើម្បីអាចទុកលទ្ធភាពអាចសួរជនជាប់ចោទបាន ។ ហើយដោយតាមការណ៍គ្រោងទុក គឺចាប់ថ្ងៃស្អែកទៅអាចជាមាននីតិវិធីត្រូវសួរសំណួរ-- ចាត់នីតិវិធីផ្សេងទៀត ។ មានការសួរសាក្សីដែលមានការពាក់ព័ន្ធនឹងអង្គហេតុនេះ ។ ឥឡូវនេះ អង្គជម្រះនឹងមិនអនុញ្ញាតឲ្យបន្តនីតិវិធីសួរនេះទៀតនៅថ្ងៃស្អែកទេ ប៉ុន្តែទុកលទ្ធភាពថ្ងៃនេះគឺបន្តអាចពីម្ភៃមីនុត ចាប់ពីពេលនេះតទៅ ។ បើមានសំណួរសូមអញ្ជើញកម្រិតត្រឹមតែម្ភៃមីនុតទៀតប៉ុណ្ណោះ ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

លោកប្រធាន ខ្ញុំសូមជំទាស់ហ្នឹងរយៈពេលដែលលោកកំណត់នៅទីនេះ គឺវាអត់មានមូលដ្ឋានទេ ដោយសារតែយើងយឺតហើយ ហើយលោកកំណត់ម្ភៃនាទីឲ្យយើង ក្រុមមេធាវីរបស់យើង ។ ហើយយើងមាន៣ក្រុម មានចំនួនច្រើន ហើយយើងមិនទាន់ឱកាសក្នុងសួរជនជាប់ចោទនៅឡើយទេ ។

ដូច្នេះ ខ្ញុំស្នើសុំឲ្យលោកចៅក្រមផ្តល់ពេលវេលាគ្រប់គ្រាន់ដល់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំសួរសំណួរទៅដល់ជនជាប់ចោទ ។ ហើយចំពោះខ្ញុំគឺម្ភៃនាទី អត់គ្រប់គ្រាន់ទេ ហើយឃើញមានក្រុមទីបី

និងទីបួន គឺយ៉ាងហោច ណាស់គាត់ចង់និយាយនិងលើកយោបល់សំណួរផងដែរ ។ ទោះបីថ្ងៃស្អែក យើងមានរបៀបវារៈយើងមួយទៀតក៏ដោយ ដែលយើងបានគ្រោងទុក ។ ខ្ញុំគិតថា ខ្ញុំត្រូវការប្រហែល សាមសិបនាទី គឺវាអាស្រ័យទៅតាមចម្លើយរបស់ជនជាប់ចោទ ពី៣០ទៅ៤៥នាទី ។ នេះគឺជាអ្វីដែល ខ្ញុំសូមជម្រាបឲ្យលោកចៅក្រមធ្វើការជ្រាបអំពីបញ្ហារយៈពេលវេលាដែលខ្ញុំត្រូវការ ។

ដូច្នេះ ខ្ញុំចង់បានសេចក្ដីសម្រេចពីលោកចៅក្រម ។

[១៦:១៣:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីបន្តនឹងសំណួរ ដែលពាក់ព័ន្ធដែលលោកស្រីចង់សួរទៅជនជាប់ចោទ តាម លទ្ធភាពពេលវេលាដែលបានកម្រិតរួចហើយ ។ ចំណែកឯ សំណួរនៅសេសសល់ថា តើអនុញ្ញាតឲ្យ បន្តការសួរនៅថ្ងៃស្អែក ឬយ៉ាងណានោះ? នេះគឺជាការសម្រេចផ្សេងមួយទៀត ដោយធ្វើការសន្សំសំចៃ ពេលវេលា និងការពន្លឿននៃដំណើរការប្រព្រឹត្តទៅ គឺអង្គជម្រះអនុញ្ញាតឲ្យលោកស្រីធ្វើការសួររហូត ដល់ម៉ោង-- ដប់ប្រាំមីនុតទៀតនឹងចប់ ។ បានប៉ុន្មានសំណួរយកប៉ុណ្ណឹង ហើយសល់សំណួរប៉ុន្មាន លោកស្រីប៉ុនប៉ងទៀត គឺនឹងបន្តនៅថ្ងៃស្អែក មិនអាចធ្វើទៅតាមតែការចង់របស់លោកស្រីបានទេ ។

មេធាវីអាចអញ្ជើញ ។ មេធាវីក្រុមផ្សេងទៀតអាច ។

[១៦:១៤:២៦]

**សួរដោយលោក ហ្វីលីព កាណុន៖**

ចំពោះក្រុមទីបី ខ្ញុំមានសំណួរប្រាំចង់សួរជាក់លាក់ ហើយខ្ញុំនឹងមិនសួរលើសពេលវេលាកំណត់ ទេ ។ ដោយមានការអនុញ្ញាតរបស់លោកចៅក្រម (លោក កាណុន បាននិយាយ) ខ្ញុំមេធាវីដើមបណ្ដឹង រដ្ឋប្បវេណីក្រុមទីបី យើងមានដើមបណ្ដឹងរដ្ឋប្បវេណី២៨នាក់ ។ សំណួររបស់ខ្ញុំដូចខាងក្រោម៖

**ស៖** លោកបានជម្រាបយើងច្រើនអំពីភាពចាំបាច់ក្នុងការយកចម្លើយសារភាព ។ ខ្ញុំចង់ដឹង តើ ប្រភេទចម្លើយសារភាពបែបណា ដែលលោកចង់បាននៅគ្រប់ពេលវេលាទាំងអស់ពីអ្នកទោស?

**ឆ៖** សេចក្ដីសារភាពដែលយើងខ្ញុំចង់បាន គឺសេចក្ដីសារភាពដែលគេនិយាយអំពី សកម្មភាព ក្បត់របស់គេ ។ តើគេធ្វើសកម្មភាពក្បត់យ៉ាងម៉េច? ប្រឆាំងនឹងបដិវត្តន៍យ៉ាងម៉េច? នេះគឺសកម្មភាព ចង់បានប៉ុណ្ណឹងឯង ។

**សៈ** ផ្អែកទៅលើការជឿរបស់លោកលើបញ្ហានយោបាយផ្សេងៗនិងការងារផ្សេងៗ ថាតើវាមានឋានានុក្រមដែរឬទេ? តើមានឋានានុក្រមយ៉ាងម៉េច?

**ឆៈ** ខ្ញុំមិនច្បាស់ពីពាក្យបារាំងថា *ត្រង់ស៊ីក្រេសស្យុង(Transgression)* ។

**សៈ** ការប្តេជ្ញាផ្អែកនយោបាយរបស់លោក គឺផ្អែកទៅលើមនោគមន៍វិជ្ជា ហើយលោកពិចារ-ណាទៅអ្នកទោសដែលនាំមកជូនលោក គឺមានពិរុទ្ធភាពដោយសារអំពើនៃការចោទប្រកាន់។ នៅក្នុងការយល់ឃើញរបស់លោក ថាតើឋានានុក្រមយ៉ាងម៉េច ចំពោះបញ្ហានៃភាពធ្ងន់ធ្ងរទៅលើបញ្ហានេះ?

[១៦:១៧:២៨]

**ឆៈ** ខ្ញុំសូមឆ្លើយតាមការសាកល្បងសិនទៅ ។ បើទាស់ខុសយ៉ាងម៉េច សូមលោកមេធាវីសួរមកម្តងទៀត ។ ទីមួយខ្ញុំសូមបញ្ជាក់ថា ឧត្តមគតិរបស់ខ្ញុំ គឺរំដោះជាតិ ប្រជាជន នេះជាការពិត ។

ដល់ថ្ងៃ២០ កក្កដា ខ្ញុំសូមបញ្ជាក់ម្តងឲ្យស្រួលស្តាប់ សូមទោសអម្បាញ់មិញខ្ញុំនិយាយលឿនពេក សូមលោកបកប្រែមេត្តាអភ័យទោស ។ ខ្ញុំចូលធ្វើបដិវត្តន៍ក្នុងឧត្តមគតិមួយត្រឹមត្រូវ គឺរំដោះជាតិ ប្រជាជនខ្លួនឯង ។ ដូច្នេះ ក្នុងនោះក៏មានមាតាបិតាខ្ញុំបងប្អូនខ្ញុំ ហើយនិងរូបខ្ញុំដែរ ។ ក៏ប៉ុន្តែ ចាប់តាំងពីថ្ងៃ២០ កក្កដា ១៩៧១ មក ទោះបីពេលហ្នឹងខ្ញុំខំប្រឹងប្រកែកយ៉ាងម៉េច ក៏ខ្ញុំដូចជា ខ្ញុំខំប្រកែកយ៉ាងម៉េច ខ្ញុំអង្វរគេយ៉ាងម៉េច? ក៏គេចមិនរួចដែរ ។ ដូច្នេះ ខ្ញុំត្រូវបង្ខំធ្វើការងារនេះ តាមពិតក៏ព្រោះខ្ញុំ-- ជំនាន់នោះខ្ញុំគ្មានឃើញលទ្ធអីដែលខ្ញុំតវ៉ាកើត ប្រកែកកើត ។ ដូច្នេះហើយបានជាខ្ញុំទទួលភារកិច្ចធ្វើមន្ទីរ-១៣នេះ ។

សកម្មភាពឧក្រិដ្ឋរបស់ខ្ញុំដំបូង វាមានលក្ខណៈនៅស្រាលទេ ។ ទារុណកម្មក៏ខ្ញុំខំជៀសវាងអតិបរមា ការសួរចម្លើយក៏មិនសួរជាបង្ខំចង់សួរចង់អីច្បាស់លាស់ទេ ។

ដូច្នេះ យើងខ្ញុំយកមនុស្សទៅធ្វើស្រែចាប់ពីពេលដែលគេប្រគល់ភារកិច្ចក្រោយពីមនុស្សរត់ចេញអស់ គេប្រគល់មនុស្សមកបណ្តើរៗ យើងខ្ញុំក៏បង្ខំចិត្តធ្វើតាមគេដោយសារតែរឿង--

ដូច្នេះ ទោះចង់មិនចង់ខ្ញុំគ្មានឃើញផ្លូវអីក្រៅពីធ្វើតាមគេតទៅទៀតទេ ខំសួរដើម្បីរកកាំភ្លើងឲ្យឃើញ ។ កាំភ្លើងដែលណាចេញពីតំបន់ខ្មាំងនាំចូលមកតំបន់រំដោះគេសារភាពថាគេលាក់ទុកនោះ គេភរទេ ព្រោះគេឈឺ ហើយខ្ញុំខំរក ។

[១៦:២៣:១១]

**សៈ** អរគុណលោកប្រធាន ខ្ញុំពិចារណាថា ជនជាប់ចោទមិនឆ្លើយតបនឹងសំណួររបស់ខ្ញុំនោះទេ ។ ដែលខ្ញុំបានសួរគាត់ ដើម្បីកុំឲ្យចំណាយពេលតុលាការ ខ្ញុំនឹងរៀបចំប្រយោគសារថ្មី គឺអត់មាន--

លោកបាននិយាយចំណុចនេះ មិនមានអ្វីដែលអាចធ្វើបានប្រសិនបើអត់មានការបញ្ជាពីខ្ញុំ ខ្ញុំជាអ្នកបញ្ជា ខ្ញុំជាអ្នកសម្រេច ។ លោកជម្រាបយើងថា អ្នកទោសមួយចំនួនបានឆ្លើយសារភាព ត្រូវបានគេដោះលែង ហើយអ្នកទោសផ្សេងទៀតមិនបានត្រូវបានដោយសារមិនឆ្លើយសារភាព ។ នេះជាសំណួររបស់ខ្ញុំ ដោយតែលោកជាសម្រេច ថាតើមានលក្ខណៈវិនិច្ឆ័យយ៉ាងម៉េច? តើមានការប៉ះពាល់នៃជម្រើសនៃការធ្វើសេចក្តីសម្រេចរបស់លោកយ៉ាងម៉េច?

**ឆ៖** រឿងនេះចូលបញ្ហាល្អិត ។ ក៏ប៉ុន្តែ ប្រសិនបើនិយាយមួយម៉ាត់ ឥឡូវខ្ញុំសូមនិយាយតែមួយម៉ាត់ខ្លី ចិត្តខ្ញុំអត់ចង់ ចិត្តខ្ញុំអត់ចង់អ្នកណាឲ្យអ្នកម្នាក់ធ្លាក់ទៅដល់ពេលស្លាប់ទេ រកវិធី-- ។ ដូច្នេះខ្ញុំរកវិធីធ្វើម៉េច សួរហើយដោះលែងមនុស្សឲ្យបាន ឧទាហរណ៍ ប្រាំអ្នកដែលគេបញ្ជូនមក ខ្ញុំមានឃើញផ្លូវដោះលែងបានតែម្នាក់ទេ ហើយខំ ខំហើយបានសម្រេចតែពាក់កណ្តាលទេ ។ ដូច្នេះ យើងចេះតែរកផ្លូវ ច្រកសម្រាប់សុំគេឲ្យរួចខ្លួនអ្នកនេះ ឲ្យរួចខ្លួនអ្នកនោះ ។ នេះជាគោលគំនិត ដល់កាលណាតែមានគោលគំនិតអ៊ីចឹងហើយ យើងចេះតែរកផ្លូវហើយ នេះជាបញ្ហាទីពីរ ជំហានទីពីរទេ ។ ដូច្នេះយើងនិយាយថាឲ្យរក *គ្រីទែរ(critère)* ស្អីច្បាស់លាស់ គឺគោលគំនិតដែលចង់ដោះលែងហ្នឹងច្បាស់លាស់ មិនមានឲ្យច្រើនពេកទៅស្លាប់ទេ ។

[១៦:២៥:៥៥]

**ស៖** ខ្ញុំចាត់ទុកថាលោកមិនបានឆ្លើយនឹងសំណួររបស់ខ្ញុំទេ ខ្ញុំកត់សម្គាល់ឃើញថាអ៊ីចឹង ។

លោកប្រធានសំនួរចុងក្រោយរបស់ខ្ញុំខ្លី គឺថាសំណួរទីបួនលោកបានប្រាប់យើងថា រណ្តៅទាំងនោះត្រូវបានជីកដើម្បីជាជម្រកអ្នកជាប់ឃុំហ្នឹង ឲ្យរួចផុតពីការទម្លាក់គ្រាប់បែក បេ-៥២ ហើយលោកក៏បាននិយាយដែរថា រណ្តៅទាំងនេះត្រូវបានប្រក់ដោយស្លឹកត្នោត ស្លឹកដូង។ តើលោកអាចពន្យល់ឲ្យជាក់លាក់បានទេ? ថាតើដំបូងបែបនោះ អាចនិងការពារ ដើម្បីការពារគ្រាប់ បេ-៥២ ដែលទម្លាក់មកបានដែរឬទេ?

**ឆ៖** រណ្តៅវាងាប់ទាំងអស់គ្នាហ្នឹង អត់មានអីការពារទេ រណ្តៅចំហរអ៊ីចឹង ។ ក៏ប៉ុន្តែ ប្រសិនបើវាទម្លាក់ខុសតែពីរម៉ែត្រ ទាំងអស់គ្នាគឺរស់ ការពារបានប៉ុណ្ណឹង ។ ទាំងខ្ញុំទាំងគេ ការពារបានប៉ុណ្ណឹង ។ ខ្ញុំក៏ជ្រកនឹងរណ្តៅចំហដែលភាគច្រើន ។

**ស៖** សំណួរតូចមួយចុងក្រោយគឺ ជាសង្ខេបបំផុត។ ជាសំណួរទាក់ទងទៅនឹងការកម្ទេច ។ លោកនិយាយថាក្នុងឱកាសមួយចំនួនច្រើន យើងប្រើពាក្យថា "កម្ទេច" ។ ខ្ញុំចង់ដឹងថាគឺជាពាក្យដែលប្រើនៅក្នុងអង្គការរបស់លោក មានន័យអ៊ីចឹង? ឬក៏វាមានន័យអី ជាពិសេសក្នុងពាក្យហ្នឹងដែរ?

**ឆ៖** ខ្ញុំនិយាយតាមពាក្យខ្មែរ ដែលខ្ញុំបានទទួលបញ្ញាពីគេ ។ សកម្មភាពជាក់ស្តែងគឺ សម្លាប់ឲ្យដាច់ជីវិត រួចហើយកប់ កុំឲ្យអ្នកណាដឹងថាយើងបានសម្លាប់ជននេះ ឬជននោះ ។ នេះសកម្មភាពជាក់ស្តែង ។ ជាមួយ វន វ៉េត អ្នកណាដែលសួរចម្លើយហើយអ៊ីចឹង គាត់ប្រាប់ថា "ដោះស្រាយ" ។

ដល់ក្រោយមកជាមួយនឹង សុន សេន គាត់ថាមិនបាច់ប្រើពាក្យ "ដោះស្រាយ" ទេ ប្រើពាក្យ "កម្ទេច" ទៅឲ្យវាចំតែម្តង ។ បើតាមខ្ញុំយល់លោកមេធាវី រឿង "កម្ទេច" ឬ "ដោះស្រាយ" គឺយើងយកគេទៅសម្លាប់ សម្លាប់រួចហើយយើងកប់ កប់ធ្វើម៉េចកុំឲ្យសត្វវាកកាយយកទៅបាន ហើយកុំអ្នកណាដឹងថាយើងកប់អ្នកណានៅកន្លែងណា ។ នេះ "កម្ទេច" ឬ "ដោះស្រាយ" វានៅតែសកម្មភាពដដែលហ្នឹងឯងទេ ។ ប៉ុន្តែ មនុស្សវាប្រើពាក្យហ្នឹង ។ ហើយដល់ក្រោយមកមានឯកសារមួយគេប្រើពាក្យ "កម្ទេច" ។

[១៦:២៩:៣០]

**លោក ហ្វីលីព កាណុន៖**

ខ្ញុំមិនមានអ្វីសួរបន្ថែមទៀតទេលោកប្រធាន ។ សូមអរគុណដែលលោកបានផ្តល់ឱកាសដល់មេធាវីក្រុមបីបានសួរ ។ អរគុណ ។

**លោក គង់ ពិសី៖**

សូមគោរពលោកប្រធាន និងហើយអង្គជំនុំជម្រះសាលាដំបូង ។ បើតាមលោកប្រធានដែលបានផ្តល់ជាការណែនាំមកថាផ្តល់ឲ្យរយៈពេលម្ភៃនាទី។ ដល់ឥឡូវបើខ្ញុំមើលម៉ោងទៅគឺថាប្រហែលជាដល់ម្ភៃនាទីហើយ ហើយខ្ញុំគ្មានពេលនឹងសួរទេ ។ ហើយខ្ញុំឈ្មោះ គង់ ពិសី ជាតំណាងឲ្យមេធាវីក្រុមបួនហើយចង់លើកជាសំណួរដែរ ។ ប្រសិនណាជាខ្ញុំផ្តល់ឱកាសឲ្យ ខ្ញុំសួរនៅពេលនេះ ខ្ញុំនឹងសួរ តែប្រសិនណាមិនផ្តល់ឱកាសឲ្យខ្ញុំទេ ខ្ញុំសូមអង្គជំនុំជម្រះរក្សាសិទ្ធិដើម្បីសួរទៅថ្ងៃស្អែកទៀត ។ តាមដែលអង្គជំនុំជម្រះសម្រេចអម្បាញ់មិញថាឲ្យសួរនៅថ្ងៃនេះ ដើម្បីឲ្យចប់សព្វគ្រប់ការសួរថ្ងៃនេះ ហើយដល់ចាំដល់ទៅថ្ងៃនឹងចាប់នីតិវិធីថ្មី ។ ខ្ញុំបាទសូមជម្រាបជូនថាយើងនៅទីនេះ គឺថាចង់បានសវនាការមួយឲ្យសមរម្យ យុត្តិធម៌ គេហៅថា *"ហ្វ៊ែរត្រាយអល (fair trial)"* អ៊ីចឹងដើម្បីឲ្យវាសមរម្យនោះភាគី

ទាំងអស់មានសិទ្ធិក្នុងការសួរ រួមទាំងឱកាសនៅក្នុងការសួរផង ។ ប្រសិនគ្រាន់តែមានសិទ្ធិក្នុងការសួរ ហើយគ្មានឱកាសនិងការសួរទេ គឺថា យើងមិនអាចស្វែងរកការពិតដោយស្របទៅនឹងគោលបំណង របស់រាជរដ្ឋាភិបាលជាមួយនឹងអង្គការសហប្រជាជាតិទេ ។ ឥឡូវ តើខ្ញុំអាចសួរទៅបានទេនៅពេល នេះ? បន្តការសួរបាន ទេ? សូមផ្តល់ការណែនាំ?

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះអង្គជម្រះសូមជម្រាបអីចេះថា ពេលវេលាក៏មានកំណត់ដែរ ប៉ុន្តែលោកមេធាវីអាច គ្រាន់តែនិយាយមកតតាំងចុះឡើងហ្នឹង វាចំណាយពេលវេលាដប់ម្ភៃមីនុត វាអាចចំណាយពេលវេលា ច្រើនរួចហើយ ។ យើងបានសម្រេចថាឲ្យនីតិវិធីប្រព្រឹត្តិទៅជាធម្មតាទៅ ដរាបណាការអនុវត្តសិទ្ធិនៅ ក្នុងការតតាំងក្តី ក្នុងការសួរនេះ មិនទាន់អនុវត្តទេនោះ យើងនឹងមានពិនិត្យលទ្ធភាពក្នុងការបន្ត បន្ត ទៀត ។ ប៉ុន្តែពេលវេលាដែលនៅសល់ប៉ុន្មាន ប្រើប្រាស់ឲ្យអស់លទ្ធភាព មិនទុកលទ្ធភាពថាម្ភៃមីនុត មិនអាចនិយាយបានទេ សូមលើកទៅថ្ងៃស្អែកនិយាយសែសិបមីនុត ឬហាសិបមីនុត តែម្តងទើបនិយាយ នោះហើយដែលជាការសម្រេចនោះ ។ យើងចង់ប្រើប្រាស់ម្ភៃមីនុត ឬសាមសិបមីនុត ចុងម៉ោងនេះ ប្រសិនបើមិនទាន់ចប់ទេ អង្គជំនុំជម្រះនិងពិនិត្យលទ្ធភាពថាដំណើរការបន្តនៅថ្ងៃស្អែកហ្នឹងគួរតែកំហិត កម្រិតត្រឹមអំឡុងពេលប៉ុន្មាន ដើម្បីពន្លឿន នៃកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ ។

ឥឡូវនេះគឺដល់ពេលវេលាត្រូវកំណត់ហើយ គឺអង្គជំនុំជម្រះសូមប្រកាសថា ពេលវេលាត្រូវ ឈប់សម្រាកនៅពេលល្ងាចហើយ អង្គជំនុំជម្រះសាលាដំបូង សូមប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃ នេះត្រឹមនេះ ។ ហើយសវនាការនឹងបន្តនៅពេលព្រឹកថ្ងៃស្អែកទី០៨ ខែមេសា ចាប់ពីម៉ោងប្រាំបួនទៅ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ កាំង ហ្គេកអ៊ាវ ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និង បង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់សាលសវនាការវិញនេះនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំហិត។ ហើយសូមជម្រាបអ្នកចូលរួមទាំងអស់ និងសាធារណជនសូមអញ្ជើញចូលរួមឲ្យបានមុនម៉ោងប្រាំបួន នៅថ្ងៃស្អែក ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង១៦:៣៣ នាទី]*